លឹម សុវណ្ណវិចិត្រ

កម្រងលំហាត់គណិតវិទ្យា

កម្រិតវិទ្យាល័យ

ភាគ ២- ពីជគណិត វិភាគ

ផ្សាយលើកទី៤
មីនា ២០១០

blank

លឹម សុវណ្ណវិចិត្រ

គម្រងលំហាត់គណិតវិទ្យា

កម្រិតវិទ្យាល័យ

ភាគ ២- ពីជគណិត វិភាគ

ផ្សាយលើកទី៩

មីនា ២០១០

ភាគ១ - ទ្រឹស្តីនៃចំនួន

ភាគ២ - ពីជគណិត វិភាគ

ផ្សាយលើកទី១ : គណិតវិទ្យាអូឡាំពិច -វិសមភាព ២០០៨

ផ្សាយលើកទី២ : កំរងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ កក្កដា២០០៩

ផ្សាយលើកទី៣ : កំរងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ សីហា ២០០៩

ផ្សាយលើកទី៤ : កម្រងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ មីនា ២០១០

ដោយ លឹម សុវណ្ណវិចិត្រ

ទំនាក់ទំនង

- វ៉ិបសាយ **http://www.dahlina.com/**
- អ៊ីមែល **lsvichet@yahoo.com**

សម្គាល់

$x \in [a; b]$ មានន័យថា $a \leq x \leq b$

$x \in (a; b)$ មានន័យថា $a < x < b$

$x \in [a; b)$ មានន័យថា $a \leq x < b$

$\binom{n}{m} = C_n^m = \frac{n!}{m!(n-m)!}$

$\mathbb{N}$ សំណុំចំនួនគត់ធម្មជាតិ ដែលមានទាំងលេខសូន្យ $\mathbb{N} = \{0;\ 1; 2; 3; \dots\}$

$\mathbb{N}^*$ សំណុំចំនួនគត់ធម្មជាតិមិនសូន្យ $\mathbb{N}^* = \{1; 2; 3; \dots\}$

$\mathbb{Z}$ សំណុំចំនួនគត់ $\mathbb{Z} = \{\dots; -3; -2;\ -1; 0; 1; 2; 3; \dots\}$

$\mathbb{Z}^*$ សំណុំចំនួនគត់មិនសូន្យ $\mathbb{Z}^* = \{\dots; -3; -2;\ -1; 1; 2; 3; \dots\}$

$\mathbb{Z}^+$ សំណុំចំនួនគត់វិជ្ជមានរឺសូន្យ $\mathbb{Z}^+ = \{0; 1; 2; 3; \dots\}$

$\mathbb{R}$ សំណុំចំនួនពិត

$\mathbb{R}^+$ សំណុំចំនួនពិតមិនអវិជ្ជមាន $\mathbb{R}^+ = \{x | x \geq 0\}$

សញ្ញាបូក

$$\sum_{i=1}^{n} x_i = x_1 + x_2 + \cdots + x_n$$

$$\sum_{1 \leq i < j \leq n} x_i x_j = x_1x_2 + x_1x_3 + x_1x_4 + \cdots + x_1x_n + x_2x_3 + x_2x_4 + \cdots + x_2x_n + \cdots + x_{n-1}x_n$$

$$\sum_{1 \leq i < j \leq 5} x_i x_j = x_1x_2 + x_1x_3 + x_1x_4 + x_1x_5 + x_2x_3 + x_2x_4 + x_2x_5 + x_3x_4 + x_3x_5 + x_4x_5$$

$$\sum_{1 \leq i < j \leq 3} \frac{x_i}{x_i + x_j} = \frac{x_1}{x_1 + x_2} + \frac{x_1}{x_1 + x_3} + \frac{x_2}{x_2 + x_3}$$

$$\sum_{1 \leq i \neq j \leq 3} x_i x_j = x_1x_2 + x_1x_3 + x_2x_1 + x_2x_3 + x_3x_1 + x_3x_2 = 2(x_1x_2 + x_1x_3 + x_2x_3)$$

និយមន័យ: ផលបូកស៊ីមេទ្រី និង ស៊ីគ្លិច

តាង $P(x,y,z)$ ជាអនុគមន៍មានបីអថេរ x,y,z។ តាង

$$\sum_{\text{cyclic}} P(x,y,z) = P(x,y,z) + P(y,z,x) + P(z,x,y)$$

$$\sum_{\text{sym}} P(x,y,z) = P(x,y,z) + P(x,z,y) + P(y,x,z)$$
$$+P(y,z,x) + P(z,x,y) + P(z,y,x)$$

ឧទាហរណ៍

$$\sum_{\text{cyclic}} x^3y = \sum_{\text{cyclic}} x^3y\,\mathrm{z}^0 = x^3yz^0 + y^3zx^0 + z^3xy^0$$
$$= x^3y + y^3z + z^3x$$
$$\sum_{\text{sym}} x^3 = \sum_{\text{sym}} x^3y^0z^0 = x^3y^0z^0 + x^3z^0y^0 + y^3x^0z^0 + y^3z^0x^0 + z^3x^0y^0 + z^3y^0x^0$$
$$= 2(x^3 + y^3 + z^3)$$
$$\sum_{\text{sym}} x^3y^2z = x^3y^2z + x^3z^2y + y^3x^2z + y^3z^2x + z^3x^2y + z^3y^2x$$
$$\sum_{\text{sym}} x^2y = \sum_{\text{sym}} x^2y^1z^0 = x^2y^1z^0 + x^2z^1y^0 + y^2x^1z^0 + y^2z^1x^0 + z^2x^1y^0 + z^2y^1x^0$$
$$= x^2y + x^2z + y^2x + y^2z + z^2x + z^2y$$
$$\sum_{\text{sym}} xyz = xyz + xzy + yxz + yzx + zxy + zyx = 6xyz$$

កន្សោមមួយមានលក្ខណៈឆ្លុះ រឺ ស៊ីមេទ្រី

កន្សោមមួយ មានលក្ខណៈស៊ីមេទ្រី បើយើងឆ្លាស់អញ្ញាតណាមួយនឹងអញ្ញាតណាមួយផ្សេងទៀត កន្សោមនោះនៅដដែល។ ឧទាហរណ៍ $P = x + y + z,\ (x,y,z) \in \mathbb{R}$ មានលក្ខណៈស៊ីមេទ្រីធៀបនឹង x,y,z ដោយសារបើយើងជំនួស x ដោយ y និង y ដោយ x វិញ វានៅដដែល។ បើយើងជំនួស x ដោយ z និង z ដោយ x វិញ វានៅដដែល។ បើយើងជំនួស y ដោយ z និង z ដោយ y វិញ វានៅដដែល។

ពហុធា $P = x^3 + y^3 + z$ មិនមានលក្ខណៈស៊ីមេទ្រីទេ ព្រោះ បើយើងជំនួស z ដោយ x និង x ដោយ z យើងទាញបាន $P' = z^3 + y^3 + x \neq x^3 + y^3 + z$ ។

ចំពោះកន្សោមស៊ីមេទ្រី យើងអាចសន្មតថា $x \geq y \geq z$ រឺ $x \leq y \leq z$ បាន បើទោះជាគេមិនប្រាប់បែបនេះក៏ដោយ រឺមួយជាទូទៅ x, y, z មិនចាំបាច់ផ្ទៀងផ្ទាត់លក្ខខណ្ឌបែបនេះក៏ដោយ លើកលែងតែមានសម្មតិកម្មមកស្រាប់ផ្សេងពីនេះ។ ហេតុអ្វីក៏យើងអាចសន្មតបានបែបនេះ?។ ព្រោះ x អាចដើរតួជំនួស y, z បាន y អាចដើរតួជំនួស x, z បាន និង z អាចដើរតួជំនួស x, y បាន។ បើមានមួយក្នុងចំនួនទាំងបីធំជាងគេ យើងតាងវាដោយ x_1 ចំនួនធំបន្ទាប់ដោយ y_1 និងតូចជាងគេដោយ z_1 ។ ដូច្នេះ $x_1 \geq y_1 \geq z_1$ ។ ដូច្នេះកន្សោមស៊ីមេទ្រី ដូចជា $P = x + y + z = x_1 + y_1 + z_1$ ។ ដូច្នេះកន្សោម P នៅតែដដែលគ្រាន់តែថែមសន្ទស្សន៍ 1 ពីក្រោមតែប៉ុណ្ណោះ។

អនុគមន៍ផត-អនុគមន៍ប៉ោង

អនុគមន៍មួយផតចន្លោះចំណុច A និង B បើ ខ្សែកោងអនុគមន៍នោះឋិតនៅក្រោមបន្ទាត់ភ្ជាប់*គ្រប់ចំណុចទាំងអស់*ឋិតនៅចន្លោះ A និង B ។ វាប៉ោងបើវានៅខាងលើ។

* អនុគមន៍ f មួយ ដែលកំណត់លើ $I \in \mathbb{R}$ ហៅថា ផត បើ ចំពោះគ្រប់ $\lambda \in [0; 1]$ និង គ្រប់ $x, y \in I$ គេមាន

$$f[\lambda x + (1-\lambda)y] \leq \lambda f(x) + (1-\lambda) f(y)$$

* អនុគមន៍មួយផតលើ $[a, b]$ បើ $f''(x) > 0, \forall x \in [a, b]$

* បើ f ផតចន្លោះ A, B នោះ តម្លៃធំបំផុតរបស់ f បើមិននៅត្រង់ A គឺនៅត្រង់ B : $f_{max} = \max(f_A, f_B)$

* បើ f ប៉ោងចន្លោះ A, B នោះ តម្លៃតូចបំផុតរបស់ f បើមិននៅត្រង់ A គឺនៅត្រង់ B : $f_{min} = \min(f_A, f_B)$



អនុគមន៍ផតចន្លោះ AB



អនុគមន៍ប៉ោងចន្លោះ AB



អនុគមន៍ផតចន្លោះ AC; អនុគមន៍ប៉ោងចន្លោះ CD;
ផតចន្លោះ DB


B
A
$\lambda f(x) + (1-\lambda) f(y)$
x
y
$\lambda x + (1-\lambda) y$
$f[\lambda x + (1-\lambda) y]$

មាតិកា

ផ្នែកទី១ លំហាត់

ផ្នែកទី២ ចម្លើយ

១. អនុគមន៍ដាយ

I. គណនា

1. គណនា $a^4+b^4+c^4$ ដោយដឹងថា $a+b+c=0$ និង $a^2+b^2+c^2=1$ ។

គណនា

2. $$S_n=1+3+6+\cdots+\frac{n(n+1)}{2}, n\in\mathbb{N}$$

3. $$S_n=1^3+2^3+3^3+\cdots+n^3, n\in\mathbb{N}$$

4. តាង $S=(2+1)(2^2+1)(2^4+1)\ldots(2^{1024}+1)+1$ ។ ចូរគណនា $S^{1/1024}$ ។

5. (**កាណាដា ១៩៦៩**)

   គណនា $1.1!+2.2!+3.3!+\cdots+(n-1).(n-1)!+n.n!$

   ដែល $n!=n.(n-1)\ldots 3.2.1$ ។

6. គណនា

$$S=\frac{1}{1!\,1999!}+\frac{1}{3!\,1997!}+\cdots+\frac{1}{1997!\,3!}+\frac{1}{1999!\,1!}$$

7. គេអោយចំនួនពិត u,v,s,t ផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$u+v+s+t=u^7+v^7+s^7+t^7=0$$

   ចូរគណនា $P=t(t+u)(t+v)(t+s)$

II. សមភាព

ចូរបង្ហាញថា

8. $$1^2+2^2+3^2+\cdots+n^2=\frac{n(n+1)(2n+1)}{6},\qquad n\in\mathbb{N}$$

9. $$\frac{1}{2}+\frac{2}{2^2}+\frac{3}{2^3}+\cdots+\frac{n}{2^n}=2-\frac{n+2}{2^n}, n\in\mathbb{N}$$

10. ចូរបង្ហាញថា បើ n ជាចំនួនគត់ធម្មជាតិ នោះ

$$1.2 + 2.5 + \cdots + n(3n-1) = n^2(n+1)$$

11. ចូរបង្ហាញថា បើ n ជាចំនួនគត់ធម្មជាតិ នោះ

$$1^2 + 3^2 + 5^2 + \cdots + (2n-1)^2 = \frac{n(4n^2-1)}{3}$$

12. តាង a, b, c ជាចំនួនពិត ខុសពី -1 និង 1 ដែល $a+b+c = abc$ ។ ចូរបង្ហាញថា

$$\frac{a}{1-a^2} + \frac{b}{1-b^2} + \frac{c}{1-c^2} = \frac{4abc}{(1-a^2)(1-b^2)(1-c^2)}$$

13. (**កាណាដា ១៩៦៩**)

ចូរបង្ហាញថា បើ $a_1/b_1 \ = a_2/b_2 \ = a_3/b_3$ និង $p_1; p_2; p_3$ មិនសូន្យទាំងអស់ព្រមគ្នា នោះ

$$\left(\frac{a_1}{b_1}\right)^n = \frac{p_1 a_1^n + p_2 a_2^n + p_3 a_3^n}{p_1 b_1^n + p_2 b_2^n + p_3 b_3^n}$$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

III. សមីការ

ដោះស្រាយសមីការ

14. $x^3 + 2x^2 - x - 2 = 0$

15. $x^3 - x^2 - 8x + 12 = 0$

16. $x^3 - 9x^2 + 27x - 27 = 0$

17. $x^3 + x^2 - 3 = 0$

18. $6x^3 + 7x^2 - 1 = 0$

19. $2x^3 + x^2 + 5x - 3 = 0$

20. $2x^4 - 5x^2 + 2 = 0$

21. $x^4 - 2x^2 - 3 = 0$

22. $(x-1)^4 + (x+1)^4 = 16$

23. $(2x-3)^4 + (2x-5)^4 = 2$

24. $\dfrac{1}{2x^2 - x + 1} + \dfrac{3}{2x^2 - x + 3} = \dfrac{10}{2x^2 - x + 7}$

25. $(x-a)x(x+a)(x+2a)=3a^4$

26. $(6x+5)^2(3x+2)(x+1)=35$

27. $x^2+\frac{4}{x^2}-8\left(x-\frac{2}{x}\right)-4=0$

28. $4x^4+6x^3-10x^2-9x+9=0$

29. $\frac{(x+1)^5}{x^5+1}=\frac{81}{11}$

30. $(x^2-6x-9)^2=x^3-4x^2-9x$

31. $x^2+\frac{25x^2}{(x+5)^2}=11$

32. $(x^2-16)(x-3)^2+9x^2=0$

33. $x^4+4x-1=0$

34. $x^4-4x^3-1=0$

35. $x^4-2x^2-400x=9999$

36. $(x^3-2x)-(x^2+2)a-2a^2x=0$

37. $(x^2-a)^2-6x^2+4x+2a=0$

38. ដោះស្រាយសមីការ $x^4-4x^3-10x^2+37x-14=0$ ដោយដឹងថាអង្គខាងឆ្វេងអាចដាក់ជាផលគុណដែលមានមេគុណជាចំនួនគត់បាន។

39. សមីការ $x^3+ax^2+bx+c=0$ ដែល a,b,c ជាចំនួនគត់ មានរឹសសនិទានមួយ តាងដោយ x_1 ។ ចូរបង្ហាញថា x_1 ជាចំនួនគត់ និងថា c ចែកដាច់នឹង x_1 ។

40. សមីការ $x^4+ax^3+bx^2+cx+d=0$ ដែល a,b,c,d ជាចំនួនគត់ មានរឹសសនិទានមួយ តាងដោយ x_1 ។ ចូរបង្ហាញថា x_1 ជាចំនួនគត់ និងថា d ចែកដាច់នឹង x_1 ។

41. សន្មតថា x_1,x_2,x_3 ជារឹសនៃសមីការ $ax^3+bx^2+cx+d=0, a\neq 0$ ។ ចូរបង្ហាញថា $x_1+x_2+x_3=-b/a\,, x_1x_2+x_2x_3+x_3x_1=c/a\,, x_1x_2x_3=-d/a$ ។

42. គេអោយសមីការ $x^3+px+q=0$ ។ ចូរគណនាផលបូកការេនៃរឹសរបស់វា។

43*. ដោះស្រាយសមីការ $x^3+3x-3=0$ ។

ចូររករឹសសនិទាននៃសមីការ

44. $x^4+2x^3-16x^2-2x+15=0$

45. $x^4 - 7x^3 + 5x^2 + 4x + 12 = 0$

46. $x^4 + x^3 - 5x - 5 = 0$

47. $x^4 + x^3 - 1 = 0$

48. $6x^4 - x^3 + 5x^2 - x - 1 = 0$

ដោះស្រាយសមីការ

49. $\sqrt{x+10} + \sqrt{x-2} = 6$

50. $\sqrt{x} - \sqrt{x+3} = 1$

51. $\sqrt{15-x} + \sqrt{3-x} = 6$

52. $\sqrt{\dfrac{20+x}{x}} + \sqrt{\dfrac{20-x}{x}} = \sqrt{6}$

53. $\sqrt{|x|+1} - \sqrt{|x|} = a$

54. $\sqrt{x^2+5x+3} - \sqrt{x^2+5x-2} = 1$

55. $\sqrt{2x+3} - \sqrt{x+1} = 1$

56. $\sqrt{2x+3} + \sqrt{x+1} = 5$

57. $\sqrt{2x-3} + \sqrt{4x+1} = 4$

58. $\sqrt{x+4} + \sqrt{2x+6} = 7$

59. $\sqrt{2x-4} - \sqrt{x+5} = 1$

60. $\sqrt{5x+7} - \sqrt{2x+3} = \sqrt{3x+4}$

61. $\sqrt{x^2+x+4} + \sqrt{x^2+x+1} = \sqrt{2x^2+2x+9}$

62. $\sqrt{x^2-9x+24} - \sqrt{6x^2-59x+149} = |5-x|$

63. $x + 12\sqrt{x} - 64 = 0$

64. $\dfrac{x-4}{\sqrt{x}+2} = x - 8$

65. $(x-3)^2 + 3x - 22 = \sqrt{x^2-3x+7}$

66. $2x^2 + 3x - 5\sqrt{2x^2+3x+9} + 3 = 0$

67. $x\sqrt{x^2+15} - 2 = \sqrt{x}\,\sqrt[4]{x^2+15}$

68. $\sqrt{\frac{x+1}{x-1}}-\sqrt{\frac{x-1}{x+1}}=\frac{3}{2}$

69. $\sqrt{\frac{x+a}{x-a}}+2\sqrt{\frac{x-a}{x+a}}=3$

70. $\sqrt{2-x}+\frac{4}{\sqrt{2-x}+3}=2$

71. $4x^2+12x\sqrt{1+x}=27(1+x)$

72. $\sqrt{7-x}+\sqrt{x-3}=a$

73*. $\sqrt[4]{x-2}+\sqrt[4]{4-x}=2$

74. $\sqrt{x^2+ax-2a}=x+1$

75. $\sqrt{2x-1}-x+a=0$

76. $\sqrt{a^2-x\sqrt{x^2+a^2}}=a-x$

77. $\sqrt{x-\sqrt{x-a}}=a$

78. $\sqrt{x+\sqrt{a^2+2a-3}}+\sqrt{x+a+\sqrt{2-2a+2a^2-a^3}}=a\sqrt{1-x}$

79. $(x-1)^2+(y+5)^2=0$

80. $x^2+y^2-2x+6y+10=0$

81. $(x+y-a)^2+(y-1)^2+(x+3)^2=0$

82*. (**ឡូរគី ១៩៩៨**)

តាង $\{a_n\}$ ជាស្វ៊ីតនៃចំនួនពិត កំនត់ដោយ $a_1=t$ និង $a_{n+1}=4a_n(1-a_n)$ ចំពោះគ្រប់ $n\geq 1$ ។ តើតំលៃរបស់ t ខុសៗគ្នាចំនួនប៉ុន្មាន ដែល $a_{1998}=0$?

83*. (MOSP ២០០១)

ចូរកំនត់គ្រប់ត្រីធាតុនៃចំនួនពិត (a,b,c) ដែល

$$a^2-2b^2=1,\ 2b^2-3c^2=1 \text{ និង } ab+bc+ca=1$$

84*. (**អន្តរជាតិ ១៩៦៣**)

ដោះស្រាយសមីការ $\sqrt{x^2-p}+2\sqrt{x^2-1}=x$ ដែល p ជាប៉ារ៉ាម៉ែត្រនិងជាចំនួនពិត។

85*. (អន្តរជាតិឡូវ៉ាគី ១៩៦៧)

គេអោយសមីការ

$$x^5+5\lambda x^4-x^3+(\lambda\alpha-4)x^2-(8\lambda+3)x+\lambda\alpha-2=0$$

ក) ចូរកំនត់ α ដើម្បីអោយសមីការមានរឹសដែលមិនអាស្រ័យនឹង λ តែមួយគត់។

ខ) ចូរកំនត់ α ដើម្បីអោយសមីការមានរឹសដែលមិនអាស្រ័យនឹង λ តែពីរគត់។

86*. (អន្តរជាតិ ១៩៥៩)

ចូរដោះស្រាយសមីការខាងក្រោម

ក) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=\sqrt{2}$

ខ) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=1$

គ) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=2$

87*. ដោះស្រាយសមីការ

$$\sqrt{x+3-4\sqrt{x-1}}+\sqrt{x+8-6\sqrt{x-1}}=1$$

88*. ដោះស្រាយសមីការ

$$\sqrt{x+2\sqrt{x+2\sqrt{x+\cdots+2\sqrt{x+2\sqrt{3x}}}}}=x$$

(មានរ៉ាឌីកាល់ចំនួន n ដង)

89. ដោះស្រាយសមីការ

$$\sqrt{x-3-2\sqrt{x-4}}+\sqrt{x-4\sqrt{x-4}}=a,$$

90. ដោះស្រាយសមីការ $(a-x)^5+(x-b)^5=(a-b)^5;\ \ a\neq b$ ។

91. ដោះស្រាយសមីការខាងក្រោមចំពោះ $x\geq -1$

$$2x^2+4x=\sqrt{\frac{x+3}{2}}$$

92. គេអោយសមីការ $x^2-3x+1=m\sqrt{x^4+x^2+1}$ (*) ដែលក្នុងនោះ m ជាប៉ារ៉ាម៉ែត្រ និង x ជាអញ្ញាត។

ក) ដោះស្រាយសមីការករណី $m=-\frac{\sqrt{3}}{3}$ ។

ខ) ចូរកំនត់តំលៃ m ដើម្បីអោយ សមីការ(*) មានរឹសចំនួនមួយ។

93. ដោះស្រាយសមីការ

$$\sqrt[3]{7x+1}-\sqrt[3]{x^2-x-8}+\sqrt[3]{x^2-8x-1}=2$$

94. ដោះស្រាយសមីការ

$$\frac{\sqrt{1+x^3}}{x^2+2}=\frac{2}{5}$$

IV. ប្រព័ន្ធសមីការ

ដោះស្រាយប្រព័ន្ធសមីការ

95. $\begin{cases} x^2-xy+3y^2+2x-5y-4=0 \\ x+2y=4 \end{cases}$

96. $\begin{cases} 2xy-y^2+5x+20=0 \\ 3x+2y-3=0 \end{cases}$

97. $\begin{cases} x^2-4y^2=200 \\ x+2y=100 \end{cases}$

98. $\begin{cases} x^2+9y^2+6xy-6x-18y-40=0 \\ x+30=2y \end{cases}$

99. $\begin{cases} x+y=5 \\ xy=6 \end{cases}$

100. $\begin{cases} x-y=5 \\ xy=-4 \end{cases}$

101. $\begin{cases} x^2+y^2=10 \\ x+y=4 \end{cases}$

102. $\begin{cases} x^4+y^4=17 \\ x+y=3 \end{cases}$

103. $\begin{cases} \dfrac{1}{x^2}+\dfrac{1}{y^2}=13 \\ \dfrac{1}{x}-\dfrac{1}{y}=1 \end{cases}$

104. $\begin{cases} x^3+y^3=7 \\ x+y=1 \end{cases}$

105. $\begin{cases} x^5+y^5=275 \\ x+y=5 \end{cases}$

106. $\begin{cases} x^3-y^3=63 \\ xy=4 \end{cases}$

107. $\begin{cases} x+y+xy=-11 \\ x^2+y^2+xy=13 \end{cases}$

108. $\begin{cases} x^2y-xy^2=30 \\ x+xy-y=13 \end{cases}$

109. $\begin{cases} (x+0{,}2)^2+(y+0{,}3)^2=1 \\ x+y=0{,}9 \end{cases}$

110. $\begin{cases} x + y + \dfrac{x}{y} = \dfrac{1}{2} \\ \dfrac{(x+y)x}{y} = -\dfrac{1}{2} \end{cases}$

111. $\begin{cases} x^3y + x^3y^2 + 2x^2y^2 + x^2y^3 + xy^3 = 30 \\ x^2y + xy + x + y + xy^2 = 11 \end{cases}$

112. $\begin{cases} 2x^2 + xy - 45y^2 = 0 \\ 2x + 9y^2 = 4 \end{cases}$

113. $\begin{cases} x^2 - 5xy = 16 \\ 2xy + y^2 = 3 \end{cases}$

114. $\begin{cases} 2x^2 + y^2 + 3xy = 12 \\ (x+y)^2 - \dfrac{1}{2}y^2 = 7 \end{cases}$

115. $\begin{cases} x^3 + xy^2 = 10 \\ x^2y - y^3 = -3 \end{cases}$

116. $\begin{cases} 10x^2 + 5y^2 - 2xy - 38x - 6y + 41 = 0 \\ 3x^2 - 2y^2 + 5xy - 17x - 6y + 20 = 0 \end{cases}$

117. $\begin{cases} y^2(x^2 - 3) + xy + 1 = 0 \\ y^2(3x^2 - 6) + xy + 2 = 0 \end{cases}$

118. $\begin{cases} \dfrac{x}{y}(x + y - 2) = \dfrac{2}{3} \\ \dfrac{y}{x}(x + y - 1) = 9 \end{cases}$

119. $\begin{cases} \dfrac{2}{x} + \dfrac{y}{3} = 3 \\ \dfrac{x}{2} + \dfrac{3}{y} = \dfrac{3}{2} \end{cases}$

120. $\begin{cases} y^2 - |xy| + 2 = 0 \\ 8 - x^2 = (x + 2y)^2 \end{cases}$

121. $\begin{cases} |xy - 2| = 6 - x^2 \\ 2 + 3y^2 = 2xy \end{cases}$

122. $\begin{cases} x + 2y - z = 5 \\ 3x - 4y + z = 1 \\ x^2 + y^2 + z^2 = 6 \end{cases}$

123. $\begin{cases} 2u + v + w = 6 \\ 3u + 2v + w = 9 \\ 3u^3 + 2v^3 + w^3 = 27 \end{cases}$

124. $\begin{cases} x + y + z = 2 \\ xy + yz + zx = -5 \\ x^2 + y^2 - z^2 = 12 \end{cases}$

125. $\begin{cases} xy + x + y = 7 \\ yz + y + z = -3 \\ xz + x + z = -5 \end{cases}$

126. $\begin{cases} x^2 - yz = 14 \\ y^2 - xz = 28 \\ z^2 - xy = -14 \end{cases}$

127. $\begin{cases} x^2 + xy + y^2 = 3 \\ y^2 + yz + z^2 = 7 \\ z^2 + zx + x^2 = 19 \end{cases}$

128. $\begin{cases} xy + xz = 8 \\ yz + xy = 9 \\ xz + yz = -7 \end{cases}$

129. $\begin{cases} \dfrac{5xy}{x+y} = 1 \\ \dfrac{7yz}{y+z} = 1 \\ 6xz = x + z \end{cases}$

130. $\begin{cases} 4xy + y^2 + 2z^2 = -3 \\ 4xz + x^2 + 2z^2 = 1 \\ 8yz + y^2 + 2z^2 = 1 \end{cases}$

131. $\begin{cases} y^3 = 9x^2 - 27x + 27 \\ z^3 = 9y^2 - 27y + 27 \\ x^3 = 9z^2 - 27z + 27 \end{cases}$

132. $\begin{cases} \dfrac{7}{\sqrt{x-7}} - \dfrac{4}{\sqrt{y+6}} = \dfrac{5}{3} \\ \dfrac{5}{\sqrt{x-7}} + \dfrac{3}{\sqrt{y+6}} = \dfrac{13}{6} \end{cases}$

133. $\begin{cases} \dfrac{4}{\sqrt{x+y} - \sqrt{x-y}} - \dfrac{1}{\sqrt[4]{x-y} - \sqrt[4]{x+y}} = 1 \\ \dfrac{2}{\sqrt{x+y} - \sqrt{x-y}} + \dfrac{4}{\sqrt[4]{x-y} - \sqrt[4]{x+y}} = \dfrac{9}{4} \end{cases}$

134. $\begin{cases} \sqrt{\dfrac{x+y}{2x-1}} + 4\sqrt{\dfrac{2x-1}{x+y}} = 5 \\ x = y + 1 \end{cases}$

135. $\begin{cases} \sqrt{\dfrac{x-y}{x+y}} + \sqrt{\dfrac{x+y}{x-y}} = \dfrac{10}{3} \\ xy - 2x - 2y = 2 \end{cases}$

136. $\begin{cases} x + y + \sqrt{\dfrac{x+y}{x-y}} = \dfrac{12}{x-y} \\ xy = 15 \end{cases}$

137. $\begin{cases} y\sqrt{x^2+y^2} - 2ay - 3 = 0 \\ x\sqrt{x^2+y^2} = 2ax \end{cases}$

138. $\begin{cases} x + y = 2 \\ xy - z^2 = 1 \end{cases}$

139. ចូរកំនត់តំលៃ a ដើម្បីអោយប្រព័ន្ធសមីការខាងក្រោមមានរឺសតែមួយគត់

$$\begin{cases}\sqrt{y} = \dfrac{1}{\sqrt{x}} \\ y = ax + 1\end{cases}$$

140*. គេអោយប្រព័ន្ធសមីការ

$$\begin{cases}\dfrac{2}{3}x + \dfrac{4}{5}y + \dfrac{5}{6}z = 61 \\ x + y + z = 79\end{cases}$$

ក) ចូរគណនាផលបូក $\frac{2}{5}y + \frac{z}{2}$; ខ) ក្នុងចំនោមរឹសជាចំនួនគត់ធម្មជាតិទាំងអស់របស់ប្រព័ន្ធ ចូរកំនត់រឹសដែលមានតំលៃ x ធំបំផុត។

141*. (**អន្តរជាតិ ១៩៦១**)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}x + y + z = a \\ x^2 + y^2 + z^2 = b^2 \\ xy = z^2\end{cases}$$

ដែល a និង b ជាចំនួនពិតដែលគេអោយ។ ចូរកំនត់លក្ខខណ្ឌលើ a និង b ដើម្បីអោយចំលើយវិជ្ជមាននិងមានតំលៃខុសគ្នា។

142*. (**អន្តរជាតិ ១៩៦៣**)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}x_5 + x_2 = yx_1 \\ x_1 + x_3 = yx_2 \\ x_2 + x_4 = yx_3 \\ x_3 + x_5 = yx_4 \\ x_4 + x_1 = yx_5\end{cases}$$

ដែលប៉ារ៉ាម៉ែត្រ $\boldsymbol{y}$ ជាចំនួនពិត។

143*. (**អន្តរជាតិ ១៩៦៤**)

គេអោយប្រព័ន្ធសមីការ

$$\begin{cases}a_{11}x_1 + a_{12}x_2 + a_{13}x_3 = 0 \\ a_{21}x_1 + a_{22}x_2 + a_{23}x_3 = 0 \\ a_{31}x_1 + a_{32}x_2 + a_{33}x_3 = 0\end{cases}$$

ដែលមានមេគុណផ្សេងផ្ទាត់លក្ខខណ្ឌខាងក្រោម

ក) a_{11}, a_{22}, a_{33} ជាចំនួនពិតវិជ្ជមាន

ខ) មេគុណផ្សេងទៀតអវិជ្ជមានទាំងអស់

គ) សមីការនិមួយៗមានផលបូកមេគុណវិជ្ជមាន។

ចូរបង្ហាញថា $x_1 = x_2 = x_3 = 0$ ជាចំលើយតែមួយគត់របស់ប្រព័ន្ធ។

144*. (អន្តរជាតិ ១៩៦៨)

ចូរកំនត់ចំនួនពិត x_1, x_2, x_3, x_4 ដែល

$$\begin{cases} x_1 + x_2x_3x_4 = 2 \\ x_2 + x_1x_3x_4 = 2 \\ x_3 + x_1x_2x_4 = 2 \\ x_4 + x_1x_2x_3 = 2 \end{cases}$$

145*. (អន្តរជាតិ ១៩៦៦)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} |a_1 - a_2|x_2 + |a_1 - a_3|x_3 + |a_1 - a_4|x_4 = 1 \\ |a_2 - a_1|x_1 + |a_2 - a_3|x_3 + |a_2 - a_4|x_4 = 1 \\ |a_3 - a_1|x_1 + |a_3 - a_2|x_3 + |a_3 - a_4|x_4 = 1 \\ |a_4 - a_1|x_1 + |a_4 - a_2|x_3 + |a_4 - a_3|x_3 = 1 \end{cases}$$

ដែល a_1, a_2, a_3 និង a_4 ជាចំនួនពិតខុសគ្នាពីរៗ។

146*. (អន្តរជាតិ ឡង់លីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x^2 + x - 1 = y \\ y^2 + y - 1 = z \\ z^2 + z - 1 = x \end{cases}$$

147. (អន្តរជាតិ ឡង់លីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} |x + y| + |1 - x| = 6 \\ |x + y + 1| + |1 - y| = 4 \end{cases}$$

148*. (អន្តរជាតិ ឡង់លីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x_1 + x_2 + \cdots + x_n = a \\ x_1^2 + x_2^2 + \cdots + x_n^2 = a^2 \\ \dots\dots \\ x_1^n + x_2^n + \cdots + x_n^n = a^n \end{cases}$$

149. (**អន្តរជាតិ ឡូជ័លីស១៩៦៧**)

តើក្នុងករណីណា ដែលប្រព័ន្ធ

$$\begin{cases} x + y + mz = a \\ x + my + z = b \\ mx + y + z = c \end{cases}$$

មានចំលើយ? ចូរកំនត់លក្ខខណ្ឌដែលចំលើយតែមួយគត់របស់ប្រព័ន្ធខាងលើ ជាស្វ៊ីតនព្វន្ត។

150*. (**អន្តរជាតិ ១៩៦៧**)

គេអោយស្វ៊ីត $(\boldsymbol{c_n})$:

$$\begin{aligned} c_1 &= a_1 + a_2 + \cdots + a_8 \\ c_2 &= a_1^2 + a_2^2 + \cdots + a_8^2 \\ \dots & \qquad \dots\dots \\ c_n &= a_1^n + a_2^n + \cdots + a_8^n \\ \dots & \qquad \dots\dots \end{aligned}$$

ដែល $a_1, a_2, \dots, a_8$ ជាចំនួនពិត ដែលមិនសូន្យទាំងអស់គ្នា។ ដោយដឹងថា ក្នុងចំនោម (c_n) មានចំនួនដែលស្មើសូន្យច្រើនរាប់មិនអស់ ចូរកំនត់តំលៃរបស់ n ដើម្បីអោយ $c_n = 0$ ។

151*. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x^2 = 2x - y \\ y^2 = 2y - z \\ z^2 = 2z - t \\ t^2 = 2t - x \end{cases}$$

152*. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x_1^2 + ax_1 + \left(\dfrac{a-1}{2}\right)^2 = x_2 \\ x_2^2 + ax_2 + \left(\dfrac{a-1}{2}\right)^2 = x_3 \\ \dots\dots\dots\dots\dots\dots\dots\dots \\ x_{1000}^2 + ax_{1000} + \left(\dfrac{a-1}{2}\right)^2 = x_1 \end{cases}$$

ដែល a ជាចំនួនពិត។

153*. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}2x_1-5x_2+3x_3=0\\2x_2-5x_3+3x_4=0\\ \dots\dots\dots\dots\dots\\2x_n-5x_1+3x_2=0\end{cases}$$

ដែល n ជាចំនួនគត់ ≥ 3 ។

154*. តាង (x,y,z) ជាចំលើយរបស់ប្រព័ន្ធសមីការ

$$\begin{cases}x=y(4-y)\\y=z(4-z)\\z=x(4-x)\end{cases}$$

ចូរកំនត់តំលៃរបស់ផលបូក $S=x+y+z$ ។

155. (**កាណាដា ១៩៧០**)

ដោះស្រាយសមីការ

$$\begin{cases}x+yz=2\\y+zx=2\\z+xy=2\end{cases}$$

156. (**អន្តរជាតិ ១៩៦៨**)

គេអោយប្រព័ន្ធសមីការ

$$\begin{cases}ax^2+bx+c=y\\ay^2+by+c=z\\az^3+bz+c=x\end{cases}$$

ដែលក្នុងនោះ $a\neq 0$ ។ តាង $\Delta=(b-1)^2-4ac$ ។ ចូរបង្ហាញថាបើ $\Delta<0$ នោះប្រព័ន្ធសមីការគ្មានរឹស។

157. ចូរកំនត់ $a\in\mathbb{R}$ ដើម្បីអោយប្រព័ន្ធ

$$\begin{cases}x^3-ay^3=\dfrac{1}{2}(a+1)^2\\x^3+ax^2y+xy^2=1\end{cases}$$

មានរឹសផ្ទៀងផ្ទាត់ $x+y=0$

158. ដោះស្រាយសមីការ

$$\begin{cases}(2-x)(3x-2z)=3-z & (1)\\y^3+3y^2=x^2-3x+2 & (2)\\y^2+z^2=6z & (3)\\z\leq 3 & (4)\end{cases}$$

159. គេអោយ $a,b,c>0$ ។ដោះស្រាយសមីការ

$$\begin{cases}\frac{a}{x}-\frac{b}{z}=c-zx\\ \frac{b}{y}-\frac{c}{x}=a-xy\\ \frac{c}{z}-\frac{a}{y}=b-yz\end{cases}$$

160. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}2x+x^2y=y\\ 2y+y^2z=z\\ 2z+z^2x=x\end{cases}$$

V. វិសមភាព

ចូរបង្ហាញថា

161. $$\frac{1}{10\sqrt{2}}<\frac{1}{2}\frac{3}{4}\frac{5}{6}\cdots\frac{99}{100}<\frac{1}{10}$$

162. $$\frac{2^{100}}{10\sqrt{2}}<\binom{100}{50}<\frac{2^{100}}{10}$$

163. $$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\le\frac{1}{\sqrt{3n+1}}, n\in\mathbb{N}$$

164. $$\frac{1}{2}\frac{3}{4}\frac{5}{6}\cdots\frac{99}{100}<\frac{1}{12}$$

165. ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n>1$ វិសមភាពខាងក្រោមពិត

$$\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{n+n}>\frac{13}{24}$$

166. ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ n វិសមភាពខាងក្រោមពិត

$$2<\left(1+\frac{1}{n}\right)^n<3$$

167. តើមួយណាធំជាង $(1{,}000001)^{1.000.000}$ រឺ 2 ?។

168. តើមួយណាធំជាង $1\,000^{1\,000}$ រឺ 1001^{999} ?។

169. (កាណាដា ១៩៦៩)

តើមួយណាធំជាង $\sqrt{c+1}-\sqrt{c}$ រឺ $\sqrt{c}-\sqrt{c-1}$ ចំពោះ $c\ge 1$?។

170. ផលគុណនៃចំនួនពិតវិជ្ជមានចំនួនn មានតំលៃស្មើមួយ។ ចូរបង្ហាញថាផលបូករបស់វា មិនមានតំលៃតូចជាង n ទេ។

171. សន្មតថា $x_1, x_2, x_3, \dots, x_n$ $(n \in \mathbb{N})$ជាចំនួនពិតមានសញ្ញាដូចគ្នា មានតំលៃធំជាង -1 ។ ចូរបង្ហាញថា $(1+x_1)(1+x_2)\dots(1+x_n) \geq 1 + x_1 + x_2 + \cdots + x_n$ ។

172. ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n > 6$ វិសមភាពខាងក្រោមពិត

$$\left(\frac{n}{2}\right)^n > n! > \left(\frac{n}{3}\right)^n$$

173. គេអោយ $f(x) = ax^2 + 1998x + c$ ដែល $a; c \in \mathbb{Z}; |a| < 2000; |c| < 2000$ ហើយ f មានរឹសពីរផ្សេងគ្នាគឺ $x_1; x_2$ ។ ចូរបង្ហាញថា $|x_1 - x_2| \geq 1/998$ ។

174. គេអោយចំនួនពិតវិជ្ជមាន a, b, x, y ផ្ទៀងផ្ទាត់

$$a + b = 1; ax + by = 2; ax^2 + by^2 = 3$$

ចូរបង្ហាញថា $4 < ax^3 + by^3 < 4{,}5$

175. គណនាតំលៃតូចបំផុតនៃ

$$S = |x| + \left|\frac{2x-1}{x+3}\right|$$

176. ចូរកំនត់ a, b, c ដើម្បីអោយ$f(x) = ax^2 + bx + c$ ផ្ទៀងផ្ទាត់ $|f(x)| \leq 1$ ចំពោះគ្រប់ $x \in [-1; 1]$ និងដែល $K = \frac{8}{3}a^2 + 2b^2$ មានតំលៃធំបំផុត។

177. គេអោយចំនួនពិតមិនអវិជ្ជមាន $a_1; a_2; a_3; a_4; a_5$ ដែល$a_1 + a_2 + a_3 + a_4 + a_5 = 1$ ។ ចូរបង្ហាញថា

$$\min_{i \neq j}\left(a_i - a_j\right)^2 \leq \frac{1}{100}; \quad \min_{i \neq j}\left|a_i^2 - a_j^2\right| \leq \frac{1}{36}$$

178. តាង a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b} < 2$$

ចំណាំ

បើជួបលក្ខខណ្ឌ a, b, c ជារង្វាស់ជ្រុងត្រីកោណ ចូរសាកល្បងតាង

$$a = x + y, b = y + z, c = z + x$$

179. គេអោយ a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$3(ab+bc+ca) \le (a+b+c)^2 < 4(ab+bc+ca)$$

180. តាង a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$\begin{aligned}(2a^2+2b^2-c^2)(2b^2+2c^2-a^2)(2c^2+2a^2-b^2)\\ \le (2a^2+bc)(2b^2+ca)(2c^2+ab)\end{aligned}$$

181. ដោយដឹងថា $f(x)=ax^2+bx+c \ge 0; \forall x \in \mathbb{R}; a<b$ ។ ចូរកំនត់ $\min F$ ដែល

$$F=\frac{a+b+c}{b-a}$$

182. (អន្តរជាតិ ១៩៦១)

តាង a, b និង c ជារង្វាស់ជ្រុងនៃត្រីកោណមួយ ដែលមានក្រលាផ្ទៃ S ។ ចូរបង្ហាញថា

$$a^2+b^2+c^2 \ge 4S\sqrt{3}$$

តើពេលណាយើងមានសមភាព?។

183. (អន្តរជាតិ ឡុងដ៍លីស១៩៦៧)

ចូរបង្ហាញថា គ្រប់គូវ៉ិចទ័រ f និង g ស្ថិតក្នុងប្លង់ វិសមភាព

$$af^2+bfg+cg^2 \ge 0$$

ពិត បើនិងមានតែបើ លក្ខខណ្ឌដូចតទៅនេះត្រូវបានផ្ទៀងផ្ទាត់៖ $a \ge 0; c \ge 0; 4ac \ge b^2$។

184. គេអោយចំនួនគត់ $n \ge 2$ និង ចំនួនពិត $a_1; a_2; \dots; a_n$ ដែល $\sum_{i=1}^{n} a_i = 0$ ។ ចូរបង្ហាញថា

$$\sum_{i<j} |a_i - a_j| \ge \frac{n}{2} \sum_{i=1}^{n} |a_i|$$

185. (អន្តរជាតិ ២០០០)

គេឱ្យ $a, b, c > 0$ ដែល $abc = 1$។ ចូរបង្ហាញថា

$$\left(a-1+\frac{1}{b}\right)\left(b-1+\frac{1}{c}\right)\left(c-1+\frac{1}{a}\right) \le 1$$

186. (ហុងគ្រី ១៩៩៦)

តាង a និង b ជាចំនួនពិតវិជ្ជមាន ដែល $a+b=1$ ។ ចូរបង្ហាញថា

$$\frac{a^2}{a+1}+\frac{b^2}{b+1} \ge \frac{1}{3}$$

187. (ប៊្រីស្តីបង)

ចូរបង្ហាញថា

ក) ចំពោះគ្រប់ចំនួនពិត a, b គេមាន $a^2+b^2 \geq 2ab$ និង $4ab \leq (a+b)^2$ វាស្មើគ្នា បើ $a=b$និង ច្រាសមកវិញ។

ខ) ចំពោះគ្រប់ចំនួនពិត $x>0$ គេមាន $x+1/x \geq 2$ ។ វាស្មើគ្នា បើ $x=1$ និង ច្រាសមកវិញ។

188. (**កាណាដា ១៩៧១**)

តាង x និង y ជាចំនួនពិតវិជ្ជមាន ដែល $x+y=1$ ។ ចូរបង្ហាញថា

$$\left(1+\frac{1}{x}\right)\left(1+\frac{1}{y}\right) \geq 9$$

189. គេអោយ២ចំនួនពិត a, b មិនសូន្យ។ ចូរកំនត់តំលៃតូចបំផុតនៃ

$$\frac{a^6}{b^6}+\frac{a^4}{b^4}+\frac{a^2}{b^2}+\frac{b^6}{a^6}+\frac{b^4}{a^4}+\frac{b^2}{a^2}$$

190. (**រុស្ស៊ី ១៩៩៨**)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $x, y>0$

$$\frac{x}{x^4+y^2}+\frac{y}{x^2+y^4} \leq \frac{1}{xy}$$

191. ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត x, y គេមាន

$$x^2+y^2+1>x\sqrt{y^2+1}+y\sqrt{x^2+1}$$

192. គេឱ្យ $x, y, z>0$ ។ ចូរបង្ហាញថា

$$\frac{x^2}{y^2}+\frac{y^2}{z^2}+\frac{z^2}{x^2} \geq \frac{x}{z}+\frac{y}{x}+\frac{z}{y}$$

193. ចូរបង្ហាញថា បើ a, b, c ជារង្វាស់ជ្រុងរបស់ត្រីកោណមួយ នោះគេមាន

$$(a+b)(b+c)(c+a) \geq 8(a+b-c)(b+c-a)(c+a-b)$$

194. គេឱ្យចំនួនពិតវិជ្ជមាន x, y, z ។ ចូរបង្ហាញថា

$$\frac{x^2-z^2}{y+z}+\frac{y^2-x^2}{z+x}+\frac{z^2-y^2}{x+y} \geq 0$$

ចូរកំណត់ករណីសមភាព។

195. (**អាស៊ីប៉ាស៊ីភិច ១៩៩៦**)

គេឱ្យ a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$\sqrt{a+b-c}+\sqrt{b+c-a}+\sqrt{c+a-b} \leq \sqrt{a}+\sqrt{b}+\sqrt{c}$$

196. (អាមេរិច ១៩៩៧)

គេអោយ $a, b, c > 0$ ។ ចូរបង្ហាញថា

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc} \le \frac{1}{abc}$$

197. (អន្តរជាតិសតលីស ១៩៩៦)

គេអោយ $a, b, c > 0$ ដែល $abc = 1$ ។ ចូរបង្ហាញថា

$$\frac{ab}{a^5+b^5+ab}+\frac{bc}{b^5+c^5+bc}+\frac{ca}{c^5+a^5+ca} \le 1$$

198. (វិសមភាពកូស៊ីស្វាត)

ចូរបង្ហាញថា គ្រប់ចំនួនពិត $a_1, a_2, \dots, a_n, b_1, b_2, \dots, b_n$ គេមាន

$$(a_1^2+\cdots+a_n^2)(b_1^2+\cdots+b_n^2) \ge (a_1b_1+\cdots+a_nb_n)^2$$

អង្គទាំង២ស្មើគ្នា បើ វ៉ិចទ័រ $(a_1, \dots, a_n)$ និង $(b_1, \dots, b_n)$ កូលីនេអ៊ែរនឹងគ្នា ។

សំគាល់

ក្នុងគណិតវិទ្យា វិសមភាពកូស៊ី–ស្វាត អ្នកខ្លះហៅថាវិសមភាពស្វាត វិសមភាពកូស៊ី រឺក៏ វិសមភាព កូស៊ី–ប៊ុន្យាកូវស្គី–ស្វាត (គឺហៅតាមឈ្មោះ អូគុស្តាំង ល្វីសកូស៊ី(Augustin Louis Cauchy), វិចទ័រ យ៉ាកូលេវិច ប៊ុន្យាកូវស្គី (Viktor Yakovlevich Bunyakovsky, គណិតវិទូរុស្ស៊ី,១៨០៤–១៨៨៩)និង ហែរម៉ាន អាម៉ានឌុស ស្វាត(Hermann Amandus Schwarz, គណិតវិទូអាល្លឺម៉ង់,១៨៤៣–១៩២១))។

199. ចូរបង្ហាញថា ចំពោះគ្រប់ $x_1, x_2, \dots, x_n > 0$ គេមាន

$$(x_1+x_2+\cdots+x_n)\left(\frac{1}{x_1}+\frac{1}{x_2}+\cdots+\frac{1}{x_n}\right) \ge n^2$$

200. ចូរបង្ហាញថា ចំពោះគ្រប់ $a, b, c > 0$ គេមាន

$$\frac{(a+2b+3c)^2}{a^2+2b^2+3c^2} \le 6$$

201. គេអោយចំនួនពិត a, b, c វិជ្ជមានដាច់ខាត ដែល $a+b+c=1$ ។ ចូរបង្ហាញថា

$$\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2 \ge \frac{100}{3}$$

202. (អាមេរិច ១៩៧៨)

គេឱ្យចំនួនពិត a, b, c, d, e ដែល

$$\begin{cases} a+b+c+d+e=8 \\ a^2+b^2+c^2+d^2+e^2=16 \end{cases}$$

ចូរកំណត់តម្លៃធំបំផុតរបស់ e ។

203. (អូស្ត្រាលី ១៩៩៣)

គេឱ្យចំនួនគត់ $n > 1$, ចំនួនពិត $a_1, a_2, \dots, a_n > 0$ និង $s = a_1 + a_2 + \cdots + a_n$ ។

ចូរបង្ហាញថា

$$\sum_{i=1}^{n} \frac{s}{s-a_i} \geq \frac{n^2}{n-1}$$

$$\sum_{i=1}^{n} \frac{s-a_i}{a_i} \geq n(n-1)$$

$$\sum_{i=1}^{n} \frac{a_i}{s-a_i} \geq \frac{n}{n-1}$$

204. (ចិន ១៩៨៧ ១៩៨៨)

ក) គេអោយ $a_1, a_2, a_3 > 0$ ដែល $(a_1^2 + a_2^2 + a_3^2)^2 > 2(a_1^4 + a_2^4 + a_3^4)$ ។ ចូរបង្ហាញថា a_1, a_2, a_3 ជារង្វាស់ជ្រុងនៃត្រីកោណមួយ។

ខ) គេអោយចំនួនគត់ $n \geq 3$ និង $a_1, a_2, \dots, a_n > 0$ ដែល

$$(a_1^2 + a_2^2 + \cdots + a_n^2)^2 > (n-1)(a_1^4 + a_2^4 + \cdots + a_n^4)$$

ចូរបង្ហាញថា គ្រប់ i, j, k ខុសគ្នាពីរៗ ចំនួន a_i, a_j, a_k ជារង្វាស់ជ្រុងនៃត្រីកោណមួយ។

205. គេអោយ $a_1, a_2, \dots, a_n > 0$ ។ តាង $S = a_1 + a_2 + \cdots + a_n$ និង $S_2 = a_1^2 + a_2^2 + \cdots + a_n^2$ ។ ចូរបង្ហាញថា

$$\frac{S_2 - a_1^2}{S_1 - a_1} + \frac{S_2 - a_2^2}{S_1 - a_2} + \cdots + \frac{S_2 - a_n^2}{S_1 - a_n} \geq S_1$$

206. (សឹង្ហបូរី ២០០០)

គេអោយ $a, b, c, d > 0$ ដែល $a^2 + b^2 = (c^2 + d^2)^3$ ។ ចូរបង្ហាញថា

$$\frac{c^3}{a} + \frac{d^3}{b} \geq 1$$

207. គេអោយ $x, y, z > 1$ ដែល $1/x + 1/y + 1/z = 2$ ។ ចូរបង្ហាញថា

$$\sqrt{x+y+z} \geq \sqrt{x-1} + \sqrt{y-1} + \sqrt{z-1}$$

208. (ឥណ្ឌា ២០០១)

គេអោយ $x, y, z > 0$ ដែល $xyz \geq xy + yz + zx$ ។ ចូរបង្ហាញថា

$$xyz \geq 3(x + y + z)$$

209. គេអោយ a, b, c ដែល $a + b + c = abc$ ។ ចូរបង្ហាញថា

$$\max(a, b, c) \geq \sqrt{3}$$

ចំណាំ

បើជួបលក្ខខណ្ឌ $a, b, c > 0$ និង $a + b + c = abc$ ចូរតាង

$$a = \tan x\,, b = \tan y\,, c = \tan z$$

ដូច្នេះ x, y, z អាចចាត់ទុកជាមុំក្នុងរបស់ត្រីកោណស្រួចបាន មានន័យថា $x, y, z \in \left[0, \frac{\pi}{2}\right)$ និង $x + y + z = \pi$ ។

210. (អន្តរជាតិ ១៩៩៩)

គេអោយចំនួនគត់ $n \geq 2$ ។

ក) ចូរកំនត់ចំនួនថេរ C តូចបំផុត ដែលចំពោះគ្រប់ចំនួនពិត $x_1, x_2, \dots, x_n \geq 0$; គេមាន

$$\sum_{1 \leq i < j \leq n} x_i x_j \left(x_i^2 + x_j^2\right) \leq C \left(\sum_{i=1}^{n} x_i\right)^4$$

ខ) ចំពោះចំនួនថេរ C នេះ ចូរកំនត់ករណីសមភាព។

211. គេអោយចំនួនពិត x, y, z, t ដែល

$$\begin{cases} x + y + z + t = 0 \\ x^2 + y^2 + z^2 + t^2 = 1 \end{cases}$$

ចូរគណនាតំលៃធំបំផុតនិងតូចបំផុតនៃ $P = xy + yz + zt + tx$ ។

212. (អន្តរជាតិសតលីស ២០០១)

តាង $x_1, x_2, \dots, x_n$ ជាចំនួនពិត។ ចូរបង្ហាញថា

$$\frac{x_1}{1 + x_1^2} + \frac{x_2}{1 + x_1^2 + x_2^2} + \cdots + \frac{x_n}{1 + x_1^2 + \cdots + x_n^2} < \sqrt{n}$$

213. (អៀរឡង់ ១៩៩៨)

ចូរបង្ហាញថា ចំពោះគ្រប់ $x; y; z > 1$ ដែល $1/x + 1/y + 1/z = 2$ គេមាន

$$\sqrt{x+y+z} \geq \sqrt{x-1}+\sqrt{y-1}+\sqrt{z-1}$$

214. (វិសមភាពតំរៀប)

គេអោយ $a_1 \leq a_2 \leq \cdots \leq a_n$ និង $b_1 \leq b_2 \leq \cdots \leq b_n$ ជាស្វ៊ីតនៃចំនួនពិត កើនពីរ។

តាង σ ជាចំលាស់នៃ$\{1,2,\ldots,n\}$ ។

ចូរបង្ហាញថា ផលបូក $S_\sigma = \sum_{i=1}^{n} a_i b_{\sigma(i)}$ មានតំលៃធំបំផុត ពេល $\sigma(i)=i$ និង តូចបំផុត ពេល $\sigma(i)=n-i$ ចំពោះគ្រប់ i ។

មានន័យថា S_σ មានតំលៃធំបំផុតពេល ស្វ៊ីតទាំង២រៀបតាមលំដាប់ដូចគ្នា ហើយ តូចបំផុតបើ រៀបតាមលំដាប់ផ្ទុយគ្នា។

215. (អន្តរជាតិ ១៩៧៥)

គេអោយចំនួនពិត $x_1 \geq x_2 \geq \cdots \geq x_n$ និង $y_1 \geq y_2 \geq \cdots \geq y_n$ ។ តាង $(z_1,z_2,\ldots,z_n)$ជាចំលាស់នៃ $(y_1,y_2,\ldots,y_n)$ ។ ចូរបង្ហាញថា

$$\sum_{i=1}^{n}(x_i-y_i)^2 \leq \sum_{i=1}^{n}(x_i-z_i)^2$$

216. ចូរគណនាតំលៃតូចបំផុតរបស់

$$f(x)=\frac{\sin^3 x}{\cos x}+\frac{\cos^3 x}{\sin x}$$

ចំពោះ $x \in (0,\pi/2)$ ។

217. ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $a,b,c \geq 0$ គេមាន

$$a^3+b^3+c^3 \geq a^2b+b^2c+c^2a \geq 3abc$$

218. (អន្តរជាតិ ១៩៧៨)

គេអោយ $(a_k)_{k\in\mathbb{N}}$ ជាស្វ៊ីតនៃចំនួនគត់ធម្មជាតិមិនសូន្យ ហើយមានតួខុសគ្នាពីរៗ។

ចូរបង្ហាញថា ចំពោះគ្រប់ $n \geq 1$ គេមាន

$$\sum_{k=1}^{n}\frac{a_k}{k^2} \geq \sum_{k=1}^{n}\frac{1}{k}$$

219. (ចិន ១៩៨៤/១៩៨៥)

គេអោយ $a_1,a_2,\ldots,a_n > 0$ ។ ចូរបង្ហាញថា

$$\frac{a_1^2}{a_2}+\frac{a_2^2}{a_3}+\cdots+\frac{a_{n-1}^2}{a_n}+\frac{a_n^2}{a_1}\geq a_1+a_2+\cdots+a_n$$

220. គេអោយចំនួនមិនអវិជ្ជមាន p,q,x,y,z ។ ចូរបង្ហាញថា

$$\frac{x^{2000}}{py+qz}+\frac{y^{2000}}{pz+qx}+\frac{z^{2000}}{px+qy}\geq\frac{x^{1999}+y^{1999}+z^{1999}}{p+q}$$

221. (វិសមភាព Chebyshev)

ចំពោះគ្រប់ស្វ៊ីតកើននៃចំនួនពិតពីរ តាងដោយ $a_1\leq a_2\leq\cdots\leq a_n$ និង $b_1\leq b_2\leq\cdots\leq b_n$ គេមាន

$$\frac{a_1+a_2+\cdots+a_n}{n}\frac{b_1+b_2+\cdots+b_n}{n}\leq\frac{a_1b_1+a_2b_2+\cdots+a_nb_n}{n}$$

ផ្ទុយទៅវិញ បើ $b_1\geq b_2\geq\cdots\geq b_n$ នោះ

$$\frac{a_1+a_2+\cdots+a_n}{n}\frac{b_1+b_2+\cdots+b_n}{n}\geq\frac{a_1b_1+a_2b_2+\cdots+a_nb_n}{n}$$

Pafnuty Lvovich Chebyshev

គណិតវិទូរុស្ស៊ី,១៨២១–១៨៩៤

222. (វិសមភាពណេសប៊ីត)

គេអោយ a,b,c ជាចំនួនពិតវិជ្ជមាន។ ចូរបង្ហាញថា

$$\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\geq\frac{3}{2}$$

223. គេអោយ $a,b,c,d \geq 0$ ដែល $ab+bc+cd+da=1$ ។ ចូរបង្ហាញថា

$$\frac{a^3}{b+c+d}+\frac{b^3}{c+d+a}+\frac{c^3}{d+a+b}+\frac{d^3}{a+b+c} \geq \frac{1}{3}$$

224. គេអោយ $a,b,c>0$ និង $n \in \mathbb{N}^*$ ។ ចូរបង្ហាញថា

$$\frac{a^n}{b+c}+\frac{b^n}{c+a}+\frac{c^n}{a+b} \geq \frac{a^{n-1}+b^{n-1}+c^{n-1}}{2}$$

225. គេអោយ $x,y,z>0$ ដែល $xyz=1$ ។ ចូរបង្ហាញថា

$$\frac{x^3}{(1+y)(1+z)}+\frac{y^3}{(1+z)(1+x)}+\frac{z^3}{(1+x)(1+y)} \geq \frac{3}{4}$$

226.** (វិសមភាពមធ្យមនព្វន្ត-មធ្យមធរណីមាត្រ មធ-មជ រឺវិសមភាពកូស៊ី)

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a_1,a_2,\dots,a_n$ រឺសូន្យ គេមាន

$$\sqrt[n]{a_1a_2\dots a_n} \leq \frac{a_1+a_2+\cdots+a_n}{n}$$

ដោយសមភាពកើតមាន ទាល់តែ និងមានតែ $a_1=a_2=\cdots=a_n$ តែប៉ុណ្ណោះ។

227. (អន្តរជាតិ ១៩៦៤)

តាង a,b,c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$a^2(b+c-a)+b^2(c+a-b)+c^2(a+b-c) \leq 3abc$$

228. (អន្តរជាតិ ឡូដ៍លីស១៩៦៧)

ចូរបង្ហាញថា

$$\frac{1}{3}n^2+\frac{1}{2}n+\frac{1}{6} \geq (n!)^{\frac{2}{n}}$$

(n ជាចំនួនគត់វិជ្ជមាន) ហើយបង្ហាញថាសមភាពអាចតែក្នុងករណី $n=1$ មួយតែប៉ុណ្ណោះ។

229. (អន្តរជាតិ ឡូដ៍លីស១៩៦៧)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន វិសមភាពខាងក្រោមពិត

$$\frac{1}{a}+\frac{1}{b}+\frac{1}{c} \leq \frac{a^8+b^8+c^8}{a^3b^3c^3}$$

230. (អន្តរជាតិ ឡូដ៍លីស ១៩៦៧)

ចូរស្រាយបញ្ជាក់វិសមភាព

$$x_1x_2\dots x_k\left(x_1^{n-1}+x_2^{n-1}+\cdots+x_k^{n-1}\right) \leq x_1^{n+k-1}+x_2^{n+k-1}+\cdots+x_k^{n+k-1}$$

ដែល $x_i > 0\ (i = 1,2, \dots, k), k \in \mathbb{N}, n \in \mathbb{N}$ ។

231. ចូរបង្ហាញថា ចំពោះគ្រប់ $x_1, x_2, \dots, x_n > 0$ គេមាន

$$(x_1 + x_2 + \cdots + x_n)\left(\frac{1}{x_1} + \frac{1}{x_2} + \cdots + \frac{1}{x_n}\right) \geq n^2$$

232.** (រុស្ស៊ី ២០០០)

គេអោយ $x, y, z \in \mathbb{R}^+$ ដែល $xyz = 1$ ។ ចូរបង្ហាញថា

$$x^2 + y^2 + z^2 + x + y + z \geq 2(xy + yz + zx)$$

233. (សូវៀត ១៩៦២)

គេអោយ $a, b, c, d > 0$ ដែល $abcd = 1$ ។ ចូរបង្ហាញថា

$$a^2 + b^2 + c^2 + d^2 + ab + ac + ad + bc + bd + cd \geq 10$$

234. គេអោយ $a, b, c \geq 0$ ។ ចូរបង្ហាញថា

$$(a + b + c)^3 \geq a^3 + b^3 + c^3 + 24abc$$

235. គេអោយ $a, b, c > 0$ ។ ចូរបង្ហាញថា

$$abc \geq (a + b - c)(b + c - a)(c + a - b)$$

236. គេអោយ $a_1, a_2, \dots, a_n \in \mathbb{R}^+$ ដែល $a_1 + a_2 + \cdots + a_n = 1$ ។ ចូរបង្ហាញថា

$$\prod_{k=1}^{n} a_k(1 - a_k) \leq \frac{(n-1)^n}{n^{2n}}$$

237. (អូទ្រីស ២០០០)

គេអោយចំនួនពិត a, b ដែល $a \neq 0$ ។ ចូរបង្ហាញថា

$$a^2 + b^2 + \frac{1}{a^2} + \frac{b}{a} \geq \sqrt{3}$$

238. ចំពោះ $n \in \mathbb{N}^*$ តាង

$$U_n = \left(1 + \frac{1}{n}\right)^n ;\ V_n = \left(1 + \frac{1}{n}\right)^{n+1}$$

ចូរបង្ហាញថា ស្វ៊ីត (U_n) ជាស្វ៊ីតកើន ហើយស្វ៊ីត (V_n) ជាស្វ៊ីតចុះ។

239.** (សូវៀត ១៩៦៩)

គេអោយចំនួនគត់ $n \geq 3$ និង $a_1, a_2, \dots, a_n \in \mathbb{R}^{+*}$ ។ ចូរបង្ហាញថា

$$\frac{a_1}{a_2 + a_3} + \frac{a_2}{a_3 + a_4} + \cdots + \frac{a_{n-1}}{a_n + a_1} + \frac{a_n}{a_1 + a_2} > \frac{n}{4}$$

240. (ចិន ១៩៨៩/១៩៩០)

គេអោយ $a_1, a_2, \ldots, a_n > 0$ ដែល $a_1 a_2 \ldots a_n = 1$ ។ ចូរបង្ហាញថា

$$(2 + a_1)(2 + a_2) \ldots (2 + a_n) \geq 3^n$$

241.** តាង a និង b ជាចំនួនពិតវិជ្ជមាន។ ចូរបង្ហាញថា

$$\frac{1}{\sqrt{1+a^2}} + \frac{1}{\sqrt{1+b^2}} \geq \frac{2}{\sqrt{1+ab}}$$

បើ (1) $0 < a, b \leq 1$ រឺក៏ (1) $ab \geq 3$ ។

242. គេអោយ $x_1, x_2, \ldots, x_{n+1} > 0$ ដែល

$$\frac{1}{1+x_1} + \frac{1}{1+x_2} + \cdots + \frac{1}{1+x_{n+1}} = 1$$

ចូរបង្ហាញថា $x_1 x_2 \ldots x_{n+1} \geq n^{n+1}$ ។

243. គេអោយចំនួនគត់ $n > 1, x_1 x_2 \ldots x_n \in \mathbb{R}^{+*}$និង $a_1, a_2, \ldots, a_n \in \mathbb{R}^+$ ។ តាង $s = x_1 + x_2 + \cdots + x_n$ ។ ចូរកំនត់ចំនួនថេរ $C(n)$ ធំបំផុត ដែល

$$\sum_{j=1}^{n} \frac{a_j(s - x_j)}{x_j} \geq C(n) \left[\prod_{j=1}^{n} a_j\right]^{\frac{1}{n}}$$

244. គេអោយ $x, y, z > 0$ ដែល $x + y + z = 1$ ។ ចូរបង្ហាញថា

$$\left(1 + \frac{1}{x}\right)\left(1 + \frac{1}{y}\right)\left(1 + \frac{1}{z}\right) \geq 64$$

245.* (រូម៉ានី ១៩៩៧)

គេអោយ ចំនួនគត់ $n \geq 2$ និង $x_1, x_2, \ldots, x_n > 0$ ដែល $x_1 x_2 \ldots x_n = 1$ ។

ចូរគណនាតំលៃតូចបំផុតរបស់

$$\sum_{1 \leq i < j \leq n} \frac{x_i^9 + x_j^9}{x_i^6 + x_i^3 x_j^3 + x_j^6}$$

246.* គេអោយ $a, b, c, d \geq 0$ ដែល $a + b + c + d = 1$ ។ ចូរបង្ហាញថា

$$abc + bcd + cda + dab \leq \frac{1}{27} + \frac{176}{27} abcd$$

247.* គេអោយ $a_1, a_2, \ldots, a_n \in \mathbb{R}^{+*}$ ដែល $a_1 + a_2 + \cdots + a_n = 1$ ។ ចូរបង្ហាញថា

$$\frac{1}{n^{n-3}} \frac{1}{a_1 a_2 \ldots a_n} \geq n^2(n-1) + \sum_{k=1}^{n} \frac{1}{a_k}$$

248. គេអោយ $a_1, a_2, \dots, a_n \in \mathbb{R}^{+*}$ ដែល $a_1 + a_2 + \cdots + a_n < 1$ ។ ចូរបង្ហាញថា

$$\frac{a_1 a_2 \dots a_n (1 - a_1 - a_2 - \cdots - a_n)}{(a_1 + a_2 + \cdots + a_n)(1 - a_1)(1 - a_2) \dots (1 - a_n)} \le \frac{1}{n^{n+1}}$$

249. (**អាមេរិចសតលីស ២០០៤**)

ចូរគណនាតំលៃធំបំផុតរបស់ $S = (1 - x_1)(1 - y_1) + (1 - x_2)(1 - y_2)$

បើ $x_1^2 + x_2^2 = y_1^2 + y_2^2 = c^2$ ។

250. (**អន្តរជាតិ ១៩៩៥**)

តាង abc ជាចំនួនវិជ្ជមាន ដែល $abc = 1$ ។ ចូរបង្ហាញថា

$$\frac{1}{a^3(b+c)} + \frac{1}{b^3(c+a)} + \frac{1}{c^3(a+b)} \ge \frac{3}{2}$$

251. (**អន្តរជាតិ ២០០១**)

តាង a, b, c ជាចំនួនពិតវិជ្ជមាន។ ចូរបង្ហាញថា

$$\frac{a}{\sqrt{a^2 + 8bc}} + \frac{b}{\sqrt{b^2 + 8ca}} + \frac{c}{\sqrt{c^2 + 8ab}} \ge 1$$

252. តាង a, b, c ជាចំនួនពិត។ ចូរបង្ហាញថា

$$(ab + bc + ca - 1)^2 \le (a^2 + 1)(b^2 + 1)(c^2 + 1)$$

253. (**អន្តរជាតិ ១៩៨៤**)

តាង x, y, z ជាចំនួនពិតមិនអវិជ្ជមាន ដែល $x + y + z = 1$ ។ ចូរបង្ហាញថា

$$0 \le xy + yz + zx - 2xyz \le \frac{7}{27}$$

254. គេអោយចំនួនពិតវិជ្ជមាន x, y, z ។ ចូរបង្ហាញថា

$$\left(1 + \frac{x}{y}\right)\left(1 + \frac{y}{z}\right)\left(1 + \frac{z}{x}\right) \ge 2\left(1 + \frac{x + y + z}{\sqrt[3]{xyz}}\right)$$

255. គេអោយចំនួនពិតបួនផ្សេងគ្នា a, b, c, d ដែល

$$\frac{a}{b} + \frac{b}{c} + \frac{c}{d} + \frac{d}{a} = 4; \quad ac = bd$$

ចូរគណនាតំលៃធំបំផុតនៃ

$$\frac{a}{c} + \frac{b}{d} + \frac{c}{a} + \frac{d}{b}$$

256. គេអោយ a, b, c ជារង្វាស់ជ្រុងនៃត្រីកោណមួយមានបរិមាត្រ ស្មើ 2 ។ ចូរបង្ហាញថា

$$\frac{52}{27} \le a^2 + b^2 + c^2 + 2abc < 2$$

257. ចំពោះគ្រប់ $a, b, c > 0$។ ចូរបង្ហាញថា

$$\sqrt{(a^2b + b^2c + c^2a)(ab^2 + bc^2 + ca^2)} \ge abc + \sqrt[3]{(a^3 + abc)(b^3 + abc)(c^3 + abc)}$$

258. 1) ចូរបង្ហាញថា ចំពោះគ្រប់ចំនួនសនិទានវិជ្ជមាន p, q ដែល $p + q = 1$ គេមាន

$$pa + qb \ge a^p b^q;\ \forall\, a, b > 0$$

2) ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន p, q ដែល $p + q = 1$ គេមាន

$$px + qy \ge x^p y^q;\ \forall\, x, y > 0$$

3) (**វិសមភាពមធ-មធធូនៅ**)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $a_1, a_2, \dots, a_n > 0$ ដែល $a_1 + a_2 + \cdots + a_n = 1$ គេមាន

$$a_1x_1 + a_2x_2 + \cdots + a_nx_n \ge x_1^{a_1} x_2^{a_2} \dots x_n^{a_n};\quad \forall x_1, x_2, \dots, x_n > 0$$

4) (**វិសមភាព** Hölder)

គេអោយ $p, q \in \mathbb{R}^{+*}$ ដែល $1/p + 1/q = 1$ និង បណ្ដាចំនួនពិត $a_1, a_2, \dots, a_n$ និង $b_1, b_2, \dots, b_n$ ចូរបង្ហាញថា

$$|a_1b_1| + |a_2b_2| + \cdots + |a_nb_n| \le (|a_1|^p + |a_2|^p + \cdots + |a_n|^p)^{\frac{1}{p}} \times (|b_1|^q + |b_2|^q + \cdots + |b_n|^q)^{\frac{1}{q}}$$

ដែលអង្គទាំងពីរស្មើគ្នា លុះត្រាតែ វ៉ិចទ័រ $\vec{u}(a_1^p, a_2^p, \dots, a_n^p)$ និង វ៉ិចទ័រ $\vec{v}(b_1^q, b_2^q, \dots, b_n^q)$ កូលីនេអ៊ែរនឹងគ្នា ហើយ បណ្ដា a_ib_i សុទ្ធតែវិជ្ជមានរឺសូន្យទាំងអស់ រឺបើមិនអញ្ចឹង សុទ្ធតែអវិជ្ជមានរឺសូន្យទាំងអស់។

259. គេអោយ $a, b \ge 0$ និង $p, q > 1$ ដែល $1/p + 1/q = 1$។ ចូរបង្ហាញថា

$$\frac{a^p}{p} + \frac{b^q}{q} \ge ab$$

260. (**ប៉ូឡូញ ១៩៩៨**)

គេអោយចំនួនគត់ $n \ge 1$ ចូរកំនត់តំលៃតូចបំផុតរបស់ផលបូក

$$x_1 + \frac{x_2^2}{2} + \cdots + \frac{x_n^n}{n}$$

ដែល $x_1, x_2, \dots, x_n$ ជាចំនួនពិត ដែល $1/x_1 + 1/x_2 + \cdots + 1/x_n = n$ ។

261. (វិសមភាព Minkowski)

តាង $p \in [1;\ +\infty)$ ហើយ $a_1, a_2, \dots, a_n$ និង $b_1, b_2, \dots, b_n$ ជាចំនួនពិត។ ចូរបង្ហាញថា

$$\begin{aligned}(|a_1+b_1|^p+|a_2+b_2|^p+\cdots+|a_n+b_n|^p)^{\frac{1}{p}}\\ \le (|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}+(|b_1|^p+|b_2|^p+\cdots+|b_n|^p)^{\frac{1}{p}}\end{aligned}$$

ដែលអង្គទាំងពីរស្មើគ្នា លុះត្រាតែ វ៉ិចទ័រ $\vec{u}(a_1, a_2, \dots, a_n)$ និង វ៉ិចទ័រ $\vec{v}(b_1, b_2, \dots, b_n)$ កូលីនេអ៊ែរនឹងគ្នា ហើយមានទិសដៅដូចគ្នា។

262. គេអោយ $x, y, z > 0$ ។ ចូរបង្ហាញថា

$$\frac{x^{\frac{4}{3}}}{x^{\frac{4}{3}}+(x^2+y^2)^{\frac{1}{3}}(x+z)^{\frac{2}{3}}}+\frac{y^{\frac{4}{3}}}{y^{\frac{4}{3}}+(y^2+z^2)^{\frac{1}{3}}(y+x)^{\frac{2}{3}}}+\frac{z^{\frac{4}{3}}}{z^{\frac{4}{3}}+(z^2+x^2)^{\frac{1}{3}}(z+y)^{\frac{2}{3}}}\le 1$$

263. គេអោយចំនួនពិត a, b, c, d ។ ចូរកំនត់តំលៃតូចបំផុតរបស់

$$\begin{aligned}S=\sqrt{(a+1)^2+2(b-2)^2+(c+3)^2}+\sqrt{(b+1)^2+2(c-2)^2+(d+3)^2}\\ +\sqrt{(c+1)^2+2(d-2)^2+(a+3)^2}\\ +\sqrt{(d+1)^2+2(a-2)^2+(b+3)^2}\end{aligned}$$

264. តាង x, y, z ជាចំនួនពិតវិជ្ជមាន

1) ចូរបង្ហាញថា បើ $x+y+z=xyz$ នោះ

$$\frac{x}{\sqrt{1+x^2}}+\frac{y}{\sqrt{1+y^2}}+\frac{z}{\sqrt{1+z^2}}\le\frac{3\sqrt{3}}{2}$$

2) ចូរបង្ហាញថា បើ $0<x, y, z<1$ និង $xy+yz+zx=1$ នោះ

$$\frac{x}{1-x^2}+\frac{y}{1-y^2}+\frac{z}{1-z^2}\ge\frac{3\sqrt{3}}{2}$$

265. (បេឡារុស ១៩៩៩)

គេអោយស្វ៊ីតនៃចំនួនពិតពីរ $x_1, x_2, \dots$ និង $y_1, y_2, \dots$ កំនត់ដោយ

$$x_1=y_1=\sqrt{3};\ x_{n+1}=x_n+\sqrt{1+x_n^2};\ y_{n+1}=\frac{y_n}{1+\sqrt{1+y_n^2}}$$

ចំពោះគ្រប់ $n\ge 1$ ។ ចូរបង្ហាញថា $2<x_ny_n<3$ ចំពោះគ្រប់ $n>1$ ។

266. តាង $x_1, x_2, \dots, x_n$ ជាចំនួនពិតខុសៗគ្នាចំនួន n ឋិតក្នុងចន្លោះ $[-1; 1]$ ដែល $n\ge 2$ ។ ចូរបង្ហាញថា

$$\frac{1}{t_1}+\frac{1}{t_2}+\cdots+\frac{1}{t_n}\geq 2^{n-2}$$

ដែល $t_i=\prod_{j\neq i}|x_j-x_i|$ ។

267. យើងយកចំនួនពិតបួននៅក្នុងចន្លោះ $\left[\frac{\sqrt{2}-\sqrt{6}}{2};\frac{\sqrt{2}+\sqrt{6}}{2}\right]$ ដោយមិនបាច់រើស។ ចូរបង្ហាញថា ត្រូវតែមានពីរក្នុងចំនោមនោះ តាងដោយ a និង b ដែល

$$\left|a\sqrt{4-b^2}-b\sqrt{4-a^2}\right|\leq 2$$

268. (**វិសមភាពយិនសិន**)

តាង $n\geq 1$ ជាចំនួនគត់ ហើយ f ជាអនុគមន៍ផត លើដែន I ។ ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $l_1,l_2,\dots,l_n\in\mathbb{R}^{+*}$ ដែល $l_1+l_2+\cdots+l_n=1$ គេមាន

$$f(l_1x_1+l_2x_2+\cdots+l_nx_n)\leq l_1f(x_1)+l_2f(x_2)+\cdots+l_nf(x_n);$$
$$\forall x_1,x_2,\dots,x_n\in I$$

ហើយ បើ f ផតដាច់ខាត នោះកន្សោមខាងលើក្លាយជាសមភាព ពេល $x_1=x_2=\cdots=x_n$

ករណី f ជាអនុគមន៍ប៉ោង :

$$f(l_1x_1+l_2x_2+\cdots+l_nx_n)\geq l_1f(x_1)+l_2f(x_2)+\cdots+l_nf(x_n);$$
$$\forall x_1,x_2,\dots,x_n\in I$$

យ៉ូហាន យិនសិន

(Johan Jensen)

ឈ្មោះពេញ យ៉ូហាន លុយឌ្វិច វីលាម វ៉ាល់ដឺមែរ យិនសិន

(Johan Ludwig William Valdemar Jensen)

(ឧសភា ១៨៥៩ - កុម្ភៈ ១៩២៥) គណិតវិទូ និង វិស្វករជាតិដាណឺម៉ាក។ គេស្គាល់គាត់ដោយសារវិសមភាពយិនសិន។ ក្នុងឆ្នាំ ១៩១៥ គាត់បានបង្ហាញថា រូបមន្តវិសមភាពរបស់គាត់អាចប្រើបានលើ វិភាគកុំផ្លិច។

269. (កូរ៉េ ១៩៩៨)

គេអោយ $a, b, c > 0$ ដែល $a + b + c = abc$ ។ ចូរបង្ហាញថា

$$\frac{1}{\sqrt{1+a^2}} + \frac{1}{\sqrt{1+b^2}} + \frac{1}{\sqrt{1+c^2}} \leq \frac{3}{2}$$

270. ចូរកំនត់ចំនួនថេរ M តូចបំផុត ដែលចំពោះគ្រប់ $a, b > 0$ គេមាន

$$a^{\frac{1}{3}} + b^{\frac{1}{3}} \leq M(a+b)^{\frac{1}{3}}$$

271. គេអោយ $x_1, x_2, \dots, x_n \in \mathbb{R}^{+*}$ ដែល $x_1 + x_2 + \cdots + x_n = 1$។ ចូរបង្ហាញថា

$$\frac{x_1}{\sqrt{1-x_1}} + \frac{x_2}{\sqrt{1-x_2}} + \cdots + \frac{x_n}{\sqrt{1-x_n}} \geq \sqrt{\frac{n}{n-1}}$$

272. (អូទ្រីស ២០០០)

គេអោយ $a, b > 0$ និង $n \in \mathbb{Z}$ ។ ចូរបង្ហាញថា

$$\left(1+\frac{a}{b}\right)^n + \left(1+\frac{b}{a}\right)^n \geq 2^{n+1}$$

273. (អន្តរជាតិ ២០០១)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $l \geq 8$ និង $a, b, c > 0$ គេមាន

$$\frac{a}{\sqrt{a^2+\lambda bc}} + \frac{b}{\sqrt{b^2+\lambda ca}} + \frac{c}{\sqrt{c^2+\lambda ab}} \geq \frac{3}{\sqrt{1+\lambda}}$$

274. គេអោយចំនួនគត់ $n \geq 1$ ។ តាង $\alpha, t \in [1; +\infty)$ និង $\beta \in \mathbb{R}^{+*}$។

តាង $a_1, a_2, \dots, a_n \in \mathbb{R}^{+*}$ ដែល $a_1 + a_2 + \cdots + a_n = 1$ ។ ចូរបង្ហាញថា

$$\sum_{i=1}^{n} \left(a_i^{\alpha} + \frac{1}{a_i^{\beta}}\right)^t \geq n\left(\frac{1}{n^{\alpha}} + n^{\beta}\right)^t$$

ដោយអង្គទាំងពីរស្មើគ្នា ទាល់តែនិងនាំអោយ $a_1 = a_2 = \cdots = a_n = 1/n$ ។

275. (អន្តរជាតិសតលីស ១៩៩៨)

គេអោយ $x_1, x_2, \dots, x_n \geq 1$ ។ ចូរបង្ហាញថា

$$\frac{1}{x_1+1} + \frac{1}{x_2+1} + \cdots + \frac{1}{x_n+1} \geq \frac{n}{1+(x_1x_2\dots x_n)^{\frac{1}{n}}}$$

276. (អាមេរិច ១៩៨០)

គេអោយ $a, b, c \in [0; 1]$ ។ ចូរបង្ហាញថា

$$\frac{a}{b+c+1}+\frac{b}{c+a+1}+\frac{c}{a+b+1}+(1-a)(1-b)(1-c)\leq 1$$

277. (**អាមេរិច ១៩៧៧**)

គេអោយ $0<p\leq a,b,c,d,e\leq q$ ។ ចូរបង្ហាញថា

$$(a+b+c+d+e)\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}+\frac{1}{d}+\frac{1}{e}\right)\leq 25+6\left(\sqrt{\frac{p}{q}}-\sqrt{\frac{q}{p}}\right)^2$$

278. (**អាស៊ីប៉ាស៊ីភិច ២០០៤**)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $a,b,c>0$

$$(a^2+2)(b^2+2)(c^2+2)\geq 9(ab+bc+ca)$$

279. (**អន្តរជាតិ ១៩៨៣**)

តាង a,b,c ជារង្វាស់ជ្រុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$a^2b(a-b)+b^2c(b-c)+c^2a(c-a)\geq 0$$

280. **និយមន័យ**- គេអោយ ចំនួនគត់ $n\geq 2$ បណ្តាចំនួនពិតវិជ្ជមាន $a_1,a_2,\dots,a_n$ និង បណ្តាចំនួនពិតវិជ្ជមាន $l_1,l_2,\dots,l_n$ ដែល $\sum_{i=1}^{n}l_i=1$ ។ យើងកំនត់អនុគមន៍ M លើ $\mathbb{R}^*$ ដោយ

$$M(a)=\left[\sum_{i=1}^{n}l_ia_i^{\alpha}\right]^{\frac{1}{\alpha}}$$

គេហៅ $M(\alpha)$ ថា មធ្យមលំដាប់ α នៃបណ្តាចំនួន a_i ផ្សំនឹងមេគុណ l_i ។

ទ្រឹស្តីបទ វិសមភាពមធ្យមលំដាប់ α

គេអោយ $a_1,a_2,\dots,a_n>0$ មិនស្មើគ្នាទាំងអស់ និង $l_1,l_2,\dots,l_n>0$ ដែល $l_1+l_2+\cdots+l_n=1$ ។ ចូរបង្ហាញថា អនុគមន៍ $M(\alpha)$ កើនដាច់ខាតលើ $\mathbb{R}$ មានន័យថា ចំពោះគ្រប់ $a_1,a_2,\dots,a_n>0$ និង $\alpha<\beta$ គេមាន $M(\alpha)\leq M(\beta)$ ដោយអង្គទាំងពីរស្មើគ្នា ទាល់តែនិងនាំអោយ $a_1=a_2=\cdots=a_n$ ។

281. ចូរបង្ហាញថា ចំពោះ $a_1,a_2,\dots,a_n>0$ គេមាន

$$\min\{a_1,a_2,\dots,a_n\}\leq M(-1)\leq M(0)\leq M(1)\leq M(2)\leq \max\{a_1,a_2,\dots,a_n\}$$

រឺ

$$\min\{a_1, a_2, \dots, a_n\} \le \frac{n}{\frac{1}{a_1} + \frac{1}{a_2} + \dots + \frac{1}{a_n}} \le (a_1 a_2 \dots a_n)^{\frac{1}{n}} \le \frac{a_1 + a_2 + \dots + a_n}{n}$$
$$\le \sqrt{\frac{a_1^2 + a_2^2 + \dots + a_n^2}{n}}$$

ហើយសមភាពកើតមាន ពេល $a_1 = a_2 = \dots = a_n$ ។

282. (អៀរ៉ង់ ១៩៩៨)

គេអោយ $x_1, x_2, x_3, x_4 > 0$ ដែល $x_1 x_2 x_3 x_4 = 1$ ។ ចូរបង្ហាញថា

$$\sum_{i=1}^{4} x_i^3 \ge \max\left\{\sum_{i=1}^{4} x_i ; \sum_{i=1}^{4} \frac{1}{x_i}\right\}$$

283. គេអោយ $x, y, z \ge 0$ ។ ចូរបង្ហាញថា

$$8(x^3 + y^3 + z^3)^2 \ge 9(x^2 + yz)(y^2 + zx)(z^2 + xy)$$

284. គេអោយចំនួនគត់ $n > 1$ និង $x_1, x_2, \dots, x_n > 0$ ដែល $x_1 + x_2 + \dots + x_n = 1$

ចូរបង្ហាញថា

$$\frac{x_1}{\sqrt{1 - x_1}} + \frac{x_2}{\sqrt{1 - x_2}} + \dots + \frac{x_n}{\sqrt{1 - x_n}} \ge \frac{\sqrt{x_1} + \sqrt{x_2} + \dots + \sqrt{x_n}}{\sqrt{n - 1}}$$

285. (ទួរគី ១៩៩៧)

គេអោយចំនួនគត់ $n \ge 2$ ។ ចូរគណនាតំលៃតូចបំផុតនៃ

$$\frac{x_1^5}{x_2 + x_3 + \dots + x_n} + \frac{x_2^5}{x_1 + x_3 + \dots + x_n} + \dots + \frac{x_n^5}{x_1 + x_2 + \dots + x_{n-1}}$$

ដែល $x_1, x_2, \dots, x_n > 0$ ហើយ $x_1^2 + x_2^2 + \dots + x_n^2 = 1$ ។

286. (វិសមភាព Schur)

តាង $x; y; z$ ជាចំនួនពិតមិនអវិជ្ជមាន។ ចូរបង្ហាញថា ចំពោះគ្រប់ $r > 0$ យើងមាន

$$x^r(x - y)(x - z) + y^r(y - z)(y - x) + z^r(z - x)(z - y) \ge 0$$

រឺ

$$\sum_{\text{cyclic}} x^r(x - y)(x - z) \ge 0$$

287. 1) គេអោយ $a,b,c>0$ ។ ចូរបង្ហាញថា

$$\begin{aligned} a^3+b^3+c^3+3abc &\geq ab(a+b)+bc(b+c)+ca(c+a) \\ &\geq 2\left[(ab)^{3/2}+(bc)^{3/2}+(ca)^{3/2}\right] \end{aligned}$$

2) តាង $t\in(0;3]$។ ចំពោះគ្រប់ $a,b,c\geq 0$ ចូរបង្ហាញថា

$$(3-t)+t(abc)^{2/t}+a^2+b^2+c^2\geq 2(ab+bc+ca)$$

3) បង្ហាញថា

$$\begin{aligned} &\frac{5}{2}+\frac{1}{2}(abc)^4+a^2+b^2+c^2\geq 2(ab+bc+ca) \\ &2+(abc)^2+a^2+b^2+c^2\geq 2(ab+bc+ca) \\ &1+2abc+a^2+b^2+c^2\geq 2(ab+bc+ca) \end{aligned}$$

288. គេអោយ $a,b,c>0$។ ចូរបង្ហាញថា

1) $$\frac{b+c}{a^2+bc}+\frac{c+a}{b^2+ca}+\frac{a+b}{c^2+ab}\leq\frac{1}{a}+\frac{1}{b}+\frac{1}{c}$$

2) $$\frac{a^2+bc}{b+c}+\frac{b^2+ca}{c+a}+\frac{c^2+ab}{a+b}\geq a+b+c$$

289. 1) តាង a_1,a_2,b_1,b_2 ជាចំនួនពិតវិជ្ជមាន ដែល $a_1+a_2=b_1+b_2$ និង $\max(a_1,a_2)\geq\max(b_1,b_2)$។ តាង x និង y ជាចំនួនពិតមិនអវិជ្ជមាន។ ចូរបង្ហាញថា

$$x^{a_1}y^{a_2}+x^{a_2}y^{a_1}\geq x^{b_1}y^{b_2}+x^{b_2}y^{b_1}$$

2) (**វិសមភាព** Muirhead)

តាង $a_1;a_2;a_3;b_1;b_2;b_3$ ជាចំនួនពិត ដែល

$$\begin{aligned} &a_1\geq a_2\geq a_3\geq 0;b_1\geq b_2\geq b_3\geq 0; \\ &a_1\geq b_1;a_1+a_2\geq b_1+b_2; \\ &a_1+a_2+a_3=b_1+b_2+b_3 \end{aligned}$$

ករណីនេះ គេថាស្វ៊ីត $(a_1;a_2;a_3)$ *លប់* លើស្វ៊ីត $(b_1;b_2;b_3)$។

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $x;y;z$ គេមាន

$$\sum_{\text{sym}}x^{a_1}y^{a_2}z^{a_3}\geq\sum_{\text{sym}}x^{b_1}y^{b_2}z^{b_3}$$

290. គេអោយ a,b,c ជាចំនួនវិជ្ជមាន ដែល $abc=1$ ។ ចូរបង្ហាញថា

$$\frac{1}{a+b+1}+\frac{1}{b+c+1}+\frac{1}{c+a+1}\leq 1$$

291. គេអោយ $a,b,c,d>0$ ។ ចូរបង្ហាញថា

$$\frac{3}{2}(a^3+b^3+c^3+d^3)\geq ab\sqrt{cd}+ac\sqrt{bd}+ad\sqrt{bc}+bc\sqrt{da}+bd\sqrt{ca}+cd\sqrt{ab}$$

292. (អៀរ៉ង់ ១៩៩៦)

តាង $x; y; z$ ជាចំនួនពិតវិជ្ជមាន។ ចូរបង្ហាញថា

$$(xy+yz+zx)\left(\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\right)\geq\frac{9}{4}$$

293. តាង $x; y; z$ ជាចំនួនពិតវិជ្ជមាន ដែល $xy+yz+zx=1$។ ចូរបង្ហាញថា

$$\frac{1}{x+y}+\frac{1}{y+z}+\frac{1}{z+x}\geq\frac{5}{2}$$

294. (អន្តរជាតិសតលីស ១៩៩០)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត a, b, c យើងមាន

$$(a^2+ab+b^2)(b^2+bc+c^2)(c^2+ca+a^2)\geq(ab+bc+ca)^3$$

295. (អៀរ៉ង់ ១៩៩៦)

គេអោយ $x, y, z>0$ ។ ចូរបង្ហាញថា

$$(xy+yz+zx)\left(\frac{1}{(x+y)^2}+\frac{1}{(y+z)^2}+\frac{1}{(z+x)^2}\right)\geq\frac{9}{4}$$

296. (ជប៉ុន ១៩៩៧)

គេអោយ $a, b, c>0$ ។ ចូរបង្ហាញថា

$$\frac{(b+c-a)^2}{(b+c)^2+a^2}+\frac{(c+a-b)^2}{(c+a)^2+b^2}+\frac{(a+b-c)^2}{(a+b)^2+c^2}\geq\frac{3}{5}$$

VI. វិសមីការ

ដោះស្រាយវិសមីការ

297. $x^3-3x^2-10x+24>0$

298. $x^3+4x^2+5x+2\leq 0$

299. $2x^3-3x^2+7x-3>0$

300. $x^4-3x^3+x^2+3x-2\geq 0$

301. $x^4+6x^3+6x^2+6x+5<0$

302. $3x^4-10x^2+3>0$

303. $3x^2(x-4)^2<32-5(x-2)^2$

304. $(x^2-x)^2+(x^2-x)+2\geq 0$

305. $x(x+1)(x+2)(x+3)<48$

306. $(x+1)^4>2(1+x^4)$

307. $x^4-x^3-10x^2+2x+4<0$

308. $\dfrac{1}{x}<\dfrac{2}{x-2}$ 309. $\dfrac{x+4}{x-2}<\dfrac{2}{x+1}$

310. $\dfrac{1}{x+1}-\dfrac{1}{x}\leq\dfrac{1}{x-1}-\dfrac{1}{x-2}$

311. $\dfrac{x^2-x+1}{x-1}+\dfrac{x^2-3x+1}{x-3}>2x-\dfrac{1}{4x-8}$

312. $\dfrac{x^3-2x^2+5x+2}{x^2+3x+2}\geq 1$

313. $\dfrac{1}{x+5}+\dfrac{1}{x-7}+\dfrac{1}{x-5}+\dfrac{1}{x+7}>0$

314. $\dfrac{1}{x^2+x}\leq\dfrac{1}{2x^2+2x+3}$

315. $\dfrac{1}{x-1}-\dfrac{4}{x-2}+\dfrac{4}{x-3}-\dfrac{1}{x-4}<\dfrac{1}{30}$

316. $\dfrac{4x-17}{x-4}+\dfrac{10x-13}{2x-3}>\dfrac{8x-30}{2x-7}+\dfrac{5x-4}{x-1}$

317. $x^2+\dfrac{x^2}{(x+1)^2}<\dfrac{5}{4}$ 318. $x^2+\dfrac{4x^2}{(x-2)^2}\leq 5$

319. $\dfrac{(x+1)^4}{x(x^2+1)}>\dfrac{128}{15}$

320. $x^3-\dfrac{1}{x^3}\geq 4\left(x-\dfrac{1}{x}\right)$

321. $\dfrac{x+6}{x-6}\left(\dfrac{x-4}{x+4}\right)^2+\dfrac{x-6}{x+6}\left(\dfrac{x+9}{x-9}\right)^2<\dfrac{2x^2+72}{x^2-36}$

322. $|x^3-x|\leq x$ 323. $\dfrac{4}{|x+1|-2}\geq|x-1|$

324. $(x-1)\sqrt{x^2-x-2} \geq 0$

325. $\sqrt{\dfrac{x-2}{1-2x}} > -1$

326. $\sqrt{4-x^2} + \dfrac{|x|}{x} \geq 0$

327. $(1-a)\sqrt{2x+1} < 1$

328. $\sqrt{x+1} > \sqrt{3-x}$

329. $\sqrt{x+2} \geq \sqrt{x-a}$

330. $\sqrt{24-10x} > 3-4x$

331. $x > \sqrt{1-x}$

332. $x > \sqrt{24-5x}$

333. $\sqrt{\dfrac{1}{x^2} - \dfrac{3}{4}} < \dfrac{1}{x} - \dfrac{1}{2}$

334. $\sqrt{4-\sqrt{1-x}} - \sqrt{2-x} > 0$

335. $\sqrt{x^2+x-12} < x$

336. $1-\sqrt{13+3x^2} \leq 2x$

337. $\sqrt{x^2+x} > 1-2x$

338. $4-x < \sqrt{x^2-2x}$

339. $\sqrt{x+3} > \sqrt{x-1} + \sqrt{x-2}$

340. $\dfrac{x-2}{\sqrt{2x-3}-1} < 4$

341. $\dfrac{2-\sqrt{x+3}}{x-1} > -\dfrac{1}{3}$

342. $\sqrt{x+2} - \sqrt{5x} > 4x-2$

343. $\sqrt{x+1} + 1 < 4x^2 + \sqrt{3x}$

344. $\dfrac{\sqrt{24+2x-x^2}}{x} < 1$

345. $2\left(x+\sqrt{x^2+4x+3}\right) < 3\left(\sqrt{x+1}+\sqrt{x+3}-2\right)$

346. ចូរបង្ហាញថាពហុធា $P(x) = x^8 - x^5 + x^2 - x + 1 > 0,\ \forall x \in \mathbb{R}$ ។

347. សន្មតថា $P(x) = a_0x^m + a_1x^{m-1} + \cdots + a_{m-1}x + a_m$ និង $Q(x) = b_0x^n + b_1x^{n-1} + \cdots + b_{n-1}x + b_n, m \in \mathbb{N}, n \in \mathbb{N}, Q(x) \not\equiv 0$ ។ ចូរបង្ហាញថាវិសមភាព $P(x)/Q(x) > 0$ និង $P(x)Q(x) > 0$ សមមូលគ្នា។

348. ដោយដឹងថា $f(-1) < 1, f(1) > -1\,, f(3) < -4$ ដែល $f(x) = ax^2 + bx + c, a \neq 0$ ចូរកំនត់សញ្ញារបស់ a ។

349. (**អន្តរជាតិ ១៩៦០**)

ដោះស្រាយវិសមីការ

$$\frac{4x^2}{\left(1-\sqrt{1+2x}\right)^2} < 2x + 9$$

350. (**អន្តរជាតិ ១៩៦២**)

ដោះស្រាយវិសមីការ

$$\sqrt{3-x} - \sqrt{x+1} > \frac{1}{2}$$

351. ដោះស្រាយវិសមីការ

$$\sqrt{9x^2+16} \geq 2\sqrt{2x+4} + 4\sqrt{2-x}$$

VII. ប្រព័ន្ធវិសមីការ

352*. ដោះស្រាយប្រព័ន្ធវិសមីការ

$$\begin{cases} x + y \leq 2, \\ x + y \geq 1, \\ x \geq 0, \\ y \geq 0 \end{cases}$$

ដែលក្នុងនោះ $z = 2x + 3y$ មានតំលៃធំបំផុត។

353. ចូរកំនត់រឹសគត់ធម្មជាតិរបស់ប្រព័ន្ធ

$$\begin{cases} x = y + 2 \\ xy \leq 17 \\ \dfrac{y+1}{x+2} < \dfrac{1}{2} \end{cases}$$

354. ចូរកំនត់តំលៃរបស់ a ដែលសំនុំ

$$\{(x;y) | x^2 + y^2 + 2x \leq 1\} \cap \{(x;y) | x - y + a \geq 0\}$$

មានចំនុចតែមួយគត់។ ចូរកំនត់ចំនុចនោះ។

355. ចូរកំនត់$(x;y)$ ដែល

$$\begin{cases} x^2 - 2xy + 12 = 0 \\ x^2 + 4y^2 \leq 60 \\ x \in \mathbb{Z} \end{cases}$$

356. ដោះស្រាយប្រព័ន្ធវិសមីការ

$$\begin{cases}\sqrt{4-3x} \geq x \\ \sqrt{x}+\sqrt{x-1} < 5\end{cases}$$

357. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}x^3+x^2(13-y-z)+x(2y+2z-2yz-26)+5yz-7y-7z+30=0 & (1) \\ x^3+x^2(17-y-z)-x(2y+2z+2yz-26)-3yz+y+z-2=0 & (2) \\ x^2-11x+28 \leq 0 & (3)\end{cases}$$

358. ចូរកំនត់ a ដើម្បីអោយប្រព័ន្ធខាងក្រោមមានរឹស

$$\begin{cases}x^2+2xy-7y^2 \geq \dfrac{1-a}{a+1} \\ 3x^2+10xy-5y^2 \leq -2\end{cases}$$

២. អនុគមន៍អិចស្ប៉ូណង់ស្យែល-លោការីត

I. គណនា

គណនា

359. $25^{\log_5 3}$

360. $e^{\ln \ln 3}$

361. $\ln ab - \ln|b|$

362. $\log_a b^2 + \log_{a^2} b^4$

363. $2^{\frac{1}{\log_3 2}}$

364. $\dfrac{\log_2 25}{\log_2 5}$

365. $\log_3 5 \,.\, \log_4 9 \,.\, \log_5 2$

366. $\sqrt{\log_{0,5}^2 4}$

367. $a^{\sqrt{\log_a b}} - b^{\sqrt{\log_b a}}$

368. ចូរគណនា $\log_{30} 8$ បើ $\log_{30} 3 = c, \log_{30} 5 = d$ ។

369. ចូរគណនា $\log_9 40$ បើ $\log 15 = c, \log_{20} 50 = d$ ។

370. ចូរគណនា $\log(0,175)^4$ បើ $\log 196 = c, \log 56 = d$ ។

371. គណនា

$$\frac{\log_2 24}{\log_{96} 2} - \frac{\log_2 192}{\log_{12} 2}$$

II. សមភាព

372. ចូរបង្ហាញថា បើ $a = \log_{12} 18\,, b = \log_{24} 54$ នោះ $ab + 5(a - b) = 1$ ។

III. សមីការ

ដោះស្រាយសមីការ

373. $4^{x+1,5} + 9^x = 6^{x+1}$

374. $25^{2x-x^2+1} + 9^{2x-x^2+1} = 34.15^{2x-x^2}$

375. $2^{2x^2} + 2^{x^2+2x+2} = 2^{5+4x}$

376. $\left(\sqrt{5\sqrt{2}-7}\right)^x + 6\left(\sqrt{5\sqrt{2}+7}\right)^x = 7$

377. $3^{2x^2} - 2.3^{x^2+x+6} + 3^{2(x+6)} = 0$

378. $x^2.2^{\sqrt{2x+1}-1} + 2^x = 2^{\sqrt{2x+1}+1} + x^2.2^{x-2}$

379. $4^{\log_{64}(x-3)+\log_2 5} = 50$

380. $x^{\log_x(1-x)^2} = 9$

381. $\log_3(x^2 + 4x + 12) = 2$

382. $\log_3 x + \log_9 x + \log_{27} x = 5,5$

383. $\log_2(3 - x) + \log_2(1 - x) = 3$

384. $\log(x - 3) + \log(x + 6) = \log 2 + \log 5$

385. $\log(x - 4) + \log(x + 3) = \log(5x + 4)$

386. $\ln(x^3 + 1) - 0,5\ln(x^2 + 2x + 1) = \ln 3$

387. $\log_5(x - 2) + 2\log_5(x^3 - 2) + \log_5(x - 2)^{-1} = 4$

388. $2\log_3(x - 2) + \log_3(x - 4)^2 = 0$

389. $\log_2(x + 2)^2 + \log_2(x + 10)^2 = 4\log_2 3$

390. $\log_2\dfrac{x-2}{x-1} - 1 = \log_2\dfrac{3x-7}{3x-1}$

391. $2\log_2 \frac{x-7}{x-1} + \log_2 \frac{x-1}{x+1} = 1$

392. $\log_3(5x-2) - 2\log_3 \sqrt{3x+1} = 1 - \log_3 4$

393. $\log(3x-2) - 2 = \frac{1}{2}\log(x+2) - \log 50$

394. $\log^2\left(1+\frac{4}{x}\right) + \log^2\left(1-\frac{4}{x+4}\right) = 2\log^2\left(\frac{2}{x-1}-1\right)$

395. $\log_2 x^4 + \log_a x^2 = 1$

396. $\log_2(x-1) - \log_{\sqrt{2}} \sqrt{x+3} = \log_8(x-a)^3 + \log_{1/2}(x-3)$

397. $\log_2(6x^2+25x) = 1 + \log_2(ax+4a-2)$

398. $\log_3 x \log_4 x \log_5 x = \log_3 x \log_4 x + \log_4 x \log_5 x + \log_5 x \log_3 x$

399. $\left(\log_3 \frac{3}{x}\right)\log_2 x - \log_3 \frac{x^3}{\sqrt{3}} = \frac{1}{2} + \log_2 \sqrt{x}$

400. $\log(10x^2)\log x = 1$

401. $\frac{\log_2 x - 1}{\log_2 \frac{x}{2}} = 2\log_2 \sqrt{x} + 3 - \log_2^2 x$

402. $2\log_9 x + 9\log_x 3 = 10$

403. $\log_x(125x)\log_{25}^2 x = 1$

404. $\log_x \sqrt{5} + \log_x 5x = \frac{9}{4} + \log_x^2 \sqrt{5}$

405. $\log(\log x) + \log(\log x^3 - 2) = 0$

406. $\log_{3x+7}(9+12x+4x^2) = 4 - \log_{2x+3}(6x^2+23x+21)$

407. $\log^2(4-x) + \log(4-x)\log\left(x+\frac{1}{2}\right) - 2\log^2\left(x+\frac{1}{2}\right) = 0$

408. $(x^2\log_x 27)\log_9 x = x + 4$

409. $\log_x 2 - \log_4 x + \frac{7}{6} = 0$

410. $\log_{0,5x} x^2 - 14\log_{16x} x^3 + 40\log_{4x}\sqrt{x} = 0$

411. $4\log_{\frac{x}{2}}\sqrt{x} + 2\log_{4x} x^2 = 3\log_{2x} x^3$

412. $\log_{3x}\left(\frac{3}{x}\right) + \log_3^2 x = 1$

413. $\left(\log_{1/\sqrt{1+x}} 10\right)\log(x^2 - 3x + 2) = (\log(x-3))\log_{1/\sqrt{1+x}} 10 - 2$

414. $\dfrac{\log_x(2a - x)}{\log_x 2} + \dfrac{\log_a x}{\log_a 2} = \dfrac{1}{\log_{a^2-1} 2}$

415. $\dfrac{\log_{a^2\sqrt{x}} a}{\log_{2x} a} + (\log_{ax} a)\log_{\frac{1}{a}} 2x = 0$

416. $\sqrt{1 + \log_{0,04} x} + \sqrt{3 + \log_{0,2} x} = 1$

417. $\sqrt{2 - \log_x 9} = -\dfrac{\sqrt{12}}{\log_3 x}$

418. $\log_x(x^2 + 1) = \sqrt{\log_{\sqrt{x}}\left(x^2(1 + x^2)\right) + 4}$

419. $\sqrt{\log_2 x} - 0,5 = \log_2\sqrt{x}$

420. $\log(3^x - 2^{4-x}) = 2 + \frac{1}{4}\log 16 - \frac{x}{2}\log 4$

421. $\log_3\left(\log_9 x + \frac{1}{2} + 9^x\right) = 2x$

422. $\log_3\left(3^{x^2-13x+28} + \frac{2}{9}\right) = \log_5 0,2$

423. $\log 2 + \log(4^{x-2} + 9) = 1 + \log(2^{x-2} + 1)$

424. $\log(6.5^x + 25.20^x) = x + \log 5$

425. $\log_{\sqrt{5}}(4^x - 6) - \log_5(2^x - 2)^2 = 2$

426. $x(1-\log 5)=\log(4^x-12)$

427. $\log_2(4^x+1)=x+\log_2(2^{x+3}-6)$

428. $\log_3(9^x+9)=x-\log_{\frac{1}{3}}(28-2.3^x)$

429. $\log_2\left(\frac{8}{2^x}-1\right)=x-2$

430. $\log_{1/3}\left(2\left(\frac{1}{2}\right)^x-1\right)=\log_{1/3}\left(\left(\frac{1}{4}\right)^x-4\right)$

431. $(x+1)^{\log(x+1)}=100(x+1)$

432. $x^{\frac{\log x+5}{3}}=10^{5+\log x}$

433. $3^{\log x}=54-x^{\log 3}$

434. $\log_2(9-2^x)=10^{\log(3-x)}$

435. $|x-1|^{\log^2 x-\log x^2}=|x-1|^3$

436. $\left(3^{x^2-7,2x+3,9}-9\sqrt{3}\right)\log(7-x)=0$

437. $3.2^{\log_x(3x-2)}+2.3^{\log_x(3x-2)}=5.6\text{^}\log_{x^2}(3x-2)$

438. $\left|1-\log_{1/5}x\right|+2=\left|3-\log_{1/5}x\right|$

439. $\log_4\left(6+\sqrt{x}-\left|\sqrt{x}-2\right|\right)=\frac{1}{2}+\log_2\left|\sqrt{x}-\left|\sqrt{x}-2\right|\right|$

440. $5^x+12^x=13^x$

441. $3^x+4^x+5^x=6^x$

442. $2^x=1-x$

443. $\log_2(4-x)=x-3$

444. ដោយដឹងថា $x = 9$ ជាឫសមួយនៃសមីការ

$$\log_{\pi}(x^2 + 15a^2) - \log_{\pi}(a-2) = \log_{\pi}\frac{8ax}{a-2}$$

ចូរកំនត់ឫសផ្សេងទៀតនៃសមីការនេះ។

IV. ប្រព័ន្ធសមីការ

ដោះស្រាយប្រព័ន្ធសមីការ

445. $$\begin{cases}\log_{a^2} x - \log_{a^4} y = 3\\ \log_{a^6} x + \log_{a^8} y = 4\end{cases}$$

446. $$\begin{cases}2^{x+y-1} + 2^{x-y+1} = 3\\ \dfrac{1}{7}.3^{x\log_3 2 + y\log_3 2 - 2} + 3^{x\log_3 2 - y\log_3 2 - 2} = \dfrac{1}{7}\end{cases}$$

447. $$\begin{cases}10^{1+\log(x+y)} = 50\\ \log(x-y) + \log(x+y) = 2 - \log 5\end{cases}$$

448. $$\begin{cases}x^{\log_x 2} = \log_3(x+y)\\ x^2 + y^2 = 65\end{cases}$$

449. $$\begin{cases}\log_2(x+y) - \log_3(x-y) = 1\\ x^2 - y^2 = 2\end{cases}$$

450. $$\begin{cases}(3y^2+1)\log_3 x = 1\\ x^{2y^2+10} = 27\end{cases}$$

451. $$\begin{cases}4^{-y}\log_2 x = 4\\ \log_2 x + 2^{-2y} = 4\end{cases}$$

452. $$\begin{cases}y + \log x = 1\\ x^y = 0{,}01\end{cases}$$

453. $$\begin{cases}x^{\log y} = 2\\ xy = 20\end{cases}$$

454. $\begin{cases} 2^x.8^{-y} = 2\sqrt{2} \\ \log_9 \dfrac{1}{x} + 0,5 = \dfrac{1}{2}\log_3 9y \end{cases}$

455. $\begin{cases} (\log_a(xy) - 2)\left(\log_a \dfrac{4}{9}\right)^{-1} = -1 \\ x + y = 5a \end{cases}$

456. $\begin{cases} 2\left(\log_y x + \log_x y\right) = 5 \\ xy = 8 \end{cases}$

457. $\begin{cases} \log_x y + \log_y x = 2,5 \\ x + y = a^2 + a \end{cases}$

458. $\begin{cases} \dfrac{x^2}{y} + \dfrac{y^2}{x} = 28 \\ \log_9 x - \log_{\frac{1}{9}} y = 1,5 \end{cases}$

459. $\begin{cases} \log_2 y = \log_4(xy - 2) \\ \log_9 x^2 + \log_3(x - y) = 1 \end{cases}$

460. $\begin{cases} 2^{x^2+y} = 4^{\frac{y^2+x}{2}} \\ \sqrt{xy} = 2 \end{cases}$

461. $\begin{cases} 4^{\frac{x}{y}-3y/x} = 16 \\ \sqrt{x} - \sqrt{2y} = \sqrt{12} - \sqrt{8} \end{cases}$

462. $\begin{cases} x + y = 4 + \sqrt{y^2 + 2} \\ \log x - 2\log 2 = \log(1 + 0,5y) \end{cases}$

463. $\begin{cases} \log_3(\log_2 x) + \log_{1/3}\left(\log_{1/2} y\right) = 1 \\ xy^2 = 4 \end{cases}$

464. $\begin{cases} \dfrac{1}{3}\sqrt[y]{9} = 9^{\frac{x}{2y}} \\ \dfrac{x + 3y}{x} = \dfrac{2x}{y} - 4 \end{cases}$

V. វិសមភាព

465. តើមួយណាធំជាង រវាង 2^{300} និង 3^{200} ?

466. ចូរបង្ហាញថា

$$\log_n(n+1) > \log_{n+1}(n+2)$$

ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n > 1$ ។

467. ដោយមិនប្រើតារាង ចូរបង្ហាញថា $\log_4 9 > \log_9 25$ ។

468. គេអោយ $x_1, x_2, \dots, x_n > 0$ ។ ចូរបង្ហាញថា

$$x_1^{x_1}.x_2^{x_2}\dots x_n^{x_n} \geq (x_1.x_2\dots x_n)^{\frac{x_1+x_2+\cdots+x_n}{n}}$$

469. (អាមេរិច សតលីស១៩៩៩)

គេអោយ $x, y, z > 1$។ ចូរបង្ហាញថា

$$x^{x^2+2yz}y^{y^2+2zx}z^{z^2+2xy} \geq (xyz)^{xy+yz+zx}$$

VI. វិសមីការ

ដោះស្រាយវិសមីការ

470. $\log_{1/5}(2x^2+5x+1) < 0$

471. $\log_{1/3}(x^2+2x) > 0$

472. $\log_{1/2}(x^2-4x+6) < -2$

473. $\log_{1/3}\dfrac{3x-1}{x+2} < 1$

474. $\log_{0,25}\dfrac{35-x^2}{x} \geq -\dfrac{1}{2}$

475. $\log_5(2x-4) < \log_5(x+3)$

476. $\log_{0,1}(x^2+x-2) > \log_{0,1}(x+3)$

477. $\log\sqrt{x^2-3x+4} - \log\sqrt{x+1} > 0$

478. $\log_{\frac{1}{2}}(x+1) \leq \log_2(2-x)$

479. $\log_{1/2}\frac{x^2+6x+9}{2(x+1)} < -\log_2(x+1)$

480. $\log(x-2)+\log(27-x) < 2$

481. $\log(x-1)+\log(x-2) < \log(x+2)$

482. $\log_2(2-x)+\log_{1/2}(x-1) > \log_{\sqrt{2}} 3$

483. $\log_{1/5}(2x+5)-\log_{1/5}(16-x^2) \leq 1$

484. $\log_2\left(1+\frac{1}{x}\right)+\log_{1/2}\left(1+\frac{x}{4}\right) \geq 1$

485. $\log_7 x-\log_7(2x-5) \leq \log_7 2-\log_7(x-3)$

486. $\log_{1/3}(x-1)+\log_{1/3}(x+1)+\log_{\sqrt{3}}(5-x) < 1$

487. $\log_2 x^2+\log_2(x-1)^2 > 2$

488. $\log^2 x+3\log x-4 \geq 0$

489. $\frac{1-\log_4 x}{1+\log_2 x} \leq \frac{1}{2}$

490. $\log_{1/3} x > \log_x 3-\frac{5}{2}$

491. $(\log_2 x)^4-\left(\log_{1/2}\frac{x^5}{4}\right)^2-20\log_2 x+148 < 0$

492. $(2\log_3^2 x-3\log_3 x-8)(2\log_3^2 x-3\log_3 x-6) \geq 3$

493. $(\log_2^2 x+3\log_2 x+1)(\log_2^2 x+3\log_2 x-3) < 5$

494. $(1{,}25)^{1-(\log_2 x)^2} < (0{,}64)^{2+\log_{\sqrt{2}} x}$

495. $2^{2x+1}-21.\left(\frac{1}{2}\right)^{2x+3}+2 \geq 0$

496. $0{,}1^{x+1} < 0{,}8+2.10^x$

497. $2^x + 2^{-x} < 3$

498. $3^{4-3x} - 35.3^{3x-2} + 6 \geq 0$

499. $\dfrac{6}{2^x - 1} < 2^x$

500. $3^{\log x + 2} < 3^{\log x^2 + 5} - 2$

501. $\left(\dfrac{1}{2}\right)^{\log x^2} + 2 > 3.2^{-\log(-x)}$

502. $\log_2(4^x - 5.2^x + 2) > 2$

503. $\log_{1/\sqrt{5}}(6^{x+1} - 36^x) \geq -2$

504. $\log_{\sqrt{2}}(5^x - 1) \log_{\sqrt{2}} \dfrac{2\sqrt{2}}{5^x - 1} > 2$

505. $\log(1 + 2^{x+1}) > \dfrac{(x \log 2) \log 4}{\log 8} + \log 3$

506. $\sqrt{\log_2 \dfrac{3 - 2x}{1 - x}} < 1$

507. $\sqrt{\log_3(9x - 3)} \leq \log_3\left(x - \dfrac{1}{3}\right)$

508. $\sqrt{9^x + 3^x - 2} \geq 9 - 3^x$

509. $\log_{1/3}(\log_4(x^2 - 5)) > 0$

510. $0,3^{\log_{\frac{1}{3}} \log_2 \frac{3x+6}{x^2+2}} > 1$

511. $\log_{4/3}\left(\sqrt{x + 3} - x\right) > 0$

512. $\log_{1/2}\left(\sqrt{5-x}-x+1\right)>-3$

513. $x^{\log_2 x-2}>\dfrac{x}{4}$

514. $x^{(\log x)^2-3\log x+1}>1000$

515. $\sqrt{x^{\log_2\sqrt{x}}}\geq 2$

516. $\log_a(x-1)+\log_a x>2$

517. $\dfrac{1}{5-\log_a x}+\dfrac{2}{1+\log_a x}<1, 0<a<1$

518. $\dfrac{3\log_a x+6}{\log_a^2 x+2}>1$

519. $\log_a(1-8a^{-x})\geq 2(1-x)$

520. $\log_{\mathrm{x}-3}(x-1)<2$

521. $\log_x(x+2)>2$

522. $\log_{2x}(x^2-5x+6)<1$

523. $\log_{x+3}(x^2-x)<1$

524. $\log_{3x+5}(9x^2+8x+2)>2$

525. $\log_{2x+4}(x^2+1)\leq 1$

526. $\log_x\dfrac{15}{1-2x}<-2$

527. $\log_{x^2}(3-2x)>1$

528. $\log_{x^2+3x}(x+3)<1$

529. $\log_{\frac{2}{3}|x-2|} 2^{1-x^2} \geq 0$

530. $\log_{\log_2\left(\frac{1}{2}x\right)}(x^2-10x+22)>0$

531. $|x|^{x^2-x-2}<1$

532. $\left|\log_2 \frac{x}{6}\right|^{x^2-18x+56}>1$

533. $\dfrac{\log_5(x^2+3)}{4x^2-16x}<0$

534. $-\dfrac{\log_{0,3}(x-1)}{\sqrt{2x-x^2+8}} \geq 0$

535. $\dfrac{\log_{0,5} x+2}{\sqrt{2x-1}}>0$

536. $\dfrac{3x^2-2x-1}{\log_3(x-1)}<0$

537. $25.2^x-10^x+5^x>25$

538. $\log_5 x+\log_x \dfrac{x}{3}>\dfrac{(\log_5 x)(2-\log_3 x)}{\log_3 x}$

539. $\dfrac{1}{\log_4 \dfrac{x+1}{x+2}} \leq \dfrac{1}{\log_4(x+3)}$

VII. ប្រព័ន្ធវិសមីការ

ដោះស្រាយប្រព័ន្ធវិសមីការ

540. $\begin{cases} \dfrac{\sqrt{(x-8)(2-x)}}{\log_{0,3}\left(\dfrac{10}{7}(\log_2 5 - 1)\right)} \geq 0 \\ 2^{x-3} - 31 > 0 \end{cases}$

541. $\begin{cases} \dfrac{\sqrt{\log_2^2 x - 3\log_2 x + 2}}{\log_5\left(\dfrac{1}{3}(\log_3 5 - 1)\right)} \geq 0 \\ x - \sqrt{x} - 2 \geq 0 \end{cases}$

542. $\begin{cases} \left(\dfrac{1}{81}\right)^{8+\log_a x} > \left(\dfrac{1}{3}\right)^{\log_a^2 x} \\ 0 < x < 1 \end{cases}$

៣. ត្រីកោណមាត្រ

I. គណនា

543. ដោយដឹងថា $\sin\alpha+\cos\alpha=a$ គណនា ក) $|\sin\alpha-\cos\alpha|$; ខ) $\sin^4\alpha+\cos^4\alpha$

544. ដោយដឹងថា $\tan\alpha+\cot\alpha=p$ គណនា ក) $\tan^2\alpha+\cot^2\alpha$; ខ) $\tan^3\alpha+\cot^3\alpha$

545. គណនា $\sin\left(\frac{\pi}{3}-\alpha\right)$ បើ $\tan\alpha=-\frac{3}{4},\frac{3\pi}{2}<\alpha<2\pi$ ។

546. គណនា $\cos(70°+\alpha)$ បើ $\sin(40°+\alpha)=b,0<\alpha<45°$ ។

547. គណនា $\sin(\alpha+\beta-\gamma)$ បើ $\sin\alpha=\frac{12}{13},\cos\beta=\frac{8}{17};\sin\gamma=\frac{4}{5};\ 0<\alpha,\beta,\gamma<\frac{\pi}{2}$ ។

548. គណនា $\sin 3\alpha,\cos 3\alpha,\tan 3\alpha$ បើ $\cot\alpha=4/3,\pi<\alpha<\frac{3}{2}\pi$ ។

គណនា

549. $$\frac{\sin\alpha+\sin 3\alpha}{\cos\alpha+\cos 3\alpha}$$

550. $$\frac{\cos 4\alpha-\cos 2\alpha}{\sin 2\alpha+\sin 4\alpha}$$

551. $$\frac{\sin\alpha-3\sin 2\alpha+\sin 3\alpha}{\cos\alpha-3\cos 2\alpha+\cos 3\alpha}$$

552. $$\frac{2(\sin 2\alpha+2\cos^2\alpha-1)}{\cos\alpha-\sin\alpha-\cos 3\alpha+\sin 3\alpha}$$

553. $$\cos\frac{2\pi}{7}+\cos\frac{4\pi}{7}+\cos\frac{6\pi}{7}$$

554. $$\cos 0+\cos\frac{\pi}{7}+\cos\frac{2\pi}{7}+\cdots+\cos\frac{6\pi}{7}$$

555. អោយ $\sin\alpha+\cos\alpha=1{,}4,0<\alpha<\frac{\pi}{4}$ ។ គណនា $\tan\frac{\alpha}{2}$ ។

556. មុំស្រួចវិជ្ជមាន α,β,γ ផ្ទៀងផ្ទាត់ទំនាក់ទំនង

$$\tan\frac{\beta}{2}=\frac{1}{3}\cot\frac{\alpha}{2},\cot\frac{\gamma}{2}=\frac{1}{2}\left(3\tan\frac{\alpha}{2}+\cot\frac{\alpha}{2}\right)$$

គណនា $\alpha+\beta+\gamma$ ។

គណនាដោយមិនប្រើតារាង

557. $\cos 292°30'$

558. $\operatorname{cosec} 10° - \sqrt{3}\sec 10°$

559. $\dfrac{2\cos 40° - \cos 20°}{\sin 20°}$

560. $-2\sqrt{2}\sin 10°\left(2\sin 35° - \dfrac{\sec 5°}{2} - \dfrac{\cos 40°}{\sin 5°}\right)$

561. $\cos^2 73° + \cos^2 47° + \cos 73° \cos 47°$

562. $\sin 6° - \sin 42° - \sin 66° + \sin 78°$

563. $\dfrac{\cos^2 33° - \cos^2 57°}{\sin 21° - \cos 21°}$

564. $6\cos 40° - 8\cos^3 40°$

565. $\tan^6 20° - 33\tan^4 20° + 27\tan^2 20° - 3$

566. $\cot^2 36° \cot^2 72°$

567. គណនា

$$A = \tan^6 \frac{\pi}{18} + \tan^6 \frac{5\pi}{18} + \tan^6 \frac{7\pi}{18}$$

568. គណនា

$$P = \left(1 - 4\cos^2 \frac{\pi}{1999}\right)\left(1 - 4\cos^2 \frac{2\pi}{1999}\right)\left(1 - 4\cos^2 \frac{3\pi}{1999}\right)\dots\left(1 - 4\cos^2 \frac{999\pi}{1999}\right)$$

II. សមភាព

បង្ហាញសមភាព

569. $\sin^6 \alpha + \cos^6 \alpha + 3\sin^2 \alpha \cos^2 \alpha = 1$

570. $\dfrac{\sin^2 \alpha - \tan^2 \alpha}{\cos^2 \alpha - \cot^2 \alpha} = \tan^6 \alpha$

571. អោយ α, β, γ ជាមុំនៃត្រីកោណ។ ចូរបង្ហាញថា $\sin \alpha \sin \beta - \cos \gamma = \cos \alpha \cos \beta$ ។

បង្ហាញសមភាព

572. $(\cos \alpha + \sin \alpha)^2 = 1 + \sin 2\alpha$

573. $1 - \sin \alpha = 2\sin^2\left(\dfrac{\pi}{4} - \dfrac{\alpha}{2}\right)$

574. $$\frac{1-2\sin^2\alpha}{2\cot\left(\frac{\pi}{4}+\alpha\right)\cos^2\left(\frac{\pi}{4}-\alpha\right)}=1$$

575. $$\frac{1-2\sin^2\beta}{1+\sin 2\beta}=\frac{1-\tan\beta}{1+\tan\beta}$$

576. $$\tan\left(\frac{\pi}{4}+\alpha\right)=\frac{1+\sin 2\alpha}{\cos 2\alpha}$$

577. $$\frac{\cos\alpha+\sin\alpha}{\cos\alpha-\sin\alpha}=\tan 2\alpha+\sec 2\alpha$$

578. $$\frac{\sin^4\alpha+2\sin\alpha\cos\alpha-\cos^4\alpha}{\tan 2\alpha-1}=\cos 2\alpha$$

579. $$\frac{\sin(\alpha-\beta)\sin(\alpha+\beta)}{1-\tan^2\alpha\cot^2\beta}=-\cos^2\alpha\sin^2\beta$$

580. $$3-4\cos 2\alpha+\cos 4\alpha=8\sin^4\alpha$$

581. $$\cos^4\alpha=\frac{1}{8}\cos 4\alpha+\frac{1}{2}\cos 2\alpha+\frac{3}{8}$$

582. $$\sin^4\alpha+\cos^4\alpha=\frac{1}{2}(1+\cos^2 2\alpha)$$

583. $$4(\sin^6\alpha+\cos^6\alpha)=1+3\cos^2 2\alpha$$

584. $$8\left(\sin^8\frac{\alpha}{2}+\cos^8\frac{\alpha}{2}\right)=1+6\cos^2\alpha+\cos^4\alpha$$

បង្ហាញសមភាព

585. $$\frac{2\sin\alpha+\sin 4\alpha}{2(\cos\alpha+\cos 3\alpha)}=\tan 2\alpha\cos\alpha$$

586. $$\cos^4\alpha-\sin^4\alpha+\sin 2\alpha=\sqrt{2}\cos\left(2\alpha-\frac{\pi}{4}\right)$$

587. $\cos^2\alpha+\cos^2\left(\frac{\pi}{3}+\alpha\right)+\cos^2\left(\frac{\pi}{3}-\alpha\right)=\frac{3}{2}$

588. $\sin^2\alpha+\cos\left(\frac{\pi}{3}-\alpha\right)\cos\left(\frac{\pi}{3}+\alpha\right)=\frac{1}{4}$

589. $\log_{1/3}[\cos^2(\alpha+\beta)+\cos^2(\alpha-\beta)-\cos 2\alpha\cos 2\beta]=0$

590. $\frac{\cot^2 2\alpha-1}{2\cot 2\alpha}-\cos 8\alpha\cot 4\alpha=\sin 8\alpha$

591. $16\sin 10°\sin 30°\sin 50°\sin 70°=1$

592. $\sin^2\alpha\cos^4\alpha=\frac{1}{16}+\frac{1}{32}\cos 2\alpha-\frac{1}{16}\cos 4\alpha-\frac{1}{32}\cos 6\alpha$

593. $\sin 9\alpha+3\sin 7\alpha+3\sin 5\alpha+\sin 3\alpha=8\sin 6\alpha\cos^3\alpha$

594. $\tan(\alpha-\beta)+\tan(\beta-\gamma)+\tan(\gamma-\alpha)=\tan(\alpha-\beta)\tan(\beta-\gamma)\tan(\gamma-\alpha)$

595. $\sqrt{1+\sin\alpha}-\sqrt{1-\sin\alpha}=2\sin\frac{\alpha}{2}; 0\leq\alpha\leq\frac{\pi}{2}$

596. ចូរបង្ហាញថា

$$\sqrt{2+\sqrt{2+\cdots+\sqrt{2}}}=2\cos\frac{p}{2^n+1}$$

(ក្នុងនោះមានឫស n ដង) ចំពោះ $n\in\mathbb{N}$ ។

597. គេអោយ ចំនួនគត់វិជ្ជមាន n ។ ចូរបង្ហាញថា មានពហុធា T_n មួយ ដែល $\cos nx=T_n(\cos x)$ ចំពោះគ្រប់ចំនួនពិត x ។ ពហុធា T_n នេះ គេហៅថា ពហុធា Tchebychev។

598. គេអោយចំនួនពិត x ផ្ទៀងផ្ទាត់

$$\left(3+2\sqrt{2}\right)^x=\left(\sqrt{2}-1\right)^x+3$$

ចូរបង្ហាញថា $\left(\sqrt{2}+1\right)^x=2\cos\frac{\pi}{9}$

599. ចូរបង្ហាញថា

$$\sin^2\frac{\pi}{7}+\sin^2\frac{2\pi}{7}+\sin^2\frac{3\pi}{7}=\frac{7}{4}$$

III. សមីការ

ដោះស្រាយសមីការ

600. $\cos(1{,}5\pi + x) = \sqrt{2}\sin(x+\pi)\cos x$

601. $2\sin x\cos x + \sqrt{3} - 2\cos x - \sqrt{3}\sin x = 0$

602. $\sin 2x = (\cos x - \sin x)^2$

603. $\tan^3 3x - 2\sin^3 3x = 0$

604. $2\tan x\cos x + 1 = 2\cos x + \tan x$

605. $\sin x + \cos^2 x = 1/4$

606. $3\cos x = 2\sin^2 x$

607. $6\cos^2 x + 13\sin x = 12$

608. $3\cos^2 x - 4\cos x - \sin^2 x - 2 = 0$

609. $\cos^4\dfrac{x}{5} + \sin^2\dfrac{x}{5} = 1$

610. $\sin x - \dfrac{|2\cos x - 1|}{2\cos x - 1}\sin^2 x = \sin^2 x$

611. $\tan^2 x - 4\tan x + 3 = 0$

612. $2\tan x - 2\cot x = 3$

613. $\dfrac{\sqrt{3}}{\cos^2 x} = 4\tan x$

614. $\dfrac{1}{\sin^2 x} = \cot x + 3$

615. $2\cos x\left(\cos x - \sqrt{8}\tan x\right) = 5$

616. $\left(\cos\dfrac{\pi}{4} - \sin\dfrac{\pi}{6}\right)(\sec x + \tan x) = \sin\dfrac{\pi}{4}\cos x$

617. $\log_2(3\sin x) - \log_2\cos x - \log_2(1-\tan x) - \log_2(1+\tan x) = 1$

618. $\sin^4 2x + \cos^4 2x = \sin 2x\cos 2x$

619. $\sin^4 x + \cos^4 x - 2\sin 2x + \dfrac{3}{4}\sin^2 2x = 0$

620. $\sin^4 x + \cos^4 x + \sin 2x + a = 0$

621. $\dfrac{1}{\sin^2 x\cos^2 x} + \dfrac{2}{\sin x\cos x} - 4 = 0$

622. $\tan 5x + 2\sin 10x = 5\sin 5x$

623. $\cos 2x - 3\sin x + 2 = 0$

624. $\cos(10x+12) + 4\sqrt{2}\sin(5x+6) = 4$

625. $6\sin^2 x + 2\sin^2 2x = 5$

626. $\cos^3 x + \cos^2 x - 4\cos^2\frac{x}{2} = 0$

627. $4\cos x\,(2 - 3\sin^2 x) = -(1 + \cos 2x)$

628. $\tan^3 x - 1 + \frac{1}{\cos^2 x} - 3\cot\left(\frac{\pi}{2} - x\right) = 3$

629. $8\cos^4 x - 8\cos^2 x - \cos x + 1 = 0$

630. $\sin x = 5\cos x$

631. $\sin x - \cos x = 0$

632. $\sin x + \cos x = 0$

633. $|\sin x| = \sin x + 2\cos x$

634. $\cos^2 x - 4\sin x\cos x = 0$

635. $\sin x + \sin 2x = \cos x + 2\cos^2 x$

636. $\sin 2x - \sin^2 x = 2\sin x - 4\cos x$

637. $\tan x + \sin(\pi + x) = 2\sin^2\frac{x}{2}$

638. $(1 + \sin 2x)(\cos x - \sin x) = \cos x + \sin x$

639. $3(\cos x - \sin x) = 1 + \cos 2x - \sin 2x$

640. $\sin^2 x + 3\sin x\cos x + 2\cos^2 x = 0$

641. $2\cos^2 x + 3\sin 2x - 8\sin^2 x = 0$

642. $3\sin^2 x + 5\cos^2 x - 2\cos 2x - 4\sin 2x = 0$

643. $2\sin^2 x - 5\sin x\cos x - 8\cos^2 x = -2$

644. $\frac{1}{\cos x} = 4\sin x + 6\cos x$

645. $\sin^3 x + 4\cos^3 x = 0$

646. $\sin^2 x\,(1 + \tan x) = 3\sin x\,(\cos x - \sin x) + 3$

647. $\sin^4 x + \sin^3 x\cos x + \sin^2 x\cos^2 x + \sin x\cos^3 x + \cos^4 x = 1$

648. $\frac{\sqrt{3}}{2}\cos x + \frac{1}{2}\sin x = \frac{\sqrt{3}}{2}$

649. $\sqrt{3}\sin x + \cos x = \sqrt{2}$

650. $\sin 5x = \sqrt{3}(1 + \cos 5x)$ **651.** $\cos x + \sin x = 1$

652. $\sin x + \cos x \cot\frac{x}{2} = -\sqrt{3}$ **653.** $\sin|x| \tan 5x = \cos x$

654. $\left(\sin 2x + \sqrt{3}\cos 2x\right)^2 - 5 = \cos\left(\frac{\pi}{6} - 2x\right)$

655. $\cos 6x + \tan^2 x + \cos 6x \tan^2 x = 1$

656. $\frac{\tan 2x + \tan x}{1 - \tan 2x \tan x} = -1$ **657.** $\frac{\tan 3x - \tan 2x}{1 + \tan 3x \tan 2x} = 1$

658. $2\tan 3x - 3\tan 2x = \tan^2 2x \tan 3x$

659. $\cot x + \cot 15° + \cot(x + 25°) = \cot 15° \cot x \cot(x + 25°)$

660. $\sin x + \tan\frac{x}{2} = 0$ **661.** $1 + \cos x + \tan\frac{x}{2} = 0$

662. $\tan 2x + \cot x = 4\sin 2x$ **663.** $15\cot\frac{x}{2} + 130\sin x = \frac{53}{3}\tan\frac{x}{2}$

664. $\frac{59}{4}\cos x + 6\sin x \tan\frac{x}{2} = 4\tan x \cot\frac{x}{2}$

665. $2\sin^2\left(x - \frac{\pi}{4}\right) = 2\sin^2 x - \tan x$

666. $\cos 3x = -2\cos x$ **667.** $\cos 9x - 2\cos 6x = 2$

668. $\cos 4x = \cos^2 3x$ **669.** $3\sin\frac{x}{3} = \sin x$

670. $\sin 6x + 2 = 2\cos 4x$ **671.** $\sin\frac{3}{2}x + 3\sin x = 3\sin\frac{x}{2}$

672. $\sin\left(\frac{\pi}{4} + \frac{3}{2}x\right) = 2\sin\left(\frac{3\pi}{4} + \frac{x}{2}\right)$

673. $3\cos x + 3\sin x + \sin 3x - \cos 3x = 0$

674. $a\cos x + b\sin x = c,\ a^2 + b^2 \neq 0$

675. $\sin x + \sin\left(x + \frac{\pi}{4}\right) = 0$ **676.** $\sin 4x - \sin 2x = 0$

677. $\sin^2 x - \cos^2 x = \cos\frac{x}{2}$

678. $\cos 2x - \cos 6x = 0$

679. $\cos(3x - 4\pi) = \sin(\pi - x)$

680. $\sin \pi x^2 = \sin \pi(x^2 + 2x)$

681. $\sin\left(x - \frac{\pi}{6}\right) - \sin\left(x + \frac{2\pi}{3}\right) = \cos\left(x + \frac{\pi}{4}\right)$

682. $1 + \sin 2x = (\sin 3x - \cos 3x)^2$

683. $\cos 5x + \cos 7x = \cos(\pi + 6x)$

684. $\cos x - \cos 3x = 2\sqrt{3}\sin^2 x$

685. $\sin x + \sin 3x + 4\cos^3 x = 0$

686. $\cos x - \cos 2x = \sin 3x$

687. $\sin x + 2\sin 2x = -\sin 3x$

688. $\frac{\sin x + \sin 2x}{\sin 3x} = -1$

689. $\sqrt{2}\sin 10x + \sin 2x = \cos 2x$

690. $\cot x \sin 2x - \cos 2x = 1$

691. $\tan 2x \cos 3x + \sin 3x + \sqrt{2}\sin 5x = 0$

692. $2\sin\left(x + \frac{\pi}{3}\right) + 2\cos\left(\frac{x}{2} + \frac{\pi}{4}\right) = 3\sin\left(\frac{x}{4} + \frac{\pi}{8}\right) + \sqrt{3}\cos\left(\frac{x}{4} + \frac{\pi}{8}\right)$

693. $\sin x + \sin 2x + \sin 3x + \sin 4x = 0$

694. $\cos 9x - \cos 7x + \cos 3x - \cos x = 0$

695. $\cos 5x - \sin 5x = \sin 7x - \cos 7x$

696. $\sin 7x + \cos^2 2x = \sin^2 2x + \sin x$

697. $\cos 2x - \sin 3x - \cos 8x = \sin 10x - \cos 5x$

698. $\sin x + \sin 2x + \sin 3x = 1 + \cos x + \cos 2x$

699. $5\sin x + 6\sin 2x + 5\sin 3x + \sin 4x = 0$

700. $\operatorname{cosec} x - \operatorname{cosec} 2x = \operatorname{cosec} 4x$

701. $\tan 3x - \tan x = 0$

702. $\tan x + \tan 2x - \tan 3x = 0$

703. $\cos 3x \cos 6x$
$= \cos 4x \cos 7x$

704. $\sin 2x \sin 6x = \cos x \cos 3x$

705. $\cos 3x \sin 7x$
$= \cos 2x \sin 8x$

706. $\sin 5x \cos 3x = \sin 6x \sin 2x$

707. $\sin\left(\pi x + \frac{\pi}{4}\right)\sin\left(\pi x - \frac{\pi}{12}\right) = \frac{1}{2}$

708. $\sin^2 x + \sin^2 2x = \sin^2 3x$

709. $\cos^2 x + \cos^2 2x \cos^2 3x + \cos^2 4x = 2$

710. $\sin 7x + \sin 9x = 2\left[\cos^2\left(\frac{\pi}{4} - x\right) - \cos^2\left(\frac{\pi}{4} + 2x\right)\right]$

711. $\sin^2 2x + \sin^2 x = \frac{9}{16}$

712. $\sin x + \sin 2x + \sin 3x = \frac{1}{2}\cot\frac{x}{2}$

713. $\cos x + \cos 2x + \cos 3x = -0{,}5$

714. $\sin^3 x \cos 3x + \cos^3 x \sin 3x + 0{,}375 = 0$

715. $\cos^3 x \cos 3x + \sin^3 x \sin 3x = \frac{\sqrt{2}}{4}$

716. $\sin x \sin\left(\frac{\pi}{3} - x\right)\sin\left(\frac{\pi}{3} + x\right) = \frac{1}{8}$

717. $8\cos x \cos\left(\frac{\pi}{3} - x\right)\cos\left(\frac{\pi}{3} + x\right) + 1 = 0$

718. $\tan x \tan\left(x + \frac{\pi}{3}\right)\tan\left(x + \frac{2\pi}{3}\right) = \sqrt{3}$

719. $\sin 3x = 4\sin x \cos 2x$

720. $\sin 3x \cos x = 1{,}5\tan x$

721. $\tan x \cot 3x = 4$

722. $6\tan x + \frac{5}{\tan 3x} = \tan 2x$

723. $\sin x \cos x \sin 3x - \cos 3x \sin^2 x = 6\cot x$

724. $2\sin 3x\sin x+\left(3\sqrt{2}-1\right)\cos 2x=3$

725. $2\cos 4x+5\cos 2x-1=2\sin^2 x$

726. $2+\cos 4x=5\cos 2x+8\sin^6 x$

727. $\tan^2 x+\cos 4x=0$

728. $\tan x+\cot x-\cos 4x=3$

729. $\sin 2x-12(\sin x-\cos x)+12=0$

730. $\dfrac{1}{\sin x}+\dfrac{1}{\sin\left(x-\dfrac{3\pi}{2}\right)}=4\sin\left(x+\dfrac{5\pi}{4}\right)$

731. $1+\tan x=2\sqrt{2}\sin x$

732. $\sin\left(x+\dfrac{\pi}{4}\right)=\dfrac{1}{\sqrt{2}}(1-\sin x\cos x)$

733. $\sin x+\sin^2 x+\cos^3 x=0$

734. $\sin\dfrac{\sqrt{x}}{2}+\cos\dfrac{\sqrt{x}}{2}=\sqrt{2}\sin\sqrt{x}$

735. $\sin^2 x+2\tan^2 x+\dfrac{4}{\sqrt{3}}\tan x-\sin x+\dfrac{11}{12}=0$

736. $8\cos x+6\sin x-\cos 2x-7=0$

737. $\sin^4 x+\sin^4\left(\dfrac{x}{2}+\dfrac{\pi}{8}\right)+\cos^4 x=0{,}5\sin^2 2x$

738. $\left(\cos\dfrac{x}{4}-2\sin x\right)\sin x+\left(1+\sin\dfrac{x}{4}-2\cos x\right)\cos x=0$

739. $3\sin 3x=\cos 4x-\sin 9x-\cos 10x$

740. $\tan x + \frac{1}{9}\cot x = \sqrt{\frac{1}{\cos^2 x} - 1} - 1$

741. $\sin x + \sqrt{3}\cos x = \sqrt{2 + \cos 2x + \sqrt{3}\sin 2x}$

742. $\sqrt{2\cos 2x + 2} = \frac{3}{\sqrt{1 + 4\cos 2x}}$

743. $\sqrt{\sin x} + \sqrt[4]{2}\cos x = 0$

744. $\sin x + \sqrt{\cos x} = 0$

745. $2\cos x = \sqrt{2 + 2\sin 2x}$

746. $\sqrt{\cos^2 x - \cos^2 3x} = \sin 2x$

747. $\sin x + \sqrt{3}\cos x = \sqrt{0{,}5 + \cos\left(\frac{\pi}{6} - x\right)}$

748. $\sqrt{1 + 4\sin x\cos x} = \cos x - \sin x$

749. $\sqrt{\cos 2x - \sin 4x} = \sin x - \cos x$

750. $\sqrt{\frac{1 + \tan x}{1 - \tan x}} = \sin x + \cos x$

751. $4\sin 3x + 3 = \sqrt{2\sin 3x + 2}$

752. $\sqrt{13 - 18\tan x} = 6\tan x - 3$

753. $\sqrt{1 + 8\sin 2x\cos^2 2x} = 2\sin(3x + \pi/4)$

754. $2\sqrt{3\sin x} = \frac{3\tan x}{2\sqrt{\sin x} - 1} - \sqrt{3}$

755. $\sqrt{\sqrt{3}\cos x + \sin x - 2} + \sqrt{\cot 3x + \sin^2 x - \frac{1}{4}} = \sin\frac{3x}{2} + \frac{1}{\sqrt{2}}$

756. $\log_5 \tan x = (\log_5 4)\log_4(3\sin x)$

757. $\log_9 \sin 2x = \log_3 \sqrt{\dfrac{\sin x}{5}}$

758. $2^{\cos 2x} = 3.2^{\cos^2 x} - 4$

759. $\cot 2^x = \tan 2^x + 2\tan 2^{x+1}$

760. $x^{3\sin 2x+2} = \sqrt{x}$

761. តើសមីការ $1 + \cos 2x + \sin 2x = 0$ និងសមីការ

$$1 + \frac{1-\tan^2 x}{1+\tan^2 x} + \frac{2\tan x}{1+\tan^2 x} = 0$$

ដូចគ្នាដែររឺទេ?

762. ចូរកំនត់តំលៃ p ដើម្បីអោយសមីការ $\sqrt{p}\cos x - 2\sin x = \sqrt{2} + \sqrt{2-p}$ មានចំលើយ។

763. ចូរកំនត់តំលៃ a, b ដើម្បីអោយសមីការខាងក្រោមពិតចំពោះគ្រប់ x

$$a(\cos x - 1) + b^2 = \cos(ax + b^2) - 1$$

IV. ប្រព័ន្ធសមីការ

ដោះស្រាយប្រព័ន្ធសមីការ

764. $\begin{cases} x - y = 6{,}5\pi \\ 3\cos^2 x - 12\cos y = -4 \end{cases}$

765. $\begin{cases} x + y = \dfrac{2}{3}\pi \\ \dfrac{\sin x}{\sin y} = 2 \end{cases}$

766. $\begin{cases} x + y = \pi/4 \\ \cos x + \cos y = a \end{cases}$

767. $\begin{cases} \sin 3x \cos 2y = 2^a - \cos 3x \sin 2y \\ \cos(x - y) = 0{,}5 \end{cases}$

768. $\begin{cases} \sin x \sin y = \dfrac{\sqrt{3}}{4} \\ \cos x \cos y = \dfrac{\sqrt{3}}{4} \end{cases}$

769. $\begin{cases}\tan x+\tan y=2\\ \cos x\cos y=0{,}5\end{cases}$

770. $\begin{cases}\sin x\cos y=\dfrac{1}{4}\\ 3\tan x=\tan y\end{cases}$

771. $\begin{cases}\tan x-2\sin y=-2\\ 5\tan x+2\sin y=-4\end{cases}$

772. $\begin{cases}4\sin y-6\sqrt{2}\cos x=5+4\cos^2 y\\ \cos 2x=0\end{cases}$

773. $\begin{cases}\dfrac{1}{\sin x}-\cos y=\dfrac{a+3}{3}\\ \sin x\cos y=-\dfrac{a}{3}\end{cases}$

774. $\begin{cases}\dfrac{1}{\cos x}-\tan y=2a+2\\ \tan y+(a^2+2a)\cos x=0\end{cases}$

775. $\begin{cases}\sin^2(-2x)-\left(3-\sqrt{2}\right)\tan 5y=\left(3\sqrt{2}-1\right)/2\\ \left(3-\sqrt{2}\right)\sin(-2x)+\tan^2 5y=\left(3\sqrt{2}-1\right)/2\end{cases}$

776. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}\tan^2 x+\tan^2 y+\tan^2 z=m^2\\ \tan^3 x+\tan^3 y+\tan^3 z=m^3\end{cases}$$

V. វិសមភាព

777. ចូរបង្ហាញថា ចំពោះគ្រប់ $0\le x\le\frac{\pi}{2};\frac{\pi}{6}<\alpha<\frac{\pi}{3}$ គេមាន

$$\tan\left(\frac{\pi\sin x}{4\sin\alpha}\right)+\tan\left(\frac{\pi\cos x}{4\cos\alpha}\right)>1$$

778. គេអោយត្រីកោណមិនកែង ABC ។ ចូរបង្ហាញថា

$3\tan^2 A\tan^2 B\tan^2 C-5(\tan^2 A+\tan^2 B+\tan^2 C)\le 9+\tan^2 B\tan^2 C+\tan^2 C\tan^2 A$

779. ចូរបង្ហាញថា

$$\frac{1-\sin\frac{\pi}{14}}{2\sin\frac{\pi}{14}}>\sqrt{3\cos\frac{\pi}{7}}$$

780. គេអោយ $2n$ ចំនួនពិត $x_1;x_2;\dots;x_{2n}\in\left[\frac{\pi}{6},\frac{\pi}{2}\right]$ ចូរកំនត់តំលៃតូចបំផុតនៃ $n\in\mathbb{N}^*$ ដែល

$$Y=\left(\sum_{i=1}^{2n}\sin x_i\right)\left(\sum_{i=1}^{2n}\frac{1}{\sin x_i}\right)=1800$$

781. គណនាតំលៃធំបំផុតនៃ

$$T=\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}$$

ដែល A,B,C ជាមុំបីនៃត្រីកោណមួយ។

782. តាង n ជាចំនួនគត់ធម្មជាតិ និងចំនួនពិត x ដែល $0<(n+1)x<\pi/2$ ចូរបង្ហាញថា

$$(1-\cos^n x)(1+\cos^n x)<\tan nx\sin x$$

783. គេអោយ A,B,C ជាមុំក្នុងនៃត្រីកោណមួយ។ ចូរបង្ហាញថា

$$27\left(\tan\frac{A}{2}\tan^2\frac{B}{2}+\tan\frac{B}{2}\tan^2\frac{C}{2}+\tan\frac{C}{2}\tan^2\frac{A}{2}\right)<4\left(\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}\right)$$

784. តាង A,B,C ជាមុំនៃត្រីកោណ ABC ។ គណនាតំលៃធំបំផុតនៃ $\sin C$ បើ

$$\frac{\sin^2 A+\sin^2 B}{\sin^2 C}=m,\qquad m>\frac{1}{2}$$

785. គេអោយ អនុគមន៍ $f(x)$ ដែល $f(\tan 2x)=\tan^4 x+\cot^4 x$ ។ ចូរបង្ហាញថា $f(\sin x)+f(\cos x)\geq 196$ ។

786. គេអោយត្រីកោណ ABC មាន $A>B>C$ ។ គណនាតំលៃតូចបំផុតនៃ

$$y=\sqrt{\frac{x-\sin A}{x-\sin C}}+\sqrt{\frac{x-\sin B}{x-\sin C}}-1$$

VI. វិសមីការ

ដោះស្រាយវិសមីការ

787. $2\sin^2 x+\sqrt{3}\sin x-3>0$

788. $\cos 2x+5\cos x+3\geq 0$

789. $\tan^2 x+\left(2-\sqrt{3}\right)\tan x-2\sqrt{3}<0$

790. $\cot^2 x+\cot x\geq 0$

791. $2\left(\sqrt{2}-1\right)\sin x-2\cos 2x+2-\sqrt{2}<0$

792. $\cos\pi x+\sin\left(\pi x-\frac{\pi}{4}\right)>0$

793. $\cos^3 x \sin 3x + \cos 3x \sin^3 x < \dfrac{3}{8}$

794. $\cos x \cos 2x \cos 3x \leq 0$

795. $\sin^4 \dfrac{x}{3} + \cos^4 \dfrac{x}{3} > \dfrac{1}{2}$

796. $\sin^6 x + \cos^6 x > \dfrac{5}{8}$

797. $8\sin^6 x - \cos^6 x > 0$

798. $\tan x \tan 3x < -1$

799. $3 \sin 2x - 1 > \sin x + \cos x$

800. $\sin 2x > \sqrt{2} \sin^2 x + \left(2 - \sqrt{2}\right) \cos^2 x \, , 0 < x < 2\pi$

801. $|\sin x| > \cos^2 x$

802. $\sqrt{5 - 2\sin x} \geq 6 \sin x - 1$

803. $1 - \cos x < \tan x - \sin x$

804. $9^{1+\sin^2 \pi x} + 30.9^{\cos^2 \pi x} \leq 117$

VII. ប្រព័ន្ធវិសមីការ

805. ចូរកំនត់ m ដើម្បីអោយប្រព័ន្ធមានរឹសតែមួយគត់

$$\begin{cases} (4-6m)\sin^3 x + 3(2m-1)\sin x + 2(m-2)\sin^2 x \, . \cos x - (4m-3)\cos x = 0 \\ 0 \leq x \leq \pi/4 \end{cases}$$

៤. ពហុធា

I. គណនា

806. កំនត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P(u^2 - v^2) = P(u+v).P(u-v)$$

ចំពោះគ្រប់ $u, v \in \mathbb{R}$ ។

807. កំនត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P(x+1) = P(x) + 2x + 1$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

808. កំនត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P((x+1)^2) = P(x^2) + 2x + 1$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

809. (**កាណាដា ១៩៧០**)

គេអោយពហុធា

$$f(x) = x^n + a_1 x^{n-1} + a_2 x^{n-2} + \cdots + a_{n-1} x + a_n$$

ដែលមានមេគុណ $a_1, a_2, \dots, a_n$ ជាចំនួនគត់ ហើយដោយដឹងថាមានចំនួនគត់បួនផ្សេងគ្នា a, b, c និង d ដែល

$$f(a) = f(b) = f(c) = f(d) = 5$$

ចូរបង្ហាញថា គ្មានចំនួនគត់ k មួយដែល $f(k) = 8$ ។

810. គេអោយពហុធាដឺក្រេទី $n \geq 1$ មានមេគុណមិនអវិជ្ជមាន និង $x_1, x_2, \dots, x_n \in \mathbb{R}^{+*}$ ។

ចូរបង្ហាញថា

$$\left[P\left(\frac{x_2}{x_1}\right)\right]^2 + \left[P\left(\frac{x_3}{x_2}\right)\right]^2 + \cdots + \left[P\left(\frac{x_n}{x_{n-1}}\right)\right]^2 + \left[P\left(\frac{x_1}{x_n}\right)\right]^2 \geq n[P(1)]^2$$

៥. សមីការអនុគមន៍

I. គណនា

811. ចូរកំនត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$f(f(x)+1) = 1 - x$$
$$f\big(f(x)\big) = x$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

812. គេអោយអនុគមន៍ $f: \mathbb{N}^* \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

a) $f(1) = 2$

b) ចំពោះគ្រប់ $n > 1$

$$f(1) + f(2) + \cdots + f(n) = n^2 f(n)$$

ចូរកំនត់ $f(n)$ ។

813. គេអោយចំនួនគត់វិជ្ជមាន n ។ ចូរកំនត់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

$$f\big(xf(y)\big) = x^n f\big(f(y)\big)$$

ចំពោះគ្រប់ $x, y \in \mathbb{R}$ ។

814. គេអោយថេរចំនួនពិតបី a, b, c ដែលមិនសូន្យទាំងបីព្រមគ្នា។ ចូរកំនត់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែល

$$af(x^2 + yz) + bf(y^2 + zx) + cf(z^2 + xy) = 0$$

ចំពោះគ្រប់ $x, y, z \in \mathbb{R}$ ។

815. ចូរកំនត់លក្ខខណ្ឌលើចំនួនវិជ្ជមាន p, q ដើម្បីអោយគេអាចរកបាននូវអនុគមន៍ $f: \mathbb{R}^+ \to \mathbb{R}^+$ ដែល

$$f\big(xf(y)\big) = x^p y^q$$

ចំពោះគ្រប់ $x, y \in \mathbb{R}^+$ ។

816. ចូរកំនត់គ្រប់អនុគមន៍ $f: \mathbb{Z} \to \mathbb{Z}$ ដែល

$$f(m+19) \geq f(m) + 19$$
$$f(m+99) \leq f(m) + 99$$

ចំពោះគ្រប់ $m \in \mathbb{Z}$ ។

817. ចូរកំនត់អនុគមន៏ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

$$xf(x+y) + yf(y-x) = f^2(x) + f^2(y)$$

ចំពោះគ្រប់ $x, y \in \mathbb{R}$ ។

818. ចូរកំនត់អនុគមន៏ $f: \mathbb{Z} \to \mathbb{Z}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

1) $f(1) = 1$
2) $f(x+y)[f(x) - f(y)] = f(x-y)[f(x) + f(y)]$

ចំពោះគ្រប់ $x, y \in \mathbb{Z}$ ។

819. (**កាណាដា ១៩៦៩**)

តាង f ជាអនុគមន៏មួយដែលមានលក្ខណៈដូចតទៅនេះ

a) $f(n)$ មានន័យចំពោះគ្រប់ ចំនួនគត់វិជ្ជមាន n ;
b) $f(n)$ ជាចំនួនគត់;
c) $f(2) = 2$;
d) $f(mn) = f(m)f(n)$ ចំពោះគ្រប់ m និង n ;
e) $f(m) > f(n)$ ចំពោះគ្រប់ $m > n$ ។

ចូរបង្ហាញថា $f(n) = n$ ។

820. គេអោយ $f(x)$ ជាអនុគមន៏ដែលផ្ទៀងផ្ទាត់

$$0 < 2f^2(xy) \le f(x)f(y^3) + f(x^3)f(y), \quad \forall x, y \in \mathbb{R}$$
$$f(1999) > 0$$

ចូរបង្ហាញថា $f(2000) > 0$ ។

៣. អនុគមន៍ដ័យ

I. គណនា

1. $1/2$. ▲ យើងមាន

$:a^2+b^2+c^2=1 \Rightarrow a^2+b^2=1-c^2$

$:a+b+c=0 \Leftrightarrow a+b=-c \Rightarrow (a+b)^2=c^2 \Leftrightarrow a^2+b^2+2ab=c^2;$

$\Rightarrow 1-c^2+2ab=c^2 \Rightarrow ab=\frac{2c^2-1}{2}$

$:a^4+b^4+c^4=(a^2+b^2)^2+c^4-2(ab)^2=(1-c^2)^2+c^4-2\left(\frac{2c^2-1}{2}\right)^2=c^4-2c^2+1-2c^4+2c^2-\frac{1}{2}=\frac{1}{2}$ ។

2. $\frac{n(n+1)(n+2)}{6}$.

3. $\left(\frac{n(n+1)}{2}\right)^2$ ▲ យើងមាន

$$(1+1)^4=2^4=1^4+4.1^3.1+6.1^2.1^2+4.1.1^3+1^4$$
$$(2+1)^4=3^4=2^4+4.2^3.1+6.2^2.1^2+4.2.1^3+1^4$$
$$\dots$$
$$(n+1)^4=n^4+4.n^3.1+6.n^2.1^2+4.n.1^3+1^4$$

បូកសមភាពទាំងអស់នេះចូលគ្នា យើងទាញបានផលបូកដែលចង់បាន។

4. 4 ▲ គុណ S នឹង $(2-1)$ យើងទាញបាន

$$\begin{aligned} S &= (2-1)(2+1)(2^2+1)(2^4+1)\dots(2^{1024}+1)+1 \\ &= (2^2-1)(2^2+1)(2^4+1)\dots(2^{1024}+1)+1 \\ &= (2^4-1)(2^4+1)\dots(2^{1024}+1)+1 \\ &\vdots \\ &= (2^{1024}-1)(2^{1024}+1)+1 \\ &= 2^{2048}-1+1=2^{2048} \end{aligned}$$

ដូច្នេះ $S^{1/1024}=4$ ។

5. $(n+1)!-1$ ▲ យើងមាន $k.k!=(k+1)!-k!$ ចំពោះ $k=1,2,3\dots$ ។ ដូច្នេះ

$$1.1!+2.2!+3.3!+\dots+(n-1).(n-1)!+n.n!$$
$$=(2!-1!)+(3!-2!)+(4!-3!)+\dots+(n!-(n-1)!)+\big((n+1)!-n!\big)$$

$$= (n+1)! - 1$$

6. ▲ យើងមាន

$$S.2000! = \binom{2000}{1} + \binom{2000}{3} + \cdots + \binom{2000}{1997} + \binom{2000}{1999}$$
$$= \frac{1}{2}\sum_{i=1}^{2000}\binom{2000}{i} = \frac{1}{2}(1+1)^{2000} = 2^{1999}$$
$$S = \frac{2^{1999}}{2000!}$$

រំលឹក៖ រូបមន្តទ្វេធាញូវតុន

$$(a+b)^n = \sum_{i=1}^{n}\binom{n}{i}a^{n-i}b^i$$

7. 0 ▲ សន្មតថា u, v, s, t ជាឫសបួននៃពហុធា

$$f(x) = x^4 - ax^3 + bx^2 - cx + d$$

តាមទ្រឹស្តីបទវៀែត យើងទាញបាន

$$u+v+s+t = a; uv+vs+st+tu+us+vt = b; uvs+vst+stu = c, uvst = d$$

ដោយ $u+v+s+t=0$ នោះ $a=0$ ។ ដូច្នេះ $f(x) = x^4 + bx^2 - cx + d$ ។ តាង

$$S_n = u^n + v^n + s^n + t^n$$

យើងមាន

$S_1 = u+v+s+t = 0;$

$S_2 = u^2+v^2+s^2+t^2 = (u+v+s+t)^2 - 2(uv+vs+st+tu+us+vt) = -2b$

ដើម្បីគណនា S_3 យើងពិនិត្យករណី២ខាងក្រោម។

- ករណី u, v, s, t សុទ្ធតែខុសពីសូន្យទាំងអស់។ ដូច្នេះ

$$u^3 + bu - c + \frac{d}{u} = 0;\ \ v^3 + bv - c + \frac{d}{v} = 0$$
$$s^3 + bs - c + \frac{d}{s} = 0;\ t^3 + bt - c + \frac{d}{t} = 0$$
$$\Longrightarrow\ \ S_3 + bS_1 - 4c + d\left(\frac{1}{u}+\frac{1}{v}+\frac{1}{s}+\frac{1}{t}\right) = 0$$
$$\Longrightarrow\ \ S_3 - 4c + d\frac{c}{d} = 0$$
$$\Longrightarrow\ \ S_3 = 3c$$

- ករណីក្នុងចំនោម u, v, s, tមានមួយស្មើសូន្យ។ សន្មតថាជា u ។ ដូច្នេះ $d = 0$ ហើយ

$$f(x) = x^4 + bx^2 - cx = x(x^3 + bx - c)$$

ដូច្នេះ v, s, t ជាឫសនៃសមីការ $x^3 + bx - c = 0$ ។ ដូច្នេះ

$$v^3 + bv - c = 0; s^3 + bs - c = 0; t^3 + bt - c = 0$$

$$\Longrightarrow S_3 + b(u+v+s+t) - 3c = 0;$$
$$\Longrightarrow S_3 = 3c$$

ក្នុងករណីទាំងពីរ យើងមាន $S_3 = 3c$ ។

យើងមាន

$$u^4 + bu^2 - cu + d = 0; v^4 + bv^2 - cv + d = 0;$$
$$s^4 + bs^2 - cs + d = 0; t^4 + bt^2 - ct + d = 0$$
$$\Longrightarrow S_4 + bS_2 - cS_1 + d = 0$$
$$\Longrightarrow S_4 = 2b^2 - 4d$$

យើងមាន $x^4 + bx^2 - cx + d = 0$ ដោយគុណអង្គទាំងពីរនឹង x^n យើងទាញបាន

$$x^{n+4} + bx^{n+2} - cx^{n+1} + dx^n = 0$$
$$\Longrightarrow \quad S_{n+4} + bS_{n+2} - cS_{n+1} + dS_n = 0$$

យើងទាញបាន

$$S_5 = -bS_3 + cS_2 + dS_1 = -5bc$$
$$S_7 = -bS_5 + cS_4 - dS_3 = 7c(b^2 - d)$$

ដោយ $S_7 = 0$ នោះ $c = 0$ រឺ $b^2 = d$ ។

- ករណី $b^2 = d$ យើងទាញបាន
$$0 \le S_4 = 2b^2 - 4d = -2b^2 \le 0 \Longrightarrow b = 0 \Longrightarrow d = 0$$
$$\Longrightarrow S_4 = 0 \Longrightarrow u = v = s = t = 0 \Longrightarrow P = 0$$
- ករណី $c = 0$ នោះ u, v, s, t ជាឫសទាំងបួននៃសមីការ $x^4 + bx^2 + d = 0$ ដូច្នេះវាត្រូវតែ $t = -u$ រឺ $t = -v$ រឺ $t = -s$។ ដូច្នេះ $P = 0$ ។

II. សមភាព

8.▲ ចំពោះ $n = 1$ យើងទាញបាន $1^2 = \frac{1.2.3}{6}$ ពិត។ សន្មតថាពិតដល់ k មានន័យថា $1^2 + 2^2 + \cdots + k^2 = \frac{k(k+1)(2k+1)}{6}$។ យើងទាញបាន $1^2 + 2^2 + \cdots + k^2 + (k+1)^2 = \frac{k(k+1)(2k+1)}{6} + (k+1)^2 = \frac{(k+1)(k+1+1)(2(k+1)+1)}{6}$ ។ ដូច្នេះតាមវិចារដោយកំនើន យើងទាញបានសមមភាពពិតចំពោះគ្រប់ $n \in \mathbb{N}$ ។

9.● ស្រាយបញ្ជាក់តាមកំនើន។

10.● ស្រាយបញ្ជាក់តាមកំនើន។

11.● ស្រាយបញ្ជាក់តាមកំនើន។

12.▲ តាង $a = \tan x, b = \tan y, c = \tan z$ ដែល $x, y, z \neq \frac{k\pi}{4}$ ចំពោះគ្រប់ចំនួនគត់ k។ លក្ខខណ្ឌ $a + b + c = abc$ ក្លាយជា $\tan(x + y + z) = 0$ ។យើងមាន

$$\tan(2x+2y+2z)=\frac{2\tan(x+y+z)}{1-\tan^2(x+y+z)}=0$$

ដូច្នេះ

$$\tan 2x+\tan 2y+\tan 2z=\tan 2x\tan 2y\tan 2z$$
$$\Rightarrow \frac{2\tan x}{1-\tan^2 x}+\frac{2\tan y}{1-\tan^2 y}+\frac{2\tan z}{1-\tan^2 z}$$
$$=\frac{2\tan x}{1-\tan^2 x}\frac{2\tan y}{1-\tan^2 y}\frac{2\tan z}{1-\tan^2 z}$$

ដូច្នេះសមភាពពិត។

13.▲ តាង $k=a_1/b_1=a_2/b_2=a_3/b_3$ នោះ

$$p_1a_1^n+p_2a_2^n+p_3a_3^n=k^n(p_1b_1^n+p_2b_2^n+p_3b_3^n)$$
$$=\left(\frac{a_1}{b_1}\right)^n(p_1b_1^n+p_2b_2^n+p_3b_3^n)$$

នាំអោយសមភាពពិត។

III. សមីការ

14. $\{-2;-1;1\}$. **15.** $\{-3;2\}$. **16.** $\{3\}$. **17.** $\{1\}$. **18.** $\left\{-1;\ -\frac{1}{2};\frac{1}{3}\right\}$. **19.** $\left\{\frac{1}{2}\right\}$. **20.** $\left\{-\sqrt{2};-\frac{1}{\sqrt{2}};\frac{1}{\sqrt{2}};\sqrt{2}\right\}$. ● តាង $x^2=y$ ។ **21.** $\{-\sqrt{3};\sqrt{3}\}$. **22.**$\{-1;1\}$.

23. $\{2\}$. ▲ តាង $2x-3=y+c$ និង $2x-5=y-c$ ។យើងទាញបាន $c=1$។ ជំនួសចូលសមីការ យើងទាញបាន $(y+1)^4+(y-1)^4=2$ សមមូលនឹង $y^4+6y^2=0$។ យើងទាញបាន $y=0$ នាំអោយ $x=2$ ។

24. $\left\{-\frac{1}{2};1\right\}$. **25.**$\left\{-\frac{a(\sqrt{13}+1)}{2};\frac{a(\sqrt{13}-1)}{2}/a\in\mathbb{R}\right\}$. ● តាង$x^2+ax=y$ ។ **26.** $\left\{-\frac{\sqrt{21}+5}{6};\frac{\sqrt{21}-5}{6}\right\}$

27. $\{-\sqrt{2};4-\sqrt{18};\sqrt{2};4+\sqrt{18}\}$. ● តាង $x-\frac{2}{x}=y$។ សមីការសមមូលនឹង $y^2-8y=0$។

28. $\left\{-\frac{3}{2};-\frac{\sqrt{7}+1}{4};\frac{\sqrt{7}-1}{4};1\right\}$. ● ចែកអង្គទាំងពីរនឹង x^2 បន្ទាប់មកតាង $2x-\frac{3}{x}=y$។ **29.** $\{\frac{1}{2};2\}$

30. $\left\{-1;9;\frac{5-\sqrt{61}}{2};\frac{5+\sqrt{61}}{2}\right\}$. ● ចែកអង្គទាំងពីរនឹង x^2 បន្ទាប់មកតាង $x-\frac{9}{x}=y$ ។

31. $\left\{\frac{1-\sqrt{21}}{2};\frac{1+\sqrt{21}}{2}\right\}$. ● ដកអង្គទាំងពីរនឹង $\frac{10x^2}{x+5}$ យើងទាញបាន $\left(\frac{x^2}{x+5}\right)^2+10\frac{x^2}{x+5}-11=0$ ។

32. $\{-\sqrt{7}-1;\sqrt{7}-1\}$. ● បង្រួមសមីការជារាង $\left(\frac{x^2}{x-3}\right)^2-6\frac{x^2}{x-3}-16=0$ ។

33.$\{-\frac{\sqrt{2\sqrt{2}-1}+1}{\sqrt{2}};\frac{\sqrt{2\sqrt{2}-1}-1}{\sqrt{2}}\}$.● បង្រួមសមីការជា $(x^2+1)^2-2(x-1)^2=0$ ។

34. $\left\{\frac{\sqrt{2}}{\sqrt{2\sqrt{2}-1}+1};\frac{\sqrt{2}}{\sqrt{2\sqrt{2}-1}-1}\right\}$. ● តាង $x=1/y$ ។

35. $\{-9; 11\}$. ● ប្ដូក $4x^2 + 400x + 1$ ទៅអង្គទាំងពីរនៃសមីការ។

36. $\{-a; a - \sqrt{a^2+2}; a + \sqrt{a^2+2} | a \in \mathbb{R}\}$. ▲ យើងទាញរក a យើងទាញបាន $a = \frac{x^2-2}{2x}$ រឺ $a = -x$ ។ ទាញរក x យើងទាញបានចំលើយ។

37. $\{-1 - \sqrt{3+a}; -1 + \sqrt{3+a}\}$ ចំពោះ $a \in [-3; -1)$; $\{-1 - \sqrt{3+a}; -1 + \sqrt{3+a}; -1 - \sqrt{1+a}; -1 + \sqrt{1+a}\}$ ចំពោះ $a \in [-1; \infty)$; គ្មានរឺសចំពោះ $a \in (-\infty; -3)$.▲ ដោះស្រាយរក a ដោយសន្មតថា x ជាប៉ារ៉ាម៉ែត្រ : $a^2 - 2(x^2-1)a + x^4 - 6x^2 + 4x = 0$; យើងទាញបាន $a = x^2 + 2x - 2$ រឺ $a = x^2 - 2x$ ។

38. $\left\{\frac{-1-\sqrt{29}}{2}; \frac{5-\sqrt{17}}{2}; \frac{-1+\sqrt{29}}{2}; \frac{5+\sqrt{17}}{2}\right\}$.▲ យើងសរសេរអង្គខាងឆ្វេងនៃសមីការជា

$$(x^2 + ax + c)\,(x^2 + bx + d) = 0$$

ដូច្នេះ

$$x^4 + (a+b)x^3 + (ab+c+d)x^2 + (bc+ad)x + cd \equiv x^4 - 4x^3 - 10x^2 + 37x - 14$$

យើងទាញបាន

$$\begin{cases} a + b = -4 \\ ab + c + d = -10 \\ bc + ad = 37 \\ cd = -14 \end{cases}$$

ដោយដឹងថា a, b, c, d ជាចំនួនគត់ នោះ ពីសមីការចុងក្រោយគេ យើងទាញបាន $(c; d) = \{(-1; 14); (1; -14); (-2; 7); (2; -7)\}$ ។ យើងផ្ទៀងផ្ទាត់ឃើញថា $(c; d) = (2; -7)$ ផ្ទៀងផ្ទាត់។ យើងទាញបាន $a = -5; b = 1$។ ដូច្នេះសមីការសមមូលនឹង $x^2 - 5x + 2 = 0$ រឺ $x^2 + x - 7 = 0$ ។

39.▲ សន្មតថា $x_1 = p/q$ ដែល $p \in \mathbb{Z}, q \in \mathbb{N}$ និង p និង q ជាចំនួនបឋមនឹងគ្នា។ ដូច្នេះ $\frac{p^3}{q^3} + a\frac{p^2}{q^2} + b\frac{p}{q} + c = 0$ សមមូលនឹង $p(p^2 + apq + bq^2) = -cq^3$ ។ អង្គខាងស្ដាំនៃសមភាពនេះចែកដាច់នឹង q ។ អង្គខាងឆ្វេងចែកដាច់នឹង q នាំអោយនិងមានតែ $q \equiv 1$ តែប៉ុណ្ណោះ ព្រោះ $p^2 + apq + bq^2$ ចែកមិនដាច់នឹង q ។ ដូច្នេះសមភាពមានរាង $p(p^2 + ap + b) = -c$ យើងទាញបាន c ជាពហុគុណនៃ $p = x_1$។

40.● ប្រើស្រាយបញ្ជាក់ដូចសំនួរទី **39.**។

41.● ប្រើសមភាព $ax^3 + bx^2 + cx + d = a(x - x_1)(x - x_2)(x - x_3)$.

42. $-2p$.

43. $\left\{\sqrt[3]{\frac{\sqrt{13}+3}{2}}-\sqrt[3]{\frac{\sqrt{13}-3}{2}}\right\}$ ● តាង $x=y-1/y$ ។ សមីការទៅជា $y^3-\frac{1}{y^3}-3\left(y-\frac{1}{y}\right)+3\left(y-\frac{1}{y}\right)-3=0$ រឺ $y^3-\frac{1}{y^3}-3=0$ ។ តាង $y^3=t$ យើងទាញបាន $t^2-3t-1=0$ ។

44.$\{-5;-1;1;3\}$. **45.**$\{2;6\}$. **46.**$\{-1\}$.

47. គ្មានរឺសសនិទាន

48.$\{-\frac{1}{3};1/2\}$.

49.$\{6\}$. ▲ គុណអង្គទាំងពីរនៃសមីការនឹង $\sqrt{x+10}-\sqrt{x-2}\neq 0$ យើងទាញបាន

$$\begin{cases}\sqrt{x+10}+\sqrt{x-2}=6\\ \sqrt{x+10}-\sqrt{x-2}=2\end{cases}$$

បូកអង្គទាំងពីរចូលគ្នា យើងទាញបាន $x=6$ ។

50. សមីការគ្មានរឺស។ **51.**$\{-1\}$. **52.**$\{12\}$. **53.** $\left\{-\frac{1}{4}\left(\frac{1}{a}-a\right)^2;\frac{1}{4}\left(\frac{1}{a}-a\right)^2\right\}$ ចំពោះ $a\in(0;1]$ ហើយគ្មានរឺសចំពោះតំលៃ a ផ្សេងទៀត។ **54.**$\{-6;1\}$. **55.**$\{-1;3\}$. **56.** $\{3\}$. **57.** $\{2\}$ **58.** $\{5\}$.
59.$\{20\}$. **60.** $\{-4/3\}$. **61.** $\{-1;0\}$. **62.** $\{5\}$. **63.** $\{16\}$. **64.** $\{9\}$. **65.** $\{-3;6\}$. ● តាង $y=\sqrt{x^2-3x+7}$ ។ **66.** $\{-9/2;3\}$. **67.** $\{1\}$. ● តាង $y=\sqrt{x}\sqrt[4]{x^2+15}$ ។ **68.** $\{5/3\}$.
69. $\{5a/3\}$ ចំពោះ $a\neq 0$; $(-\infty;0)\cup(0;\infty)$ ចំពោះ $a=0$ ។ **70.** $\{1\}$. **71.** $\left\{3;9\frac{9-\sqrt{97}}{8}\right\}$.
72. $\left\{5\pm a\sqrt{8-\frac{a^2}{2}}\right\}$ ចំពោះ $a\in[2;2\sqrt{2}]$; គ្មានរឺសចំពោះតំលៃ a ផ្សេងពីនេះ។▲ តាង $u=\sqrt{7-x},v=\sqrt{x-3}$ ។ យើងមានប្រព័ន្ធសមីការ

$$\begin{cases}u+v=a\\ 7-x+x-3=u^2+v^2=4,(u\geq 0,v\geq 0)\end{cases}$$

ដោះស្រាយប្រព័ន្ធសមីការនេះ យើងទាញបាន

$$\begin{cases}u_1=\dfrac{a+\sqrt{8-a^2}}{2}\\ v_1=\dfrac{a-\sqrt{8-a^2}}{2}\end{cases}\qquad\begin{cases}u_2=\dfrac{a-\sqrt{8-a^2}}{2}\\ v_2=\dfrac{a+\sqrt{8-a^2}}{2}\end{cases}$$

73. $\{3\}$.▲ តាង $\sqrt[4]{x-2}=u\geq 0,\sqrt[4]{4-x}=v\geq 0$ យើងទាញបានប្រព័ន្ធ

$$\begin{cases}u+v=2\\ u^4+v^4=2\end{cases}$$

លើកសមីការទីមួយជាស្វ័យគុណ៤ និងប្រើសមីការទី២ យើងទាញបាន $uv(2(u+v)^2-uv)=7$ ហើយដោយ $u+v=2$ យើងទាញបាន $(uv)^2-8(uv)+7=0$។ ដូច្នេះ $(uv)_1=1; (uv)_2=7$។ ដូច្នេះយើងទាញបានប្រព័ន្ធសមីការ

$$\begin{cases} u+v=2 \\ uv=1 \end{cases} \qquad \begin{cases} u+v=2 \\ uv=7 \end{cases}$$

ប្រព័ន្ធសមីការទីមួយមានរឹស $u=v=1$ ។ ត្រូវនឹង$x=3$ ។ ប្រព័ន្ធទី២គ្មានរឹស។

74. $\left\{\frac{2a+1}{a-2}\right\}$ ចំពោះ$a\in(-\infty;3]\cup(2;\infty)$; $\emptyset$ចំពោះ$a\in\left(\frac{1}{3};2\right]$.

75. $\{a+1+\sqrt{2a}; a+1-\sqrt{2a}\}$ ចំពោះ $a\in[0;1/2]$, $\{a+1+\sqrt{2a}\}$ ចំពោះ $a\in\left(\frac{1}{2};\infty\right)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

76. $(-\infty;0)$ ចំពោះ $a=0$, $\{0;3a/4\}$ ចំពោះ $a\in(0;\infty)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

77. $\{a^2+a; a^2-a+1\}$ ចំពោះ $a\in[0;1]$, $\{a^2+a\}$ ចំពោះ $a\in(1;\infty)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

78. $\{0\}$ ចំពោះ $a=1$, $\emptyset$ ចំពោះ $a\neq 1$. **79.**$\{(1;-5)\}$. **80.** $\{(1;-3)\}$. **81.** $\{(-3;1)\}$ចំពោះ $a\in\{-2\}$; $\emptyset$ ចំពោះ $a\notin\{-2\}$.

82.▲ តាង $f(x)=4x(1-x)=1-(2x-1)^2$ ។ យើងឃើញថា បើ $0\le f(x)\le 1$ នោះ $0\le x\le 1$។ ដូច្នេះ បើ $a_{1998}=0$ នោះ ត្រូវតែ $0\le t\le 1$។ អីលូវ យើងយក $0\le\theta\le\frac{\pi}{2}$ ដែល $\sin\theta=\sqrt{t}$ ។ យើងសង្កេតឃើញថា ចំពោះគ្រប់ $\phi\in\mathbb{R}$ យើងមាន

$$f(\sin^2\phi)=4\sin^2\phi\,(1-\sin^2\phi)=4\sin^2\phi\cos^2\phi=\sin^2 2\phi$$

ដោយ $a_1=\sin^2\theta$ នោះ យើងទាញបាន

$$a_2=\sin^2 2\theta, a_3=\sin^2 4\theta, \cdots, a_{1998}=\sin^2 2^{1997}\theta$$

ដូច្នេះ $a_{1998}=0$ ទាល់តែនិងនាំអោយ $\sin 2^{1997}\theta=0$ ។ មានន័យថា $\theta=\frac{k\pi}{2^{1997}}$ ចំពោះចំនួនគត់ k ខ្លះ ហើយ តំលៃរបស់ t ដែល $a_{1998}=0$ ស្មើនឹង $\sin^2(k\pi/2^{1997})$ ដែល $k\in\mathbb{Z}$ ។ ដូច្នេះយើងមានតំលៃរបស់ t បែបនេះ ចំនួន $2^{1996}+1$ គឺមានតំលៃ $\sin^2(k\pi/2^{1997})$ ចំពោះ $k=0,1,2,\cdots,2^{1996}$ ។

83. ▲ ដោយ $a^2-2b^2=1$ នោះ $a\neq 0$ ។ ដោយ $2b^2-3c^2=1$ នោះ $b\neq 0$ ។ បើ $c=0$ នោះ $b=\frac{1}{\sqrt{2}}$ និង $a=\sqrt{2}$ ។ $(a,b,c)=(\sqrt{2},1/\sqrt{2},0)$ ជាចំលើយមួយរបស់ប្រព័ន្ធសមីការ។ យើងនឹងបង្ហាញថា គ្មានចំលើយណាផ្សេងទៀតទេ។

យើងសន្មតថា មានចំនួនពិត (a,b,c) ដោយ $abc\neq 0$ ផ្ទៀងផ្ទាត់សមីការ។ យើងឃើញថា បើ (a,b,c) ជាចំលើយ នោះ $(-a,-b,-c)$ ក៏ជាចំលើយដែរ។ ដូច្នេះត្រូវតែមានចំនួនវិជ្ជមានពីរក្នុង

ចំនោម(a,b,c) រឺ $(-a,-b,c)$។ សន្មតថា a,b វិជ្ជមាន។ តាង $a=\cot A\,, b=\cot B$ និង $c=\cot C$ ដែល $0<A,B<\frac{\pi}{2}, 0<C<\pi$ ។ ដោយ $ab+bc+ca=1$ នោះ

$$\cot A\cot B+\cot B\cot C+\cot C\cot A=1$$
$$\cot C=\frac{1-\cot A\cot B}{\cot A+\cot B}=-\cot(A+B)=\cot(\pi-A-B)$$
$$A+B+C=\pi$$

ដូច្នេះ A,B,C ជាមុំក្នុងត្រីកោណ។ យើងមាន

$$a^2+1=2(b^2+1)=3(c^2+1)$$

$$\Rightarrow\ \frac{1}{\sin^2 A}=\frac{2}{\sin^2 B}=\frac{3}{\sin^2 C}$$

$$\Rightarrow\ \frac{1}{\sin A}=\frac{\sqrt{2}}{\sin B}=\frac{\sqrt{3}}{\sin C}$$

តាមច្បាប់ស៊ីនុស យើងទាញបានថា ជ្រុងឈមនឹងមុំ A,B,C មានរង្វាស់ $k,k\sqrt{2},k\sqrt{3}$ រៀងគ្នា ចំពោះចំនួនពិតវិជ្ជមាន k ខ្លះ។ ដូច្នេះត្រីកោណ ABC កែងត្រង់ C នាំអោយ $c=\cot C=0$ ផ្ទុយពីសន្មតដែល $c\neq 0$ ។ ដូច្នេះការសន្មតរបស់យើងខុស ហើយ $(a,b,c)=\left(\sqrt{2},1/\sqrt{2},0\right)$ ជាចំលើយតែមួយគត់របស់ប្រព័ន្ធ។

84.$\left\{\frac{4-p}{2\sqrt{4-2p}}\right\}$ ចំពោះ $\frac{4}{3}\leq p\leq 2$. ▲ យើងមាន $x\geq 0$។ លើកអង្គទាំងពីរជាការេយើងទាញបាន

$$5x^2-p-4+4\sqrt{(x^2-1)(x^2-p)}=x^2$$
$$\Leftrightarrow 4\sqrt{(x^2-1)(x^2-p)}=(p+4)-4x^2$$

បើ $4x^2\leq p+4$ យើងលើកអង្គទាំងពីរនៃសមីការជាការេម្តងទៀត យើងទាញបាន

$$-16(p+1)x^2+16p=-8(p+4)x^2+(p+4)^2$$
$$\Leftrightarrow x^2=\frac{(4-p)^2}{4(4-2p)}$$

មានន័យថា $x=\frac{4-p}{2\sqrt{4-2p}}$។ ដើម្បីអោយតំលៃនេះជាចំលើយនៃសមីការទាល់តែ $p\leq 2$ និង $\frac{(4-p)^2}{4-2p}=4x^2\leq p+4$ សមមូលនឹង $\frac{4}{3}\leq p\leq 2$ ។ ក្រៅពីនេះសមីការគ្មានចំលើយ។

85.▲ យើងសរសេរសមីការដែលអោយជារាង

$$x^5-x^3-4x^2-3x-2+\lambda(5x^4+\alpha x^2-8x+\alpha)=0$$

រឺសរបស់សមីការនេះមិនអាស្រ័យនឹង λ នាំអោយនិងបើ វាជារឺសរួមរបស់សមីការ

$$x^5-x^3-4x^2-3x-2=0 \text{ និង } 5x^4+\alpha x^2-8x+\alpha=0$$

សមីការទីមួយសមមូលនឹង $(x-2)(x^2+x+1)^2=0$ ហើយមានរឺសផ្សេងគ្នាចំនួនបី $x_1=2;\ x_{2,3}=\frac{-1\pm i\sqrt{3}}{2}$ ។

ក) ចំពោះ $\alpha=-\frac{64}{5}$ យើងមាន $x_1=2$ ជារឺសតែមួយគត់ ដែលមិនអាស្រ័យនឹង λ ។

ខ) ចំពោះ $\alpha = -3$ យើងមានរឹសចំនួនពីរដែលមិនអាស្រ័យនឹង λ គឺ $x_1 = \omega$ និង $x_2 = \omega^2$ ។

86.▲ លក្ខខណ្ឌ $2x-1 \geq 0, \Rightarrow x \geq \frac{1}{2}$ និង $x \geq \sqrt{2x-1} \Rightarrow (x-1)^2 \geq 0$ ពិតជានិច្ច។ យើងមាន $\sqrt{x+\sqrt{2x-1}} + \sqrt{x-\sqrt{2x-1}} = c \Leftrightarrow c^2 = 2x + 2|x-1| = \begin{cases} 2, & 1/2 \leq x \leq 1 \\ 4x-2, & x \geq 1 \end{cases}$

ក) $c^2 = 2$។ សមីការមានរឹស $\frac{1}{2} \leq x \leq 1$ ។

ខ) $c^2 = 1$។ សមីការគ្មានរឹស។

គ) $c^2 = 4$។ សមីការទៅជា $4x-2=4, \Rightarrow x = 3/2$ ។

87. $\{[5;10]\}$ ▲ យើងមាន

$$x+3-4\sqrt{x-1} = x-1-4\sqrt{x-1}+4 = \left(\sqrt{x-1}\right)^2 - 4\sqrt{x-1}+4 = \left(\sqrt{x-1}-2\right)^2$$
$$x+8-6\sqrt{x-1} = x-1-6\sqrt{x-1}+9 = \left(\sqrt{x-1}-3\right)^2$$

ដូច្នេះសមីការទៅជា

$$\sqrt{\left(\sqrt{x-1}-2\right)^2} + \sqrt{\left(\sqrt{x-1}-3\right)^2} = 1$$
$$\Rightarrow \quad \left|\sqrt{x-1}-2\right| + \left|\sqrt{x-1}-3\right| = 1$$

បើ $\sqrt{x-1} \geq 3$ នោះ

$$\sqrt{x-1}-2+\sqrt{x-1}-3 = 1$$
$$\Rightarrow x = 10$$

បើ $\sqrt{x-1}-2 \geq 0$ និង $\sqrt{x-1}-3 \leq 0 \Rightarrow 5 \leq x \leq 10$នោះ

$$\sqrt{x-1}-2-\sqrt{x-1}+3 = 1$$
$$\Rightarrow 1 = 1$$

បើ $\sqrt{x-1}-2 \leq 0 \Rightarrow x \leq 5$ នោះ

$$-\sqrt{x-1}+2-\sqrt{x-1}+3 = 1 \;\Rightarrow x = 5$$

88.$\{0;3\}$▲ តាង

$$3x = x+2x = y_1^2$$
$$x+2y_1 = y_2^2$$
$$x+2y_2 = y_3^2$$
$$\dots\dots\dots\dots\dots$$
$$x+2y_{n-2} = y_{n-1}^2$$
$$x+2y_{n-1} = y_n^2$$

ដែល $y_1, y_2, \dots, y_n$ ជាចំនួនពិតវិជ្ជមាន។ សមីការដែលអោយមានរាង

$$y_n = x$$

យើងនឹងបង្ហាញថា $y_1 = x$ ។ សន្មតថា $x > y_1$ ។ ដូច្នេះ $y_1 > y_2 > \cdots > y_n$ ។ មានន័យថា បើ $x > y_1$ នោះ $x > y_n$ ផ្ទុយពីសមីការ $x = y_n$ ។ ដូចគ្នាចំពោះករណី $x < y_1$ ។ ដូច្នេះ $x = y_1$ ។ ដោយ $y_1^2 = 3x$ នោះ $3x = x^2$ យើងទាញបាន $x = 0; x = 3$ ។

89. ▲ សមីការសមមូលនឹង

$$\left|\sqrt{x-4}-1\right| + \left|\sqrt{x-4}-2\right| = a$$

តាង $y = \sqrt{x-4} \geq 0$ ។ សមីការទៅជា $|y-1| + |y-2| = a$ ។ បើ $a = 0$ នោះ $y = 1$ និង $y = 2$ មិនអាច។ ដូច្នេះ $a > 0$ ។

បើ $0 \leq y < 1$ នោះ $1 - y + 2 - y = a; \Rightarrow y = \frac{3-a}{2}$ ។ ដោយ $0 \leq y = \frac{3-a}{2} < 1$ នោះ $1 < a \leq 3$ ។ យើងទាញបាន $x = 4 + \left(\frac{3-a}{2}\right)^2$ ។

បើ $1 \leq y \leq 2$ នោះ $y - 1 - y + 2 = a; \Rightarrow a = 1$ ។ $1 \leq y \leq 2$ ត្រូវនឹង $5 \leq x \leq 8$ ។

បើ $y > 2$ នោះ $y - 1 + y - 2 = a; \Rightarrow y = \frac{a+3}{2}$ ។ $y > 2 \Rightarrow a > 1$ ។ យើងទាញបាន $x = 4 + \left(\frac{a+3}{2}\right)^2$

ជាសរុប

បើ $a < 1$ សមីការគ្មានរឺស។

បើ $a = 1$ សមីការមានរឺស $5 \leq x \leq 8$ ។

បើ $1 < a \leq 3$ សមីការមានរឺស $x = 4 + \left(\frac{3-a}{2}\right)^2$ រឺ $x = 4 + \left(\frac{a+3}{2}\right)^2$ ។

បើ $a > 3$ សមីការមានរឺស $x = 4 + \left(\frac{a+3}{2}\right)^2$ ។

90. ▲ តាង $u = a - x; v = x - b$ ។ ដូច្នេះ $u^5 + v^5 = (a-b)^5; u + v = a - b$ ។ យើងមាន

$$\begin{aligned}
&u^5 + v^5 = (u+v)\{[(u+v)^2 - 2uv]^2 - uv(u+v)^2 + u^2v^2\} \\
&\Leftrightarrow (a-b)^5 = (a-b)\{[(a-b)^2 - 2uv]^2 - uv(a-b)^2 + u^2v^2\} \\
&\Leftrightarrow (a-b)^4 = (a-b)^4 + 5u^2v^2 - 5uv(a-b)^2 \\
&\Leftrightarrow 5(uv)^2 - 5uv(a-b)^2 = 0
\end{aligned}$$

ដូច្នេះ $uv = 0$ រឺ $uv = a - b$ ។

ករណី $uv = 0$ នោះ $u = 0$ រឺ $v = 0$ ។ បើ $u = 0$ នោះ $x = a$ ។បើ $v = 0$ នោះ $x = b$ ។

ករណី $uv = a - b$ នោះ យើងមាន

$$\begin{cases} u + v = a - b \\ uv = a - b \end{cases}$$

(u, v) ជារឺសនៃសមីការ $t^2 - (a-b)t + (a-b) = 0$ គ្មានរឺស។

ដូច្នេះសមីការមានរឺសពីរ គឺ $x_1 = a; x_2 = b$ ។

91. ▲ តាង

$$y=\sqrt{\frac{x+3}{2}}-1 \implies y\geq 0; y+1=\sqrt{\frac{x+3}{2}}$$
$$\implies 2y^2+4y+2=x+3$$
$$\implies x=2y^2+4y-1$$
ដូច្នេះ ចំពោះ $x\geq -1$ យើងទាញបានថា អនុគមន៍ $y=2x^2+4x-1$ ជាអនុគមន៍ច្រាស នៃអនុគមន៍ $y=\sqrt{\frac{x+3}{2}}-1$ ម្យ៉ាងវិញទៀត អនុគមន៍ $y=2x^2+4x-1$ កើនលើ $(-1;\infty)$ (អនុគមន៍ទាំងពីរឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$) ដូច្នេះ
$$2x^2+4x-1=\sqrt{\frac{x+3}{2}}-1$$
$$\Leftrightarrow 2x^2+4x-1=x$$
$$\Leftrightarrow 2x^2+3x-1=0$$
$$\implies x=\frac{-3+\sqrt{17}}{4}$$
92. ▲ យើងមាន
$$x^4+x^2+1=(x^2+x+1)(x^2-x+1)>0$$
$$x^2-3x+1=2(x^2-x+1)-(x^2+x+1)$$
តាង $t=\sqrt{\frac{x^2-x+1}{x^2+x+1}}$ ។ សមីការទៅជា
$$2t^2-mt-1=0 \quad (1)$$
ពី $t=\sqrt{\frac{x^2-x+1}{x^2+x+1}}$ យើងទាញបាន
$$t^2(x^2+x+1)=x^2-x+1$$
$$(t^2-1)x^2+(t^2+1)x+t^2-1=0 \quad (2)$$
$$\Delta=(t^2+1)^2-4(t^2-1)^2$$
$$=(3-t^2)(3t^2-1)\geq 0$$
$$\implies \frac{\sqrt{3}}{3}\leq t\leq \sqrt{3}$$
ក) ករណី $m=-\sqrt{3}/3$

ពី(១) យើងទាញបាន
$$t_1=-\frac{3}{2\sqrt{3}}; t_2=\frac{1}{\sqrt{3}}$$
យើងយក $t=1/\sqrt{3}$ ។ ពី(២) យើងទាញបាន $x=1$ ។

១) ក្នុងសមីការ(១) យើងមាន $\Delta = m^2 + 8 > 0$ ដូច្នេះ(១)មានរឹសពីរ $t_1; t_2$ ។ ដោយ $t_1 t_2 = -\frac{1}{2} < 0$ នោះ $t_1 < 0 < t_2$ ។ មានតែរឹស t_2 មួយគត់ ដែលអាចអោយសមីការ(២) មានរឹស ព្រោះ $\frac{\sqrt{3}}{3} \le t \le \sqrt{3}$។ សមីការ(*) មានរឹសតែមួយគត់ បើ សមីការ(២)មានរឹសតែមួយគត់ដែរ។

បើ $t = 1$ នោះ (១)នាំអោយ $m = 1$ ហើយ (២) នាំអោយ $x = 0$ ។

បើ $t^2 - 1 \neq 0$ នោះ $\Delta = (3 - t^2)(3t^2 - 1) = 0 \implies t_1 = \frac{\sqrt{3}}{3}; t_2 = \sqrt{3}$ ។

បើ $t = \frac{\sqrt{3}}{3}; (1) \implies m = -\frac{\sqrt{3}}{3} \implies x = 1$

បើ $t = \sqrt{3}; (1) \implies m = \frac{5\sqrt{3}}{3} \implies x = 1$

ដូច្នេះ $m = \left\{-\frac{\sqrt{3}}{3};\ 1; \frac{5\sqrt{3}}{3}\right\}$ ។

93. ▲ តាង $y = \sqrt[3]{7x+1}; z = -\sqrt[3]{x^2 - x - 8}; t = \sqrt[3]{x^2 - 8x - 1}$ ។ ដូច្នេះ

$$\begin{aligned} & y + z + t = 2 \\ \implies & (y + z + t)^3 = 8 \quad (1) \end{aligned}$$

យើងមាន

$$y^3 + z^3 + t^3 = (7x + 1) - (x^2 - x - 8) + (x^2 - 8x - 1) = 8 \quad (2)$$

ពី(១)និង(២) យើងទាញបាន

$$(y + z + t)^3 - (y^3 + z^3 + t^3) = 3(y + z)(z + t)(t + y) = 0$$

$$\implies \begin{bmatrix} y + z = 0 \\ z + t = 0 \\ t + y = 0 \end{bmatrix} \iff \begin{bmatrix} y = -z \\ z = -t \\ t = -y \end{bmatrix}$$

$$\sqrt[3]{7x+1} = \sqrt[3]{x^2 - x - 8} \iff 7x + 1 = x^2 - x - 8 \iff x = -1\ ; x = 9$$

$$\sqrt[3]{x^2 - x - 8} = \sqrt[3]{x^2 - 8x - 1} \iff x^2 - x - 8 = x^2 - 8x - 1 \iff x = 1$$

$$\sqrt[3]{7x+1} = -\sqrt[3]{x^2 - 8x - 1} \iff 7x + 1 = -(x^2 - 8x - 1) \iff x = 0; x = 1$$

94. ▲ តាង $u = \sqrt{x+1} \ge 0; v = \sqrt{x^2 - x + 1} > 0$ ។ សមីការសមមូលនឹង

$$5uv = 2(v^2 + v^2) \iff 5\frac{u}{v} = 2\left(\frac{u}{v}\right)^2 \iff \begin{bmatrix} \frac{u}{v} = 2 \\ \frac{u}{v} = \frac{1}{2} \end{bmatrix}$$

$$\frac{u}{v} = 2 \iff \sqrt{x+1} = 2\sqrt{x^2 - x + 1}$$

$$\Leftrightarrow \begin{cases} x > -1 \\ 4x^2 - 5x + 3 = 0 \end{cases} : \text{ គ្មានរឺស}$$

$$\frac{u}{v} = \frac{1}{2} \Leftrightarrow 2\sqrt{x+1} = \sqrt{x^2 - x + 1}$$

$$\Leftrightarrow \begin{cases} x > -1 \\ x = \dfrac{5 \pm \sqrt{37}}{2} \end{cases}$$

សមីការមានរឺសពីរ $x = \frac{5\pm\sqrt{37}}{2}$ ។

IV. ប្រព័ន្ធសមីការ

95. $\left\{\left(-\frac{4}{9}; 20/9\right); (2;1)\right\}$. **96.** $\left\{(-1;3); \left(\frac{71}{21}; -25/7\right)\right\}$.**97.** $\{(51; 24{,}5)\}$.

98. $\{\,(-19{,}6\,; 5{,}2);\ (-14;8)\}$.● ដាក់អង្គខាងឆ្វេងនៃសមីការទីមួយជារាង $(x+3y)^2 - 6(x+3y) - 40$ ហើយតាង $x + 3y = t$ ។

99. $\{(2;3);(3;2)\}$**. 100.** $\{(4;-1);(1;-4)\}$. **101.** $\{(1;3);(3;1)\}$. **102.**$\{(1;2);(2;1)\}$
103.$\left\{\left(-\frac{1}{2}; -1/3\right); (1/3; 1/2)\right\}$.**104.**$\{(-1;2);(2;-1)\}$ **105.**$\{(3;2);(2;3)\}$
106.$\{(-1;-4);(4;1)\}$. **107.** $\{(-3;4);(4;-3)\}$. **108.** $\left\{\left(5+\sqrt{28}; -5+\sqrt{28}\right); \left(5-\sqrt{28}; -5-\sqrt{28}\right); (5;2); (-2;-5)\right\}$. **109.**$\{(0{,}6; 0{,}3); (0{,}4; 0{,}5)\}$.

110.$\left\{(-1;2); \left(-\frac{1}{4}; -\frac{1}{4}\right)\right\}$

111.$\left\{(2;1);(1;2);\left(\frac{5+\sqrt{21}}{2};\frac{5-\sqrt{21}}{2}\right);\left(\frac{5-\sqrt{21}}{2};\frac{5+\sqrt{21}}{2}\right)\right\}$.● តាង $x+y=u, xy=v$ បន្ទាប់មក $-u+v=z$ និង $uv=t$ ។

112. $\left\{\left(-\frac{25+5\sqrt{61}}{9};\frac{5+\sqrt{61}}{9}\right);\left(\frac{-25+5\sqrt{61}}{9};\frac{5-\sqrt{61}}{9}\right);(-6;-4/3);(3/2;1/3)\right\}$. ● តាង $x = yt$.

113. $\left\{(-1;3);(1;-3);\left(16/\sqrt{11}; 1/\sqrt{11}\right);\left(-16/\sqrt{11}; -1/\sqrt{11}\right)\right\}$.

114. $\left\{(1;2);(-1;-2);\left(\sqrt{2};\sqrt{2}\right);\left(-\sqrt{2};-\sqrt{2}\right)\right\}$.

115. $\left\{\left(\frac{2+\sqrt{19}}{\sqrt[3]{14+4\sqrt{19}}}; -\frac{3}{\sqrt[3]{14+4\sqrt{19}}}\right);\left(\frac{-2+\sqrt{19}}{\sqrt[3]{-14+4\sqrt{19}}};\frac{3}{\sqrt[3]{-14+4\sqrt{19}}}\right);(2;-1)\right\}$.

116. $\{(2;1)\}$. ▲ គុណសមីការទីពីរនឹង 2 រួចបូកចូលសមីការទីមួយ បន្ទាប់មកគុណសមីការទីពីរដដែលនឹង -2 រួចបូកចូលសមីការទីមួយចាស់ យើងទាញបានប្រព័ន្ធថ្មី

$$\begin{cases}16x^2+8xy+y^2-72x-18y+81=0\\4x^2-12xy+9y^2-4x+6y+1=0\end{cases}$$
$$\Leftrightarrow \begin{cases}(4x+y)^2-18(4x+y)+81=0\\(2x-3y)^2-2(2x-3y)+1=0\end{cases}$$
$$\Leftrightarrow \begin{cases}4x+y=9\\2x-3y=1\end{cases}$$

117. $\{(0;1/\sqrt{3});(0;-1/\sqrt{3});(1;1);(-1;-1)\}$. **118.** $\left\{\left(\frac{2}{7};-9/7\right);(1;3)\right\}$.

119. $\{(2;6);(1;3)\}$.**120.** $\{(2\sqrt{2};-\sqrt{2});(-2\sqrt{2};\sqrt{2})\}$.

121. $\{(\sqrt{6};\sqrt{6}/3);(-\sqrt{6};-\sqrt{6}/3)\}$

122. $\{(2;1;-1);(31/15;17/15;-2/3)\}$. **123.** $\{(1;2;2);(2;1;1)\}$

124. $\left\{(3;-2;1);(-2;3;1);\left(\frac{3+\sqrt{17}}{2};\frac{3-\sqrt{17}}{2};-1\right);\left(\frac{3-\sqrt{17}}{2};\frac{3+\sqrt{17}}{2};-1\right)\right\}$.

125. $\{(3;1;-2);(-5;-3;0)\}$. **126.** $\{(3;5;-1);(-3;-5;1)\}$

127. $\left\{(2;-1;3);(-2;1;-3);\left(-\frac{7}{\sqrt{13}};\frac{5}{\sqrt{13}};-\frac{11}{\sqrt{13}}\right);\left(\frac{7}{\sqrt{13}};-\frac{5}{\sqrt{13}};\frac{11}{\sqrt{13}}\right)\right\}$.

128. $\{(-4;-3;1);(4;3;-1)\}$. **129.** $\{(1/2;1/3;1/4)\}$.

130. $\{(-1;1;0);(1;-1;0)\}$. **131.** $\{(3;3;3)\}$.

132. $\{(16;30)\}$. **133.** $\{(41;40)\}$. **134.** $\left\{(c;c-1)|c\in\mathbb{R}\setminus\left\{\frac{1}{2}\right\}\right\}$.

135. $\left\{\left(-\frac{1}{2};-\frac{2}{5}\right);(5;4)\right\}$.

136. $\left\{\left(\sqrt{\frac{3\sqrt{109}+9}{2}};\sqrt{\frac{3\sqrt{109}-9}{2}}\right);(-5;-3)\right\}$. **137.** $\{(0;a+\sqrt{a^2+3})\}$ ចំពោះ $a\in(-\infty;\sqrt{3})$; $\{(0;a+\sqrt{a^2+3});(0;-a-\sqrt{a^2-3});(0;-a+\sqrt{a^2-3})\}$ ចំពោះ $a\in[\sqrt{3};\infty)$។

138. $\{(1;1;0)\}$. ▲ សមីការទីមួយ យើងទាញបាន $x=2-y$ ។ ជំនួសចូលសមីការទីពីរ យើងទាញបាន

$$\begin{aligned}&2y-y^2-z^2=1\\ \Rightarrow\ &z^2+(y-1)^2=0\\ \Rightarrow\ &z=0;y=1\end{aligned}$$

139. $\left\{-\frac{1}{4}\right\}\cup[0;\infty)$.

140. ក) 25. ▲ គុណសមីការទីមួយនឹង α និងសមីការទីពីរនឹង β ដែល $\alpha\beta\neq 0$ បន្ទាប់មកបូកចូលគ្នា យើងទាញបាន៖

$$\left(\frac{2\alpha}{3}+\beta\right)x+\left(\frac{4\alpha}{5}+\beta\right)y+\left(\frac{5\alpha}{6}+\beta\right)z=61\alpha+79\beta$$

យើងយក $\frac{2\alpha}{3}+\beta=0;\frac{4\alpha}{5}+\beta=\frac{2}{5};\ \frac{5\alpha}{6}+\beta=\frac{1}{2}$ ។ យើងទាញបាន $\alpha=3,\beta=-2$ ។ ដូច្នេះ $\frac{2}{5}y+\frac{z}{2}=61\alpha+79\beta=15$ ។

ខ) $\{(27;10;42)\}$. ▲ ដោយសារ x,y,z ជាចំនួនគត់ធម្មជាតិ នោះ $x=3k;y=5l;z=6m$ ដែល $k;l;m\in\mathbb{N}$ ។ ប្រព័ន្ធសមីការសមមូលនឹង

$$\begin{cases}4l+5m=61-2k\\5l+6m=79-3k\end{cases}$$

យើងទាញបាន $l=29-3k$ និង $m=2k-11$ ។ ដោយ $k;l;m\in\mathbb{N}$នោះ

$$\begin{cases}k>0\\29-3k>0\\2k-11>0\end{cases}$$

យើងទាញបាន $k=9$ ។

141.▲ ចំពោះ $a=0$ យើងទាញបាន $(x,y,z)=(0,0,0)$។ ចំពោះ $a\neq 0$ យើងទាញបាន $(x,y,z)\in\{(t_1,t_2,z_0);(t_2,t_1,z_0)\}$ ដែល

$$z_0=\frac{a^2-b^2}{2a};\ t_{1,2}=\frac{a^2+b^2\pm\sqrt{(3a^2-b^2)(3b^2-a^2)}}{4a}$$

ដើម្បីអោយចំលើយវិជ្ជមាននិងខុសគ្នា លក្ខខណ្ឌចាំបាច់នឹងគ្រប់គ្រាន់គឺ $3b^2>a^2>b^2$ និង $a>0$ ។

142.▲ បូកសមីការទាំងអស់បញ្ចូលគ្នា យើងទាញបាន $2(x_1+x_2+x_3+x_4+x_5)=y(x_1+x_2+x_3+x_4+x_5)$ ។ បើ $y=2$ នោះយើងទាញបាន $x_1-x_2=x_2-x_3=\cdots=x_5-x_1$ ដូច្នេះ $x_1=x_2=\cdots=x_5$ ជាចំលើយរបស់ប្រព័ន្ធ។ បើ $y\neq 2$ នោះ $x_1+x_2+x_3+x_4+x_5=0$។ បូកសមីការទីបីខាងដើមចូលគ្នា យើងទាញបាន $x_2=y(x_1+x_2+x_3)$ ។ដោយ $x_1+x_3=yx_2$ នោះ $x_2=(y^2+y)x_2,\Longrightarrow(y^2+y-1)x_2=0$ ។ បើ $y^2+y-1\neq 0$ នោះ $x_2=0$ ដូចគ្នាយើងទាញបាន $x_1=x_2=\cdots=x_5=0$ ។ បើ $y^2+y-1=0$ នោះ បូកសមីការទីមួយនិងទីពីរ យើងទាញបាន $x_5+x_2+x_1+x_3=yx_1+yx_2\ \Longrightarrow x_3+x_5=yx_1+yx_2-x_2-x_1\ \Longrightarrow\ x_3+x_5=-y^2x_2-y^2x_1\ \Longrightarrow x_3+x_5=-y(x_1+x_3)-y(x_5+x_2)\ \Longrightarrow x_3+x_5=yx_4$ ។ ដូចគ្នា យើងទាញបានសមីការទី៥។ មានន័យថា សមីការទី៤និងទី៥ អាស្រ័យលីនេអ៊ែរនឹងសមីការបីខាងលើ។ យក $x_1=u;x_5=v$ ។ យើងទាញបាន $x_2=yu-v;x_3=y^2u-yv-u;x_4=y^3u-y^2v-2yu+v$ ។

143.▲ សន្មតថា (x_1,x_2,x_3) ជាចំលើយរបស់ប្រព័ន្ធ។ យើងអាចសន្មតថា $|x_1|\geq|x_2|\geq|x_3|$ ។ សន្មតថា $|x_1|>0$ ។ ពីសមីការទីមួយ យើងទាញបាន

$$0 = |x_1|.\left|a_{11} + a_{12}\frac{x_2}{x_1} + a_{13}\frac{x_3}{x_1}\right| \geq |x_1|.(a_{11} - |a_{12}| - |a_{13}|) > 0$$

មិនអាច។ ដូច្នេះ $|x_1| = 0$ នាំអោយ $x_1 = x_2 = x_3 = 0$ ។

144.▲ បើមានចំនួនណាមួយស្មើសូន្យ ឧបមាថា $x_1 = 0$ នោះ $x_1 + x_2x_3x_4 = 2 \Rightarrow x_2x_3x_4 = 2; x_2 + x_1x_3x_4 = 2 \Rightarrow x_2 = 2; \dots; x_3 = x_4 = 2$ មិនអាច។ ដូច្នេះគ្មានចំនួនណាមួយអាចស្មើសូន្យបានទេ។ តាង $x_1x_2x_3x_4 = p$ ។ សម្មតិកម្មសមមូលនឹង $x_i + \frac{p}{x_i} = 2, i = 1,2,3,4$ ។ សមីការ $x + \frac{p}{x} = 2$ មានរឹសយ៉ាងច្រើនចំនួនពីរតាងដោយ y និង z ។ ដូច្នេះ x_i នីមួយៗអាចស្មើ y រឺស្មើz ។ យើងមានបីករណី៖

$x_1 = x_2 = x_3 = x_4 = y$ ។ ដូច្នេះ $y + y^3 = 2$ នាំអោយ $y = 1$ ។

$x_1 = x_2 = x_3 = y, x_4 = z$ ។ ដូច្នេះ $z + y^3 = y + y^2z = 2$ ។ យើងទាញបាន $(y; z) = \{(-1; 3); (1; 2)\}$

$x_1 = x_2 = y, x_3 = x_4 = z$ ។ ករណីនេះយើងទាញបាន $y = z = 1$ ។

ដូច្នេះរឹស $(x_1; x_2; x_3; x_4)$ គឺ $\{(1; 1; 1; 1); (-1; -1; -1; 3)\}$ និងចំលាស់របស់វា។

145.▲ តាង $L_1 = |a_1 - a_2|x_2 + |a_1 - a_3|x_3 + |a_1 - a_4|x_4$ និងដូចគ្នាចំពោះ L_2, L_3 និង L_4 ។ សន្មតថា $a_1 < a_2 < a_3 < a_4$ ។ នៅក្នុងករណីនេះ

$$\begin{aligned}2|a_1 - a_2||a_2 - a_3|x_2 &= |a_3 - a_2|L_1 - |a_1 - a_3|L_2 + |a_1 - a_2|L_3\\ &= |a_3 - a_2| - |a_1 - a_3| + |a_1 - a_2| = 0\\ 2|a_2 - a_3||a_3 - a_4|x_3 &= |a_4 - a_3|L_2 - |a_2 - a_4|L_3 + |a_2 - a_3|L_4\\ &= |a_4 - a_3| - |a_2 - a_4| + |a_2 - a_3| = 0\end{aligned}$$

ដូច្នេះ យើងទាញបាន $x_2 = x_3 = 0$ ហើយនាំអោយ $x_1 = x_4 = 1/|a_1 - a_4|$ ។ រឹសនេះផ្ទៀងផ្ទាត់ប្រព័ន្ធសមីការដែលអោយ។ ចំលើយផ្សេងទៀតជាចំលាស់នៃចំលើយមួយនេះ។

146.▲ បើមួយក្នុងចំនោម x, y, z ស្មើ 1 រឺ -1 នោះ $(-1, -1, -1)$ និង $(1,1,1)$ ។ ប្រព័ន្ធគ្មានចំលើយផ្សេងពីនេះទេ។ តាង $f(t) = t^2 + t - 1$ ។ បើក្នុងចំនោម x, y, z មានមួយធំជាង 1 សន្មតថា $x > 1$ យើងមាន $x < f(x) = y < f(y) = y < f(y) = z < f(z) = x$ មិនអាច។ ដូច្នេះ $x, y, z \leq 1$ ។

ឥលូវសន្មតថា មានមួយក្នុងចំនោម x, y, z សន្មតថា x មានតំលៃតូចជាង -1 ។ ដោយ $\min f = -\frac{5}{4}$ នោះ យើងមាន $x = f(z) \in \left[-\frac{5}{4}; -1\right)$។ ដោយ $f\left(\left[-\frac{5}{4}; -1\right)\right) = (-1; -11/16) \subseteq (-1; 0)$ និង $f\big((-1; 0)\big) = \left[-\frac{5}{4}; -1\right)$ ដូច្នេះ $y = f(x) \in (-1; 0), z = f(y) \in \left[-\frac{5}{4}; -1\right)$ និង $x = f(z) \in (-1,0)$ ផ្ទុយពីការសន្មត។ ដូច្នេះ $-1 \leq x, y, z \leq 1$ ។

បើ $-1 < x, y, z < 1$ នោះ $x > f(x) = y > f(y) = z > f(z) = x$ មិនអាច។

147.$(-2;-1);\left(-\frac{14}{3};\frac{13}{3}\right).$

148.▲ តាង $S_k=x_1^k+x_2^k+\cdots+x_n^k$ និង តាង $\sigma_k,k=1,2,\dots,n$ ជាពហុធាស៊ីមេទ្រីបឋមទីk នៃ $x_1,x_2,\dots,x_n$។ ពហុធាស៊ីមេទ្រីបឋមទីk ជា $\sigma_k(x_1,x_2,\dots,x_n)=\sum x_{i_1}x_{i_2}\dots x_{i_k}$ ដែល $\{i_1,i_2,\dots,i_k\}\in\{1,2,\dots,n\}$។ ឧទាហរណ៍ $\sigma_1(x_1,x_2,x_3)=x_1+x_2+x_3;\ \sigma_2(x_1,x_2,x_3)=x_1x_2+x_2x_3+x_3x_1;\ \sigma_3(x_1,x_2,x_3)=x_1x_2x_3$ ។

ប្រព័ន្ធសមីការដែលអោយ $S_k=a^k,k=1,2,\dots,n$ ។ តាមរូបមន្តញូវតុន យើងទាញបាន

$$k\sigma_k=S_1\sigma_{k-1}-S_2\sigma_{k-2}+\cdots+(-1)^kS_{k-1}\sigma_1+(-1)^{k-1}S_k,k=1,2,\dots,n$$

$$\sigma_1=a$$

$$k\sigma_2=S_1\sigma_1+(-1)^1S_2=a.a-a^2=0,\sigma_2=0$$

$$\dots$$

$$\Longrightarrow\sigma_1=a;\ \ \sigma_k=0 \text{ ចំពោះ } k=2,\dots,n$$

តាមទ្រឹស្តីបទវៀែត $x_1,x_2,\dots,x_n$ ជារឹសនៃពហុធា x^n-ax^{n-1} មានន័យថា រឹសទាំងនោះស្មើនឹង $a,0,\dots,0$ និងចំលាស់ទាំងអស់។

149.▲ បើ $m\notin\{-2;1\}$ នោះប្រព័ន្ធមានរឹសតែមួយគត់

$$x=\frac{b+a-(1+m)c}{(2+m)(1-m)};y=\frac{a+c-(1+m)b}{(2+m)(1-m)};z=\frac{b+c-(1+m)a}{(2+m)(1-m)}$$

ចំនួន x,y,z ជាស៊ីតនព្វន្ត បើនិងមានតែបើ a,b,c ជាស៊ីតនព្វន្តដែរ។

បើ $m=1$ នោះប្រព័ន្ធមានចំលើយ បើនិងមានតែបើ $a=b=c$។ ករណី $m=-2$ ប្រព័ន្ធមានចំលើយ បើនិងមានតែបើ $a+b+c=0$ ។ នៅក្នុងករណីទាំងពីរនេះ ប្រព័ន្ធមានចំលើយច្រើនរាប់មិនអស់។

150.▲ យើងមាន $c_n>0$ ចំពោះគ្រប់ n គូ។ ដូច្នេះ $c_n=0$ អាចបានតែចំពោះ n សេសតែប៉ុណ្ណោះ។ សន្មតថា $a_1\le a_2\le\cdots\le a_8$ ហើយថា $a_1\le 0\le a_8$។

បើ $|a_1|<|a_8|$ នោះមាន n_0 ដែលចំពោះគ្រប់ចំនួនសេស $n>n_0$ យើងមាន $7|a_1|^n<a_8^n$ ។ ដូច្នេះ $a_1^n+a_2^n+\cdots+a_8^n>7a_1^n+a_8^n>0$ ផ្ទុយពីលក្ខខណ្ឌដែលថា $c_n=0$ ចំពោះតំលៃ n ច្រើនរាប់មិនអស់។ ដូចគ្នាករណី $|a_1|>|a_8|$ ក៏មិនអាចដែរ។ យើងទាញបាន $a_1=-a_8$ ។ តាមរបៀបដូចគ្នា យើងទាញបាន $a_2=-a_7;a_3=-a_6$ និង $a_4=-a_5$ ។ ហើយ $c_n=0$ ចំពោះគ្រប់ចំនួនសេស n ។

151.▲ តាង $X=1-x;Y=1-y;Z=1-z;T=1-t$ ។ យើងទាញបាន

$$\begin{cases} X^2 = Y \\ Y^2 = Z \\ Z^2 = T \\ T^2 = X \end{cases}$$

យើងទាញបាន $X^4 = Y^2 = Z \Rightarrow X^8 = Z^2 = T \Rightarrow X^{16} = T^2 = X \Rightarrow X(X^{15} - 1) = 0$ ។ យើងទាញបាន

- $X = 0; \Rightarrow Y = Z = T = 0 \Rightarrow x = y = z = t = 1$

- $X = 1; \Rightarrow Y = Z = T = 1 \Rightarrow x = y = z = t = 0$

152.▲ បូកសមីការទាំងអស់បញ្ចូលគ្នា យើងទាញបាន

$$0 = \sum_{i=1}^{1000} \left(x_i^2 + 2\left(\frac{a-1}{2}\right)x_i + \left(\frac{a-1}{2}\right)^2 \right) = \sum_{i=1}^{1000} \left(x_i + \frac{a-1}{2} \right)^2$$

យើងទាញបាន $x_1 = x_2 = \cdots = x_{1000} = \frac{a-1}{2}$ ។

153.▲ តាង $t_1 = x_1 - x_2; t_2 = x_2 - x_3; \dots; t_n = x_n - x_1$ ។ ប្រព័ន្ធសមីការសមមូលនឹង

$$\begin{cases} 2t_1 = 3t_2 \\ 2t_2 = 3t_3 \\ \quad \dots\dots \\ 2t_n = 3t_1 \end{cases}$$

គុណអង្គនឹងអង្គនៃសមីការ យើងទាញបាន $2^n t_1 t_2 \dots t_n = 3^n t_1 t_2 \dots t_n \Rightarrow t_1 t_2 \dots t_n = 0$។ ដូច្នេះត្រូវមាន t_i មួយដែលស្មើសូន្យ ។ ហើយដោយ $2t_i = 3t_{i+1}$ នោះ យើងទាញបាន $t_1 = t_2 = \cdots = t_n = 0$ ហើយ $x_1 = x_2 = \cdots = x_n$ ។

154.▲ យើងមាន $3S = x^2 + y^2 + z^2 \geq 0 \Rightarrow S = x + y + z \geq 0$ ។ ដូច្នេះក្នុងចំនោម x, y, z ត្រូវតែមានមួយជាចំនួនមិនអវិជ្ជមាន។ សន្មតថា $x \geq 0$ ។ យើងទាញបាន

$$y(4 - y) = x \geq 0 \Rightarrow 0 \leq y \leq 4$$

ដូចគ្នាយើងទាញបាន $0 \leq x, y, z \leq 4$ ។ តាង $x = 4\sin^2\alpha$ ដែល $0 \leq \alpha \leq \frac{\pi}{2}$ ។ យើងទាញបាន $z = 4\sin^2 2\alpha\,; y = 4\sin^2 4\alpha$ ។ ហើយ $x = 4\sin^2 8\alpha$ ។ ដូច្នេះ

$$4\sin^2 8\alpha = 4\sin^2\alpha \Rightarrow \cos 16\alpha = \cos 2\alpha$$

នាំអោយ

1) $16\alpha = 2\alpha + 2k\pi \Rightarrow \alpha = \frac{k\pi}{7}\ (k \in \mathbb{Z});$

$$0 \leq \alpha \leq \frac{\pi}{2} \Rightarrow k = \{0; 1; 2; 3\}$$

- $k = 0$

$$x = y = 0; \Rightarrow S = 0$$

-$k = 1; 2; 3$

$$\Longrightarrow\ S = 4\left(\sin^2\frac{\pi}{7} + \sin^2\frac{2\pi}{7} + \sin^2\frac{3\pi}{7}\right) = 7$$

2) $16\alpha = -2\alpha + 2k\pi \ \ \Longrightarrow \alpha = \frac{k\pi}{9}\ (k \in \mathbb{Z});$

$$0 \le \alpha \le \frac{\pi}{2} \Longrightarrow k = \{0; 1; 2; 3; 4\}$$

- $k = 0$

$$x = y = 0;\ \Longrightarrow S = 0$$

- $k = 1; 2; 4$

$$\Longrightarrow\ S = 4\left(\sin^2\frac{\pi}{9} + \sin^2\frac{2\pi}{9} + \sin^2\frac{4\pi}{9}\right) = 6$$

- $k = 3$

$$\Longrightarrow\ S = 4\left(\sin^2\frac{\pi}{3} + \sin^2\frac{2\pi}{3} + \sin^2\frac{4\pi}{3}\right) = 9$$

155. $\{(1; 1; 1); (-2; -2; -2)\}$▲យកសមីការទីមួយដកសមីការទីពីរ សមីការទីពីរដកសមីការទីបី យើងទាញបាន

$$(x-y)(1-z) = 0; \quad (1)$$
$$(y-z)(1-x) = 0 \quad (2)$$

$(1) \Longrightarrow\ \ x = y$ រឺ $z = 1$

$(2) \Longrightarrow\ \ y = z$ រឺ $x = 1$

យើងទាញបានបួនករណី

$$(x = y = z); (x = y; x = 1); (z = 1; y = z); (z = 1; x = 1)$$

ករណីទាំងបួននេះ ត្រូវនឹង $x = y = z = 1$ រឺ $x = y = z = -2$ ។

156. ▲ យើងសិក្សាករណី $a > 0$ ព្រោះ $a \neq 0$ ។ ករណី $a < 0$ គុណអង្គសមីការនឹងសញ្ញាដក។ បូកសមីការទាំងបីនៃប្រព័ន្ធបញ្ចូលគ្នា យើងទាញបាន

$$[ax^2 + (b-1)x + c] + [ay^2 + (b-1)y + c] + [az^2 + (b-1)z + c] = 0$$

តាង $f(t) = at^2 + (b-1)t + c$ ។ យើងមាន

$$f(x) + f(y) + f(z) = 0 \qquad (*)$$

បើ $\Delta = (b-1)^2 - 4ac < 0$ នោះ $f(t) > 0$ ចំពោះគ្រប់ $t \in \mathbb{R}$ ព្រោះ $a > 0$។ ដូច្នេះ

$$f(x) + f(y) + f(z) > 0$$

ផ្ទុយពីសមីការ(*)។

157. ▲ ជំនួស $y = -x$ ចូលក្នុងប្រព័ន្ធ យើងទាញបាន

$$\begin{cases} x^3 + ax^3 = \dfrac{1}{2}(a+1)^2 & (1) \\ 2x^3 - ax^3 = 1 & (2) \end{cases}$$

សមីការទី២ យើងទាញបាន $x \neq 0$ ។ បូកសមីការទាំងពីរចូលគ្នា យើងទាញបាន

$$3x^3 = \frac{1}{2}(a+1)^2 + 1 > 0; \Rightarrow x > 0$$

យកសមីការទី១ចែកនឹងសមីការទី២ យើងទាញបាន

$$\frac{a+1}{2-a} = \frac{1}{2}(a+1)^2 \quad \Rightarrow a = 0;\ -1; 1$$

ចំពោះ $a = 0$ យើងមាន

$$\begin{cases} x^3 = \dfrac{1}{2} \\ x^3 + xy^2 = 1 \end{cases} \Leftrightarrow \begin{cases} x = \dfrac{1}{\sqrt[3]{2}} \\ y = \pm\dfrac{1}{\sqrt[3]{2}} \end{cases}$$

រឹសដែលផ្ទៀងផ្ទាត់គឺ $x = \frac{1}{\sqrt[3]{2}}; y = -\frac{1}{\sqrt[3]{2}}$ ។

ចំពោះ $a = -1$ យើងទាញបាន

$$\begin{cases} x^3 + y^3 = 0 \\ x^3 - x^2y + xy^2 = 1 \end{cases} \Rightarrow \begin{cases} x = \dfrac{1}{\sqrt[3]{3}} \\ y = -\dfrac{1}{\sqrt[3]{3}} \end{cases}$$

ចំពោះ $a = 1$ យើងទាញបាន

$$\begin{cases} x^3 - y^3 = 2 \\ x^3 + x^2y + xy^2 = 1 \end{cases} \Rightarrow \begin{cases} x^3 - y^3 = 2 \\ 2x^3 + 2x^2y + 2xy^2 = 2 \end{cases}$$
$$\Rightarrow x^3 + 2x^2y + 2xy^2 + y^3 = 0$$
$$\Rightarrow (x+y)(x^2 - xy + y^2) + 2xy(x+y) = 0$$
$$\Rightarrow (x+y)(x^2 + xy + y^2) = 0$$
$$\Rightarrow x + y = 0$$
$$\Rightarrow x = 1; y = -1$$

ដូច្នេះ $a = \{-1; 0; 1\}$ ប្រព័ន្ធមានរឹសផ្ទៀងផ្ទាត់ លក្ខខណ្ឌ។

158. ▲ប្រព័ន្ធសមមូលនឹង

$$\begin{cases} 3x^2 - 2(3+z)x + 3z + 3 = 0 & (1) \\ y^3 + 3y^2 = x^2 - 3x + 2 & (2) \\ y^2 = -z^2 + 6z & (3) \\ z \leq 3 & (4) \end{cases}$$

សមីការ(១) មានរឹស បើ $\Delta' = (3+z)^2 - 3(3z+3) \geq 0 \quad \Rightarrow z \leq 0\,; z \geq 3$ (៥)។ សមីការទី៣ មានរឹសបើ $-z^2 + 6z \geq 0 \quad \Rightarrow 0 \leq z \leq 6$ (៦)។ ពី(៤) (៥)(៦)យើងទាញបាន $z = 0; z = 3$ ។ បើ $z = 0$ នោះ តាម(៣) យើងទាញបាន $y = 0;$ និងពី(២) យើងទាញបាន $x = 1; x = 2$ ។ ផ្ទៀងផ្ទាត់តាម(១) យើងទាញបាន $x = 1$ ។

បើ $z=3$ នោះ តាម(៣) យើងទាញបាន $y=\pm 3$ ។ ពី(១) យើងទាញបាន $x=2$ ។ ចំពោះ $x=2$ ផ្ទៀងផ្ទាត់តាម(២) យើងទាញបាន $y=-3$ ។ ដូច្នេះ

$$(x;y;z)=\{(1;0;0);(2;-3;3)\}$$

159. ▲ គុណសមីការទីមួយទីពីរនិងទីបី នឹង c,a,b រៀងគ្នា យើងទាញបាន

$$\begin{cases}\frac{ac}{x}-\frac{bc}{z}=c^2-czx\\ \frac{ab}{y}-\frac{ac}{x}=a^2-axy\\ \frac{bc}{z}-\frac{ab}{y}=b^2-byz\end{cases}$$

បូកសមីការទាំងបីបញ្ចូលគ្នា យើងទាញបាន

$$a^2+b^2+c^2=axy+bzy+cxz \qquad (1)$$

បំបាត់ភាគបែងនៃប្រព័ន្ធដើម

$$\begin{cases}az-bx=cxz-z^2x^2\\ bx-cy=axy-x^2y^2\\ cy-az=bzy-y^2z^2\end{cases}$$

បូកបញ្ចូលគ្នា យើងទាញបាន

$$x^2y^2+y^2z^2+z^2x^2=axy+bzy+cxz \qquad (2)$$

បូក(១)នឹង(២) យើងទាញបាន

$$a^2+b^2+c^2+x^2y^2+y^2z^2+z^2x^2=2(axy+bzy+cxz)$$
$$\Longrightarrow\quad (xy-a)^2+(zy-b)^2+(xz-c)^2=0$$
$$\Longrightarrow\begin{cases}xy=a\\ zy=b\\ xz=c\end{cases}$$
$$\Longrightarrow\quad (x;y;z)=\left\{\left(\sqrt{\frac{ac}{b}};\sqrt{\frac{ab}{c}};\sqrt{\frac{bc}{a}}\right);\left(-\sqrt{\frac{ac}{b}};-\sqrt{\frac{ab}{c}};-\sqrt{\frac{bc}{a}}\right)\right\}$$

160. ▲ ប្រព័ន្ធមានរឹសងាយ $(0;0;0)$ ។ បើ $x=\pm 1$ នោះ $\pm 2+y=y$ មិនអាច។ ដូចគ្នាយើងទាញបាន $x\neq\pm 1; y\neq\pm 1; z\neq\pm 1$ ។ យើងមាន

$$\begin{cases}2x+x^2y=y\\ 2y+y^2z=z\\ 2z+z^2x=x\end{cases}\quad\Leftrightarrow\quad\begin{cases}y=\frac{2x}{1-x^2} & (4)\\ z=\frac{2y}{1-y^2} & (5)\\ x=\frac{2z}{1-z^2} & (6)\end{cases}$$

តាង $x=\tan\alpha\neq\pm1\ \Longrightarrow \alpha\neq\pm\frac{\pi}{4}+k\frac{\pi}{2}, k\in\mathbb{Z}$ ។ ពី(៤) យើងទាញបាន $y=\tan 2\alpha$ និងពី(៥) យើងទាញបាន $z=\tan 4\alpha$ ហើយជាចុងក្រោយ $x=\tan 8\alpha=\tan\alpha$ ។ ដូច្នេះ

$$8\alpha=\alpha+n\pi \quad\Longrightarrow\quad \alpha=n\frac{\pi}{7}\ ;(n\in\mathbb{Z})$$

ដូច្នេះប្រព័ន្ធមានឫស $(x;y;z)=\left\{\left(\tan n\frac{\pi}{7};\tan n\frac{2\pi}{7};\tan n\frac{4\pi}{7}\right)|n\in\mathbb{Z}\right\}$

V. វិសមភាព

161. ▲ តាង $A=\frac{1}{2}.\frac{3}{4}.\frac{5}{6}\dots.\frac{99}{100}; B=\frac{2}{3}.\frac{4}{5}.\frac{6}{7}\dots\frac{98}{99}$ ។ ដោយ

$$\frac{2}{3}>\frac{1}{2};\frac{4}{5}>\frac{3}{4};\frac{6}{7}>\frac{5}{6};\dots;\frac{98}{99}>\frac{97}{98};1>\frac{99}{100}$$

នោះ $B>A$។ យើងមាន

$$AB=\left(\frac{1}{2}.\frac{2}{3}\right)\left(\frac{3}{4}.\frac{4}{5}\right)\left(\frac{5}{6}.\frac{6}{7}\right)\dots\left(\frac{98}{99}.\frac{99}{100}\right)=\frac{1}{100}$$

ដូច្នេះ $A^2<AB=\frac{1}{100}\ \Longrightarrow A<\frac{1}{10}$ ។

បន្ទាប់មកទៀត

$$B<2A=\frac{3}{4}.\frac{5}{6}.\frac{7}{8}\dots\frac{99}{100}$$

ព្រោះ $\frac{2}{3}<\frac{3}{4};\frac{4}{5}<\frac{5}{6};\frac{6}{7}<\frac{7}{8};\dots;\frac{98}{99}<\frac{99}{100}$។ ដូច្នេះ

$$A.2A>AB=\frac{1}{100}\quad\Longrightarrow A>\frac{1}{10\sqrt{2}}$$

162. ▲ យើងមាន

$$\frac{1}{2^{100}}C_{100}^{50}=\frac{1.2.3\dots100}{2^{50}(1.2.3\dots50).2^{50}(1.2.3\dots50)}$$
$$=\frac{1.2.3\dots100}{(2.4.6\dots100)(2.4.6\dots100)}=\frac{1.3.5..99}{2.4.6\dots100}$$

ហើយតាមសំនួរ**161.** យើងទាញបានវិសមភាពពិត។

163. ▲ ដំបូងយើងនឹងបង្ហាញថា ចំពោះគ្រប់ $n\geq1$ យើងមាន

$$\frac{1}{2}.\frac{3}{4}.\frac{5}{6}\dots\frac{2n-1}{2n}\leq\frac{1}{\sqrt{3n+1}}$$

ចំពោះ $n=1$ យើងមាន $\frac{1}{2}=\frac{1}{\sqrt{3.1+1}}$។ បន្ទាប់មកទៀតសន្មតថាពិតដល់ n មានន័យថា

$$\frac{1}{2}.\frac{3}{4}.\frac{5}{6}\dots\frac{2n-1}{2n}\leq\frac{1}{\sqrt{3n+1}}$$

យើងគុណអង្គសង្ខាងនៃវិសមភាពនេះនឹង $\frac{2n+1}{2n+2}$ យើងទាញបាន

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\cdot\frac{2n+1}{2n+2}\leq\frac{2n+1}{(2n+2)\sqrt{3n+1}}$$

យើងមាន

$$\left[\frac{2n+1}{(2n+2)\sqrt{3n+1}}\right]^2=\frac{(2n+1)^2}{12n^3+28n^2+20n+4}$$
$$=\frac{(2n+1)^2}{(12n^3+28n^2+19n+4)+n}$$
$$=\frac{(2n+1)^2}{(2n+1)^2(3n+4)+n}<\frac{1}{3n+4}$$
$$\Rightarrow\frac{2n+1}{(2n+2)\sqrt{3n+1}}<\frac{1}{\sqrt{3n+4}}$$
$$\Rightarrow\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\cdot\frac{2n+1}{2n+2}<\frac{1}{\sqrt{3n+4}}$$

164. ▲ អនុវត្តន៍វិសមភាពក្នុងសំនួរទី**163.** ចំពោះ $n = 50$ យើងទាញបាន

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}<\frac{1}{\sqrt{3n+1}}$$
$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2\times50-1}{2\times50}<\frac{1}{\sqrt{3\times50+1}}$$
$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{99}{100}<\frac{1}{\sqrt{151}}=\frac{1}{12{,}288}<\frac{1}{12}$$

ពិត។

165. ● ស្រាយបញ្ជាក់តាមកំនើន។

166. ▲ជាដំបូង យើងនឹងបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ$k\leq n$ យើងមាន

$$1+\frac{k}{n}\leq\left(1+\frac{1}{n}\right)^k<1+\frac{k}{n}+\frac{k^2}{n^2}$$

ចំពោះ $k=1$ វិសមភាពពិត។ សន្មតថាវិសមភាពពិតចំពោះតំលៃ k ណាមួយ។ យើងមាន

$$\left(1+\frac{1}{n}\right)^{k+1}=\left(1+\frac{1}{n}\right)^k\left(1+\frac{1}{n}\right)\geq\left(1+\frac{k}{n}\right)\left(1+\frac{1}{n}\right)$$
$$=1+\frac{k+1}{n}+\frac{k}{n^2}>1+\frac{k+1}{n}$$

ពិត (មិនចាំបាច់ទាល់តែ $k\leq n$ ទេ)។

យើងមាន

$$\left(1+\frac{1}{n}\right)^{k+1}=\left(1+\frac{1}{n}\right)^k\left(1+\frac{1}{n}\right)<\left(1+\frac{k}{n}+\frac{k^2}{n^2}\right)\left(1+\frac{1}{n}\right)$$
$$=1+\frac{k+1}{n}+\frac{k^2+2k+1}{n^2}-\frac{k+1}{n^2}+\frac{k^2}{n^3}$$

$$= 1 + \frac{k+1}{n} + \frac{(k+1)^2}{n^2} - \frac{n(k+1) - k^2}{n^3}$$
$$< 1 + \frac{k+1}{n} + \frac{(k+1)^2}{n^2}$$

ព្រោះ $n(k+1) > k^2$ បើ $n \geq k$ ។ ដូច្នេះដោយយក $k = n$ យើងទាញបាន

$$2 = 1 + \frac{1}{n} < \left(1 + \frac{1}{n}\right)^n < 1 + \frac{n}{n} + \frac{n^2}{n^2} = 3$$

167. ▲ តាមសំនួរ **166.** យើងទាញបាន

$$(1{,}000\,001)^{1\,000\,000} = \left(1 + \frac{1}{1\,000\,000}\right)^{1\,000\,000} > 2$$

168. ▲យើងមាន

$$\frac{1001^{999}}{1000^{1000}} = \left(\frac{1001}{1000}\right)^{1000} \cdot \frac{1}{1001} = \left(1 + \frac{1}{1000}\right)^{1000} \cdot \frac{1}{1001}$$
$$< \frac{3.1}{1001} < 1$$

(តាមសំនួរ **166.**)។ ដូច្នេះ $1000^{1\,000} > 1001^{999}$ ។

169. ▲យើងមាន

$$\begin{aligned} & \sqrt{c+1} - \sqrt{c} < \sqrt{c} - \sqrt{c-1} \\ \Leftrightarrow\ & \sqrt{c+1} - \sqrt{c-1} < 2\sqrt{c} \\ \Leftrightarrow\ & \left(\sqrt{c+1} - \sqrt{c-1}\right)^2 < 4c \\ \Leftrightarrow\ & \sqrt{c^2 - 1} < c \end{aligned}$$

ពិត។

170. ▲តាងចំនួនពិតទាំងនោះដោយ $x_1, x_2, \dots, x_n$ ដែល $x_1 x_2 \dots x_n = 1$ ។ យើងត្រូវបង្ហាញថា $x_1 + x_2 + \cdots + x_n \geq n$ ។ ចំពោះ $n = 1$ វិសមភាពពិត។ សន្មតថាពិតចំពោះ $n = k$ មានន័យថា ចំពោះគ្រប់ចំនួនពិត $x_1, x_2, \dots, x_k$ ដែល $x_1 x_2 \dots x_k = 1$ យើងមាន $x_1 + x_2 + \cdots + x_k \geq k$ ។ ចំពោះ $n = k+1$ បើ $x_1 = x_2 = \cdots = x_{k+1} = 1$ នោះ$x_1 + x_2 + \cdots + x_{k+1} \geq k+1$ វិសមភាពពិត។ ករណីផ្សេងពីនេះ ដោយសារ ផលគុណនៃចំនួនទាំងនេះមានតំលៃស្មើមួយ ហើយចំនួនទាំងនេះមិនមានតំលៃស្មើមួយដូចគ្នាទាំងអស់ ដូច្នេះមានចំនួនខ្លះតូចជាងមួយចំនួនខ្លះធំជាងមួយ។ សន្មត $x_1 < 1, x_{k+1} > 1$។ តាង $y_1 = x_1 x_{k+1}$។ យើងមាន $y_1 x_2 \dots x_k = 1$ ដូច្នេះ $y_1 + x_2 + \cdots + x_k \geq k$ ។ យើងមាន

$$\begin{aligned} x_1 + x_2 + \cdots + x_{k+1} &= (y_1 + x_2 + \cdots + x_k) - y_1 + x_1 + x_{k+1} \\ &\geq k - y_1 + x_1 + x_{k+1} = (k+1) - 1 - x_1 x_{k+1} + x_1 + x_{k+1} \\ &= k + 1 + (x_{k+1} - 1)(1 - x_1) > k+1 \end{aligned}$$

វិសមភាពពិតដល់ $k+1$ ។

171. ▲ ស្រាយបញ្ជាក់តាមកំនើន។ ចំពោះ $n=1$ វិសមភាពពិត។ សន្មតថាពិតចំពោះ $n=k$ មានន័យថា $(1+x_1)(1+x_2)\ldots(1+x_k)\geq 1+x_1+x_2+\cdots+x_k$ ។ គុណអង្គទាំងពីរនៃវិសមភព នឹង $(1+x_{k+1})$ យើងទាញបាន $(1+x_1)(1+x_2)\ldots(1+x_k)(1+x_{k+1})\geq(1+x_1+x_2+\cdots+x_k)(1+x_{k+1})$។ យើងមាន $(1+x_1+x_2+\cdots+x_k)(1+x_{k+1})\geq(1+x_1+x_2+\cdots+x_k)+x_{k+1}\Leftrightarrow(x_1+x_2+\cdots+x_k)x_{k+1}\geq 0$ ពិតព្រោះ $x_1,x_2,\ldots,x_{k+1}$ មានសញ្ញាដូចគ្នា។
ដូច្នេះ $(1+x_1)(1+x_2)\ldots(1+x_k)(1+x_{k+1})\geq(1+x_1+x_2+\cdots+x_k)+x_{k+1}$ ។

172. ▲ ចំពោះ $n=6$ យើងមាន $2^6=64<6!=720<3^6=729$
សន្មតថាវិសមភាពពិតចំពោះ ចំនួនគត់ធម្មជាតិ n មួយ។ យើងនឹងបង្ហាញថា ពិតចំពោះ $n+1$ ដែរ។ យើងមាន

$$\left(\frac{n}{2}\right)^n>n!>\left(\frac{n}{3}\right)^n$$
$$\Longrightarrow\ (n+1)\left(\frac{n}{2}\right)^n>(n+1)!>(n+1)\left(\frac{n}{3}\right)^n$$

ដូច្នេះ យើងគ្រាន់តែបង្ហាញថា

$$\left(\frac{n+1}{2}\right)^{n+1}>(n+1)\left(\frac{n}{2}\right)^n\ \text{និង}\ \left(\frac{n}{3}\right)^n(n+1)>\left(\frac{n+1}{3}\right)^{n+1}$$

ជាការស្រេច។ វិសមភាពទាំងពីរសមមូលនឹង

$$\frac{\left(\frac{n+1}{2}\right)^{n+1}}{\left(\frac{n}{2}\right)^n}>n+1>\frac{\left(\frac{n+1}{3}\right)^{n+1}}{\left(\frac{n}{3}\right)^n}$$
$$\Leftrightarrow\ \frac{\frac{1}{2}\left(\frac{n+1}{2}\right)^n}{\left(\frac{n}{2}\right)^n}>1>\frac{\frac{1}{3}\left(\frac{n+1}{3}\right)^n}{\left(\frac{n}{3}\right)^n}$$
$$\Leftrightarrow\frac{1}{2}\left(1+\frac{1}{n}\right)^n>1>\frac{1}{3}\left(1+\frac{1}{n}\right)^n$$
$$\Leftrightarrow 2<\left(1+\frac{1}{n}\right)^n<3$$

ពិត តាមសំនួរ **166.** ។

173. ▲ យើងមាន $\Delta'=999^2-ac>0;\ \Delta'\in\mathbb{Z}$ ព្រោះ $a,c\in\mathbb{Z}$ និង $|x_1-x_2|=\frac{2\sqrt{\Delta'}}{|a|}$ ។
បើ $\Delta'\geq 2$ នោះ

$$|x_1-x_2|=\frac{2\sqrt{\Delta'}}{|a|}>\frac{2\sqrt{\Delta'}}{2000}\geq\frac{2\sqrt{2}}{2000}>\frac{1}{998}$$

បើ $\Delta^{'}=1$ នោះ $ac=999^2-1=998.1000=2^4.5^3.449$ ។ យើងមាន $2^2.5^3.449=1996<2000$ ជាតួចែកមួយនៃ $2^4.5^3.449=ac \Rightarrow$ តួចែកធំបំផុតនៃ $ac=2^4.5^3.449$ ហើយដែលតូចជាង 2000 ស្មើនឹង 1996 ។ ដូច្នេះ $a\le 1996$ (ហេតុអ្វីបានយកតួចែកតូចជាង2000 ? ព្រោះ $|a|<2000, |c|<2000$)។ យើងទាញបាន

$$|x_1-x_2|=\frac{2\sqrt{\Delta^{'}}}{|a|}=\frac{2}{|a|}\ge\frac{1}{998}$$

174. ▲ លក្ខខណ្ឌដែលអោយ នាំអោយ $x\neq y$ និង

$$a=\frac{y-2}{y-x};b=\frac{2-x}{y-x}$$

ជំនួសចូលលក្ខខណ្ឌទីបី យើងទាញបាន

$$3=ax^2+by^2=\frac{(y-2)x^2}{y-x}+\frac{(2-x)y^2}{y-x}=2(x+y)-xy \quad (1)$$

តាង $C=ax^3+by^3>0$ ។ យើងមាន

$$\begin{aligned}C&=\frac{y-2}{y-x}x^3+\frac{2-x}{y-x}y^3\\&=-xy(x+y)+2(x^2+xy+y^2)\\&=-xy\,(x+y)+2(x+y)^2-2xy\\&=(x+y)[-xy+2(x+y)]-2xy\\&=3(x+y)-2xy; \qquad \text{តាម } (1)\end{aligned}$$

ដូច្នេះ

$$\begin{cases}2(x+y)-xy=3\\3(x+y)-2xy=C\end{cases}$$

យើងទាញបាន $x+y=6-C; xy=9-2C$ ។

យើងមាន $(x+y)^2>4xy \ \Rightarrow\ (6-C)^2>4(9-2C)\ \Rightarrow C>4$ ។

យើងមាន $xy>0\ \Rightarrow 9-2C>0; \Rightarrow C<4{,}5$ ។

175. ▲ ● ករណី $x<-3$ នោះ

$$S=|x|+\left|\frac{2x-1}{x+3}\right|>|x|>3$$

● ករណី $-3<x<0$

ករណីនេះ $\frac{2x-1}{x+3}<0$ ដូច្នេះ

$$S\ge\frac{2x-1}{x+3}=-2+\frac{7}{x+3}>-2+\frac{7}{3}=\frac{1}{3}$$

● ករណី $x>1/2$

យើងមាន

$$S = |x| + \left|\frac{2x-1}{x+3}\right| \geq |x| > \frac{1}{2}$$

● ករណី $0 \leq x \leq 1/2$

ករណីនេះយើងមាន $S \geq 1/3$ ព្រោះ

$$S = x - \frac{2x-1}{x+3} = \frac{x^2+x+1}{x+3}$$

$$S \geq \frac{1}{3} \Leftrightarrow \frac{x^2+x+1}{x+3} \geq \frac{1}{3}$$

$$\Leftrightarrow 3x^2 + 3x + 3 \geq x + 3 \quad \Leftrightarrow x \geq 0$$

ពិត។សញ្ញាស្មើកើតមាន ពេល $x = 0$ ។

ដូច្នេះ $\min S = 1/3$ ពេល $x = 0$ ។

176. ▲ សន្មតថា $a \geq 0$ ។ បើ $a < 0$ នោះគុណពហុធា$f(x)$ នឹង(-1) យើងទាញបានពហុធាដែលមេគុណវិជ្ជមាន ហើយនៅតែផ្ទៀងផ្ទាត់សម្មតិកម្មដដែល។ យើងសន្មតផងដែរថា $b \geq 0$ ។ បើ$b < 0$ នោះយើងយក $f(-x)$ ព្រោះសម្មតិកម្មស៊ីមេទ្រីធៀបនឹង x ។

ជំនួស $x = 0; x = \pm 1$ ចូល$f(x)$ យើងទាញបាន

$$\begin{cases} -1 \leq c \leq 1 \ (1) \\ -1 \leq a + b + c \leq 1 \ (2) \\ -1 \leq a - b + c \leq 1 \ (3) \end{cases}$$

(2) និង(3) នាំអោយ

$$\begin{cases} -1 - c \leq a + b \leq 1 - c \\ -1 - c \leq a - b \leq 1 + c \end{cases}$$

ដោយ $a \geq 0; b \geq 0; |c| \leq 1$ នោះ

$$\begin{cases} 0 \leq a + b \leq 2 \\ -2 \leq a - b \leq 2 \end{cases}$$

$$\Rightarrow \begin{cases} a^2 + 2ab + b^2 \leq 4 \\ a^2 - 2ab + b^2 \leq 4 \end{cases}$$

$$\Rightarrow a^2 + b^2 \leq 4 \quad (4)$$

យើងមាន

$$K = \frac{8}{3}(a^2 + b^2) - \frac{2}{3}b^2 \leq \frac{8}{3}(a^2 + b^2) \leq \frac{8}{3}.4 = \frac{32}{3}$$

K មានតំលៃធំបំផុតពេល $b = 0; a^2 + b^2 = 4 \Rightarrow b = 0; a = \pm 2$ ។

បើ $b = 0; a = 2; (2) \Rightarrow c = -1$ ។

បើ $b = 0; a = -2; (2) \Rightarrow c = 1$ ។

ដូច្នេះ $(a, b, c) = \{(2; 0; -1); (-2; 0; 1)\}$ ។

177. ▲ សន្មតថា $a_1 \leq a_2 \leq a_3 \leq a_4 \leq a_5$ ។ សន្មតថា $\min_{i \neq j}(a_i - a_j)^2 > \frac{1}{100}$ នោះ

$$a_2 - a_1 > \frac{1}{10} \ \Rightarrow a_2 > \frac{1}{10}$$
$$a_3 - a_2 > \frac{1}{10} \ \Rightarrow a_3 > \frac{2}{10}$$
$$a_4 - a_3 > \frac{1}{10} \ \Rightarrow a_4 > \frac{3}{10}$$
$$a_5 - a_4 > \frac{1}{10} \ \Rightarrow a_2 > \frac{4}{10}$$
$$\Rightarrow a_1 + a_2 + a_3 + a_4 + a_5 > \frac{1+2+3+4}{10} = 1$$

មិនត្រឹមត្រូវ។

សន្មតថា $\min_{i \neq j} \left|a_i^2 - a_j^2\right| > \frac{1}{36}$ នោះ

$$a_2^2 - a_1^2 > \frac{1}{36} \ \Rightarrow a_2 > \frac{1}{6}$$
$$a_3^2 - a_2^2 > \frac{1}{36} \ \Rightarrow a_3 > \frac{\sqrt{2}}{6}$$
$$a_4^2 - a_3^2 > \frac{1}{36} \ \Rightarrow a_4 > \frac{\sqrt{3}}{6}$$
$$a_5^2 - a_4^2 > \frac{1}{36} \ \Rightarrow a_5 > \frac{\sqrt{4}}{6}$$
$$\Rightarrow a_1 + a_2 + a_3 + a_4 + a_5 > \frac{1+\sqrt{2}+\sqrt{3}+\sqrt{4}}{10} > 1$$

មិនត្រឹមត្រូវ។

178. ▲ ❶ ដំនោះស្រាយទី១

យើងមាន

$$\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b} = \frac{2a}{(b+c)+(b+c)} + \frac{2b}{(c+a)+(c+a)} + \frac{2c}{(a+b)+(a+b)}$$
$$< \frac{2a}{a+(b+c)} + \frac{2b}{b+(c+a)} + \frac{2c}{c+(a+b)} = 2$$

❷ ដំនោះស្រាយទី២

តាង $a = x+y; b = y+z; c = z+x$។

$$a+b > c \ \Leftrightarrow x+y+y+z > z+x \ \Rightarrow y > 0$$
$$a+c > b \ \Leftrightarrow x+y+z+x > y+z \ \Rightarrow x > 0$$
$$b+c > a \ \Leftrightarrow y+z+z+x > x+y \ \Rightarrow z > 0$$

ដូច្នេះ យើងបំលែង លក្ខខណ្ឌ a, b, c ជារង្វាស់ជ្រុងត្រីកោណមក $x, y, z > 0$ ។

យើងមាន

$$\frac{x+y}{y+z+z+x} + \frac{y+z}{z+x+x+y} + \frac{z+x}{x+y+y+z} < \frac{x+y}{y+z+x} + \frac{y+z}{z+x+y} + \frac{z+x}{x+y+z} = 2$$

ពិត។

179. ▲ តាង $a = x + y; b = y + z; c = z + x$ នោះ $x; y; z > 0$ ។

វិសមភាពខាងឆ្វេងសមមូលនឹង

$$
\begin{aligned}
&(a+b+c)^2 \geq 3(ab+bc+ca) \\
\Leftrightarrow\quad &4(x+y+z)^2 \geq 3[(x+y)(y+z)+(y+z)(z+x)+(z+x)(x+y)] \\
\Leftrightarrow\quad &x^2+y^2+z^2 \geq xy+yz+zx \\
\Leftrightarrow\quad &\frac{1}{2}[(x-y)^2+(y-z)^2+(z-x)^2] \geq 0
\end{aligned}
$$

ពិត។ អង្គទាំងពីរស្មើគ្នាពេល $x = y = z$ មានន័យថា $a = b = c$ ។

ដូចគ្នាវិសមភាពខាងស្ដាំសមមូលនឹង $xy + yz + zx > 0$ ពិត ព្រោះ $x, y, z > 0$ ។

180. ▲ យើងមាន

$$
\begin{aligned}
&a^2+b^2 > 2ab \\
&a+b > c \quad \Rightarrow a^2+b^2+2ab > c^2 \\
\Rightarrow\quad &a^2+b^2+(a^2+b^2) > a^2+b^2+2ab > c^2 \\
\Rightarrow\ &2a^2+2b^2-c^2 > 0
\end{aligned}
$$

ដូចគ្នាយើងទាញបាន

$$
\begin{aligned}
2b^2+2c^2-a^2 > 0 \\
2c^2+2a^2-b^2 > 0
\end{aligned}
$$

យើងនឹងបង្ហាញថា

$$(2a^2+2b^2-c^2)(2c^2+2a^2-b^2) \leq (2a^2+bc)^2$$

យើងមាន

$$
\begin{aligned}
&(2a^2+bc)^2-(2a^2+2b^2-c^2)(2c^2+2a^2-b^2) \\
&= 4a^2bc-2a^2(b^2+c^2)-4b^2c^2+2b^4+2c^4 \\
&= 2(b^2-c^2)^2-2a^2(b-c)^2 \\
&= 2(b-c)^2(b+c+a)(b+c-a) \geq 0
\end{aligned}
$$

ដូចគ្នាយើងទាញបាន

$$
\begin{aligned}
0 < (2a^2+2b^2-c^2)(2c^2+2a^2-b^2) \leq (2a^2+bc)^2 \\
0 < (2b^2+2c^2-a^2)(2a^2+2b^2-c^2) \leq (2b^2+ac)^2 \\
0 < (2c^2+2a^2-b^2)(2b^2+2c^2-a^2) \leq (2c^2+ab)^2
\end{aligned}
$$

គុណអង្គនឹងអង្គយើងទាញបានវិសមភាព។ អង្គទាំងពីរស្មើគ្នាពេល $a = b = c$ ។

181. ▲យើងទាញបាន

$$
\begin{aligned}
&a \geq 0; b^2-4ac \leq 0 \ \Rightarrow b^2 \leq 4ac = 4.2a.\frac{c}{2} \leq \left(2a+\frac{c}{2}\right)^2 \\
&\Rightarrow 2b \leq 4a+c \\
&\Rightarrow 2b-4a \leq c \\
&\Rightarrow 3b-3a \leq a+b+c
\end{aligned}
$$

$$\Longrightarrow \frac{a+b+c}{b-a} \geq 3$$
$$\Longrightarrow \min F = 3$$

182. ▲ យើងមាន

$$S = bc\sin\frac{\alpha}{2}$$
$$a^2 = b^2 + c^2 - 2bc\cos\alpha$$
$$\frac{\sqrt{3}\sin\alpha + \cos\alpha}{2} = \cos(\alpha - 60^\circ)$$

យើងមាន

$$a^2 + b^2 + c^2 \geq 4S\sqrt{3} \Leftrightarrow b^2 + c^2 \geq bc\left(\sqrt{3}\sin\alpha + \cos\alpha\right)$$
$$\Leftrightarrow (b-c)^2 + 2bc(1 - \cos(\alpha - 60^\circ)) \geq 0$$

យើងមានសមភាពទាល់តែ $b = c$ និង $\alpha = 60^\circ$ មានន័យថា ត្រីកោណជាត្រីកោណសម័ង្ស។

183. ▲ សន្មតថា $a \geq 0; c \geq 0; 4ac \geq b^2$ ។ បើ $a = 0$ នោះ $b = 0$ ហើយវិសមភាពទៅជា $cg^2 \geq 0$ ។ បើ $a > 0$ នោះ

$$af^2 + bfg + cg^2 = a\left(f + \frac{b}{2a}g\right)^2 + \frac{4ac - b^2}{4a}g^2 \geq 0$$

ឥលូវយើងសន្មតថា $af^2 + bfg + cg^2 \geq 0$ ចំពោះគ្រប់គូវ៉ិចទ័រ f, g ។ ជំនួស f ដោយ tg $(t \in \mathbb{R})$ យើងទាញបាន $(at^2 + bt + c)g^2 \geq 0$ ពិតចំពោះគ្រប់ចំនួនពិត t ដូច្នេះនាំអោយ $a \geq 0, c \geq 0, 4ac \geq b^2$។

184. ▲យើងមាន

$$-a_i = \sum_{j=1;j\neq i}^{n} a_j$$
$$n\,|a_i| = |(n-1)a_i - (-a_i)| = \left|\sum_{j=1;j\neq i}^{n}\left(a_i - a_j\right)\right|$$
$$= \left|\sum_{i\neq j}\left(a_i - a_j\right)\right| \leq \sum_{i\neq j}\left|a_i - a_j\right|$$
$$\Longrightarrow \quad n\sum_{i=1}^{n}|a_i| \leq 2\sum_{i<j}\left|a_i - a_j\right|$$

$\Longrightarrow$ វិសមភាពពិត។

ចំពោះ $a_1 = a_2 = \cdots = a_{n-1} = x$ និង $a_n = -(n-1)x$ យើងទាញបានអង្គទាំង២ស្មើគ្នា។ ដូច្នេះ វិសមភាពជាវិសមភាពតូចជាងឬស្មើ។

185. ▲ ❶ ដំណោះស្រាយទី១

ជាដំបូងយើងសន្មតថា កត្តានិមួយៗនៃអង្គខាងស្តាំរបស់វិសមភាពមានតម្លៃវិជ្ជមានឬសូន្យ។

យើងមាន

$$
\begin{aligned}
b-1+\frac{1}{c} &= b\left(1-\frac{1}{b}+\frac{1}{bc}\right) = b\left(1-\frac{1}{b}+a\right) \\
\Rightarrow \left(a-1+\frac{1}{b}\right)\left(b-1+\frac{1}{c}\right) &= b\left[a-\left(1-\frac{1}{b}\right)\right]\left[a+\left(1-\frac{1}{b}\right)\right] \\
&= b\left[a^2-\left(1-\frac{1}{b}\right)^2\right] \\
&\le ba^2
\end{aligned}
$$

ដូចគ្នា យើងទាញបាន

$$
\begin{aligned}
\left(b-1+\frac{1}{c}\right)\left(c-1+\frac{1}{a}\right) &\le cb^2 \\
\left(a-1+\frac{1}{b}\right)\left(c-1+\frac{1}{a}\right) &\le ac^2 \\
\Rightarrow \left[\left(a-1+\frac{1}{b}\right)\left(b-1+\frac{1}{c}\right)\left(c-1+\frac{1}{a}\right)\right]^2 &\le (abc)^2 = 1
\end{aligned}
$$

ពិត។

ករណីមានកត្តាណាមួយអវិជ្ជមាន ឧទាហរណ៍ $a-1+\frac{1}{b}<0$ នោះ $a<1$ ហើយ $b>1$។ ក្នុងករណីនេះ $b-1+\frac{1}{c}>0$ និង $c-1+\frac{1}{a}>0$ ។ ដូច្នេះបើមានកត្តាណាមួយអវិជ្ជមាន នោះ មានតែកត្តាមួយនោះប៉ុណ្ណោះ ដែលអវិជ្ជមាន ដូច្នេះផលគុណនៃកត្តាទាំងបីនេះអវិជ្ជមាន ដូច្នេះតូចជាង១។

❷ ដំណោះស្រាយទី២

វិសមភាពដែលឱ្យសមមូលនឹង

$$
\left(a-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{b}\right)\left(b-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{c}\right)\left(c-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{a}\right)\le abc
$$

ជំនួស $a=x^3; b=y^3; c=z^3$ ដែល $x,y,z>0$ យើងទាញបាន

$$
\begin{aligned}
&\left(x^3-xyz+\frac{(xyz)^2}{y^3}\right)\left(y^3-xyz+\frac{(xyz)^2}{z^3}\right)\left(z^3-xyz+\frac{(xyz)^2}{x^3}\right)\le x^3y^3z^3 \\
&\Leftrightarrow\ (x^2y-y^2z+z^2x)(y^2z-z^2x+x^2y)(z^2x-x^2y+y^2z)\le x^3y^3z^3 \\
&\Leftrightarrow\ 3x^3y^3z^3+\sum_{cyclic}x^6y^3\ge\sum_{cyclic}x^4y^4z+\sum_{cyclic}x^5y^2z^2
\end{aligned}
$$

$$\Leftrightarrow \quad 3(x^2y)(y^2z)(z^2x) + \sum_{cyclic}(x^2y)^3 \geq \sum_{sym}(x^2y)^2(y^2z)$$

តាង $u = x^2y; v = y^2z; w = z^2x$ ។ យើងមាន $u, v, w > 0$

$$\Rightarrow \quad 3uvw + \sum_{cyclic} u^3 \geq \sum_{sym} u^2v$$

$$\Leftrightarrow \quad \sum_{cyclic} u(u-v)(u-w) \geq 0$$

ពិត តាមវិសមភាព Schur ។

186.▲ ដោយប្រើលក្ខខណ្ឌ $a + b = 1$ យើងបំលែងវិសមភាពដែលអោយទៅជាវិសមភាពអូម៉ូសែន

$$\frac{1}{3} \leq \frac{a^2}{(a+b)(a+(a+b))} + \frac{b^2}{(a+b)\big(b+(a+b)\big)} \Leftrightarrow a^2b + ab^2 \leq a^3 + b^3$$

$$\Leftrightarrow (a-b)^2(a+b) \geq 0$$

ពិត។ សមភាពកើតមាន ពេល $a = b = 1/2$ ។

187.

188. ▲ដោយ $0 < x < 1$ នោះវិសមភាពដែលឲ្យអាចសរសេរជា

$$\left(1+\frac{1}{x}\right)\left(1+\frac{1}{1-x}\right) \geq 9$$

$$(x+1)(1-x+1) \geq 9x(1-x)$$

$$2 + x - x^2 \geq 9x - 9x^2$$

$$(2x-1)^2 \geq 0$$

ពិត។

189. ▲ យើងមាន

$$\frac{a^6}{b^6} + \frac{a^4}{b^4} + \frac{a^2}{b^2} + \frac{b^6}{a^6} + \frac{b^4}{a^4} + \frac{b^2}{a^2} = \left(\frac{a^6}{b^6} + \frac{b^6}{a^6}\right) + \left(\frac{a^4}{b^4} + \frac{b^4}{a^4}\right) + \left(\frac{a^2}{b^2} + \frac{b^2}{a^2}\right)$$

$$\geq 2 + 2 + 2 = 6$$

អង្គទាំង២ស្មើគ្នា លុះត្រាតែ $a = b$ ។

190. ▲ យើងមាន

$$\frac{x}{x^4 + y^2} + \frac{y}{x^2 + y^4} \leq \frac{x}{2\sqrt{x^4y^2}} + \frac{y}{2\sqrt{x^2y^4}}$$

$$\leq \frac{x}{2x^2y} + \frac{y}{2xy^2} = \frac{1}{xy}$$

191. ▲ យើងមាន

$$0 \le \left(x-\sqrt{y^2+1}\right)^2+\left(y-\sqrt{x^2+1}\right)^2$$
$$\Longrightarrow x^2+y^2+1 \ge x\sqrt{y^2+1}+y\sqrt{x^2+1}$$

អង្គទាំង២ស្មើគ្នា បើ

$$\begin{cases} x=\sqrt{y^2+1} \\ y=\sqrt{x^2+1} \end{cases}$$

$\Longrightarrow x^2+y^2=x^2+y^2+2$ មិនអាច។ ដូច្នេះអង្គទី១ធំជាងអង្គទី២ដាច់ខាត មានន័យថា

$$x^2+y^2+1 > x\sqrt{y^2+1}+y\sqrt{x^2+1}$$

192. ▲ យើងមាន

$$\frac{x^2}{y^2}+\frac{y^2}{z^2}+\frac{z^2}{x^2} \ge \frac{x}{z}+\frac{y}{x}+\frac{z}{y}$$

$$\Leftrightarrow \left(\frac{x}{y}\right)^2-2\frac{x}{z}+\left(\frac{y}{z}\right)^2+\left(\frac{y}{z}\right)^2-2\frac{y}{x}+\left(\frac{z}{x}\right)^2+\left(\frac{z}{x}\right)^2-2\frac{z}{y}+\left(\frac{x}{y}\right)^2 \ge 0$$

$$\Leftrightarrow \left(\frac{x}{y}-\frac{y}{z}\right)^2+\left(\frac{y}{z}-\frac{z}{x}\right)^2+\left(\frac{z}{x}-\frac{x}{y}\right)^2 \ge 0$$

ពិតជានិច្ច។ អង្គទាំង២ស្មើគ្នា មានតែ$x = y = z$ ។

193. ▲តាង $a=x+y, b=y+z, c=z+x$ នោះ $x,y,z>0$ ។

វិសមភាពសមមូលនឹង

$$(x+2y+z)(x+y+2z)(2x+y+z) \ge 64xyz$$

យើងមាន

$$\begin{aligned} x+2y+z &= (x+y)+(y+z) \\ &\ge 2\sqrt{xy}+2\sqrt{yz} \\ &\ge 4(xy^2z)^{1/4} \end{aligned}$$

ដូចគ្នា

$$x+y+2z \ge 4(xyz^2)^{\frac{1}{4}}$$
$$2x+y+z \ge 4(x^2yz)^{1/4}$$

ដូច្នេះ

$$(x+2y+z)(x+y+2z)(2x+y+z) \ge 64(xy^2z.xyz^2.x\text{^}2yz)^{\frac{1}{4}}=64xyz$$

ពិត។

194. ▲តាង $a=x+y; b=y+z; c=z+x$ នោះ $a;b;c>0$ ។ យើងមាន

$$\frac{x^2-z^2}{y+z}+\frac{y^2-x^2}{z+x}+\frac{zx^2-y^2}{x+y}=\frac{(a-b)c}{b}+\frac{(b-c)a}{c}+\frac{(c-a)b}{a}$$
$$=\frac{ac}{b}+\frac{ba}{c}+\frac{bc}{a}-a-b-c$$

តែថា

$$\frac{1}{2}\left(\frac{ac}{b}+\frac{ba}{c}\right)=\ a\frac{b^2+c^2}{2bc}\geq a$$

ទៅជាស្មើគ្នា ទាល់តែ $b=c$ ។ ដូចគ្នាដែរ

$$\frac{1}{2}\left(\frac{ac}{b}+\frac{bc}{a}\right)\geq c$$
$$\frac{1}{2}\left(\frac{ba}{c}+\frac{bc}{a}\right)\geq b$$

បូកអង្គនៃវិសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន$\frac{ac}{b}+\frac{ba}{c}+\frac{bc}{a}-a-b-c\geq 0$ ។ ដូច្នេះ វិសមភាពពិត។ សញ្ញាស្មើកើតមានពេល$a=b=c$ មានន័យថា $x=y=z$ ។

195. ▲តាង $x=a+b-c, y=b+c-a, z=c+a-b$ ។

ដូច្នេះ $x,y,z>0$ និង $a=\frac{x+z}{2}, b=\frac{y+x}{2}, c=\frac{z+y}{2}$ ។ យើងមាន

$$2(x+y)=(x+y)+(x+y)\geq x+y+2\sqrt{xy}=\left(\sqrt{x}+\sqrt{y}\right)^2$$
$$\Longrightarrow \sqrt{x}+\sqrt{y}\leq\sqrt{2}.\sqrt{x+y}$$

ដោយអង្គទាំងពីរស្មើគ្នា បើ $x=y$ ។

ដូច្នេះ

$$\sqrt{a+b-c}+\sqrt{b+c-a}=\sqrt{x}+\sqrt{y}\leq\sqrt{2}.\sqrt{x+y}=2\sqrt{b}$$

ដូចគ្នា

$$\sqrt{b+c-a}+\sqrt{c+a-b}\leq 2\sqrt{c}$$
$$\sqrt{c+a-b}+\sqrt{a+b-c}\leq 2\sqrt{a}$$

បូកអង្គនឹងអង្គនៃវិសមភាព យើងទាញបានវិសមភាពពិត។

សមភាពកើតមាន លុះត្រាតែ $x=y=z$ មានន័យថា $a=b=c$ ។

196. ▲ ❶ ដំណោះស្រាយទី១

យើងមាន $(a-b)(a^2-b^2)\geq 0 \Longrightarrow a^3+b^3\geq ab(a+b)$ ដោយអង្គទាំងពីរស្មើគ្នា ទាល់តែ និងមានតែ $a=b$ ។ ដូច្នេះ

$$\frac{1}{a^3+b^3+abc}\le\frac{1}{ab(a+b)+abc}=\frac{c}{abc(a+b+c)}$$
$$\frac{1}{b^3+c^3+abc}\le\frac{a}{abc(a+b+c)}$$
$$\frac{1}{c^3+a^3+abc}\le\frac{b}{abc(a+b+c)}$$
ដូច្នេះ
$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{c+b+a}{abc(a+b+c)}=\frac{1}{abc}$$

❷ ដំណោះស្រាយទី២

វិសមភាពនេះសមមូលនឹង
$$\sum_{sym}(a^3+b^3+abc)(b^3+c^3+abc)abc$$
$$\le 2(a^3+b^3+abc)(b^3+c^3+abc)(c^3+a^3+abc)$$
$$\Leftrightarrow\ \sum_{sym}(a^7bc+3a^4b^4c+4a^5b^2c^2+a^3b^3c^3)$$
$$\le\sum_{sym}(a^3b^3c^3+2a^6b^3+3a^4b^4c+a^7bc+2a^5b^2c^2)$$
$$\Leftrightarrow\ \sum_{sym}(2a^6b^3-2a^5b^2c^2)\ \ge 0$$
$$\Leftrightarrow\ \sum_{sym}a^6b^3c^0\ge\sum_{sym}a^5b^2c^2$$
ពិតតាមវិសមភាព Muirhead ព្រោះ $(6;3;0)$លុបលើ $(5;2;2)$។ ស្អីត$(6;3;0)$លុបលើ $(5;2;2)$ ព្រោះ $6>5; 6+3=9>5+2=7; 6+3+0=5+2+2$ ។

197. ▲ យើងមាន
$$\begin{aligned}a^5+b^5&=(a+b)(a^4-a^3b+a^2b^2-ab^3+b^4)\\&=(a+b)[(a-b)(a^3-b^3)+a^2b^2]\\&\ge(a+b)a^2b^2\end{aligned}$$
ព្រោះ $(a-b)(a^3-b^3)\ge 0$ ។
$$\Rightarrow\frac{ab}{a^5+b^5+ab}\le\frac{ab}{(a+b)a^2b^2+ab}$$
$$=\frac{1}{ab(a+b)+1}$$

$$= \frac{1}{ab(a+b)+abc}$$
$$= \frac{1}{ab(a+b+c)}$$
$$= \frac{c}{a+b+c}$$

តាមរបៀបដូចគ្នា ចំពោះតួផ្សេងទៀត។ យើងទាញបាន

$$\frac{ab}{a^5+b^5+ab}+\frac{bc}{b^5+c^5+bc}+\frac{ca}{c^5+a^5+ca} \le \frac{c}{a+b+c}+\frac{a}{a+b+c}+\frac{b}{a+b+c} = 1$$

សមភាពកើតមានពេល $a=b=c$ ។

198.▲ តាង

$$A = \left(\sum_{i=1}^{n} a_i^2\right)\left(\sum_{i=1}^{n} b_i^2\right)$$
$$B = \left(\sum_{i=1}^{n} a_i b_i\right)^2$$
$$A - B = \sum_{i=1}^{n} a_i^2 b_i^2 + \sum_{i\neq j} a_i^2 b_j^2 - \left[\sum_{i=1}^{n} a_i^2 b_i^2 + 2\sum_{1\le i<j\le n} a_i b_i a_j b_j\right]$$
$$= \sum_{i\neq j} a_i^2 b_j^2 - 2\sum_{1\le i<j\le n} a_i b_i a_j b_j$$
$$= \left[\sum_{1\le i<j\le n} a_i^2 b_j^2 + \sum_{1\le i<j\le n} a_j^2 b_i^2\right] - 2\sum_{1\le i<j\le n} a_i b_i a_j b_j$$
$$= \sum_{1\le i<j\le n}\left(a_i^2 b_j^2 + a_j^2 b_i^2 - 2a_i b_i a_j b_j\right)$$
$$= \sum_{1\le i<j\le n}\left(a_i b_j - a_j b_i\right)^2 \ge 0$$

$\Longrightarrow$ សំណើពិត។

199.▲ តាមវិសមភាពកូស៊ី– ស្វាត

$$(x_1+x_2+\cdots+x_n)\left(\frac{1}{x_1}+\frac{1}{x_2}+\cdots+\frac{1}{x_n}\right) \ge \left(\sum_{i=1}^{n}\sqrt{x_i}.\frac{1}{\sqrt{x_i}}\right)^2 = n^2$$

200.▲ តាមវិសមភាពកូស៊ីស្វាត

$$(a+b+b+c+c+c)^2 \le (1+1+1+1+1+1)(a^2+b^2+b^2+c^2+c^2+c^2)$$

$$\Rightarrow \frac{(a+2b+3c)^2}{a^2+2b^2+3c^2} \le 6$$

201.▲ តាមវិសមភាពកូស៊ីស្វាត

$$\Rightarrow 3\left[\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2\right] \ge \left[\left(a+\frac{1}{a}\right)+\left(b+\frac{1}{b}\right)+\left(c+\frac{1}{c}\right)\right]^2$$

$$= \left(a+b+c+\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)\right)^2 = \left(1+\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)\right)^2$$

$$\ge \left(1+\frac{3}{(abc)^{\frac{1}{3}}}\right)^2 \quad \text{តាមវិសមភាពកូស៊ី}$$

$$\ge \left(1+\frac{9}{a+b+c}\right)^2 \quad \text{តាមវិសមភាពកូស៊ី}$$

$$= (1+9)^2 = 100$$

$$\Rightarrow \left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2 \ge \frac{100}{3}$$

202.▲ តាមវិសមភាពកូស៊ី– ស្វាត

$$\begin{aligned}(a+b+c+d)^2 &\le (1+1+1+1)(a^2+b^2+c^2+d^2)\\ &= 4(a^2+b^2+c^2+d^2)\end{aligned}$$

$$\Rightarrow \quad (8-e)^2 \le 4(16-e^2)$$

$$\Rightarrow \quad e(5e-16) \le 0$$

$$\Rightarrow \quad 0 \le e \le \frac{16}{5}$$

ដើម្បីឱ្យ $e = 16/5$ លក្ខខណ្ឌគឺ $a=b=c=d$ និង $a+b+c+d = 24/5 \Rightarrow a=b=c=d = 6/5$។

203.▲ ❶ តាមវិសមភាពកូស៊ី– ស្វាត យើងមាន

$$\left(\sum_{i=1}^{n}\frac{s}{s-a_i}\right)\left(\sum_{i=1}^{n}\frac{s-a_i}{s}\right) \ge n^2$$

យើងមាន

$$\sum_{i=1}^{n}\frac{s-a_i}{s} = \sum_{i=1}^{n}1-\frac{1}{s}\sum_{i=1}^{n}a_i = n-1 \ \Rightarrow\ \left(\sum_{i=1}^{n}\frac{s}{s-a_i}\right) \ge \frac{n^2}{n-1} \qquad \text{ពិត។}$$

❷ ម្យ៉ាងវិញទៀត

$$\sum_{i=1}^{n}\frac{s-a_i}{a_i}=-n+\sum_{i=1}^{n}\frac{s}{a_i}\quad(*)$$

តាមវិសមភាពកូស៊ី–ស្វាត

$$\left(\sum_{i=1}^{n}\frac{s}{a_i}\right)\left(\sum_{i=1}^{n}\frac{a_i}{s}\right)\geq n^2$$

ដោយ

$$\left(\sum_{i=1}^{n}a_i/s\right)=1\ \Rightarrow\left(\sum_{i=1}^{n}\frac{s}{a_i}\right)\geq n^2\,;(*)\ \Rightarrow\sum_{i=1}^{n}\frac{s-a_i}{a_i}\geq -n+n^2=n(n-1)$$

ពិត។

❸ យើងមាន

$$\left(\sum_{i=1}^{n}1\right)\left(\sum_{i=1}^{n}a_i^2\right)\geq\left(\sum_{i=1}^{n}a_i\right)^2\Rightarrow\left(\sum_{i=1}^{n}a_i^2\right)\geq\frac{s^2}{n}$$

តែថា

$$\left(\sum_{i=1}^{n}[a_i(s-a_i)]\right)\left(\sum_{i=1}^{n}\frac{a_i}{s-a_i}\right)\geq\left(\sum_{i=1}^{n}a_i\right)^2=s^2$$

$$\Rightarrow\quad\left(\sum_{i=1}^{n}\frac{a_i}{s-a_i}\right)\geq\frac{s^2}{\left(\sum_{i=1}^{n}[a_i(s-a_i)]\right)}=\frac{s^2}{s\sum_{i=1}^{n}a_i-\sum_{i=1}^{n}a_i^2}$$

$$\geq\frac{s^2}{s^2-\frac{s^2}{n}}=\frac{n}{n-1}$$

ពិត។

204.▲ ក) សំនួរនេះគ្មានលក្ខណៈពិសេសណាលើលំដាប់ $a_1;a_2;a_3$ ទេ មានន័យថា បើយើងផ្លាស់ a_1 ទៅ a_2; a_2 ទៅ a_1 ។ល។នោះសម្មតិកម្មនៅដដែលគ្មានប្រែប្រួល។ តាមលក្ខណៈនេះ យើងអាចសន្មតថា $a_1\leq a_2\leq a_3$ ។ ដូច្នេះ យើងគ្រាន់តែបង្ហាញថា $a_1+a_2>a_3$ ទៅបានហើយ។ យើងមាន

$$(a_1^2+a_2^2+a_3^2)^2>2(a_1^4+a_2^4+a_3^4)$$
$$\Leftrightarrow\quad(a_1+a_2+a_3)(a_1+a_2-a_3)(-a_1+a_2+a_3)(a_1-a_2+a_3)>0$$

កត្តានិមួយៗសុទ្ធតែវិជ្ជមាន លើកលែងតែ$(a_1+a_2-a_3)$ដែលមិនទាន់ដឹង។ តែ ផលគុណរបស់កត្តាទាំងអស់វិជ្ជមាន ដូច្នេះ$(a_1+a_2-a_3)$ ត្រូវតែវិជ្ជមាន។

ខ) ករណី $n=3$ បានស្រាយបញ្ជាក់រួចក្នុងសំនួរក)។ យើងសន្មតថា $n\geq 4$ ។

តាមដូចរៀបរាប់ក្នុងសំនួរក) យើងគ្រាន់តែបង្ហាញថា $a_1; a_2; a_3$ ជារង្វាស់ជ្រុងនៃត្រីកោណ ជាការគ្រប់គ្រាន់ហើយ។

តាមវិសមភាពកូស៊ី– ស្វាត

$$\begin{aligned}&(n-1)(a_1^4+a_2^4+\cdots+a_n^4) < (a_1^2+a_2^2+\cdots+a_n^2)^2\\ &=\left(\frac{a_1^2+a_2^2+a_3^2}{2}+\frac{a_1^2+a_2^2+a_3^2}{2}+\sum_{k=4}^{n}a_k^2\right)^2\\ &\le (n-1)\left(\frac{(a_1^2+a_2^2+a_3^2)^2}{4}+\frac{(a_1^2+a_2^2+a_3^2)^2}{4}+\sum_{k=4}^{n}a_k^4\right)\end{aligned}$$

$\Leftrightarrow\ 2(a_1^4+a_2^4+a_3^4) < (a_1^2+a_2^2+a_3^2)^2$ ហើយតាម សំនួរ ក) យើងទាញបានថាសំនើពិត។

205.▲ តាមវិសមភាពកូស៊ី– ស្វាត ចំពោះគ្រប់ i យើងមាន

$$\begin{aligned}S_2-a_i^2 &= a_1^2+a_2^2+\cdots+a_{i-1}^2+a_{i+1}^2+\cdots+a_n^2\\ &\ge \frac{1}{n-1}(a_1+a_2+\cdots+a_{i-1}+a_{i+1}+\cdots+a_n)^2=\frac{1}{n-1}(S_1-a_i)^2\end{aligned}$$

$$\Leftrightarrow \frac{S_2-a_i^2}{S_1-a_i}\ge\frac{1}{n-1}(S_1-a_i)$$

$$\Rightarrow\ \sum_{k=1}^{n}\frac{S_2-a_i^2}{S_1-a_i}\ge\frac{1}{n-1}\sum_{k=1}^{n}(S_1-a_k)=S_1$$

206.▲ តាង $E=\{(a,b,c,d)\in\mathbb{R}^+/a^2+b^2=(c^2+d^2)^3\}$ និង f ជាអនុគមន៍ កំនត់លើ E ដោយ

$$f(a,b,c,d)=\frac{c^3}{a}+\frac{d^3}{b}-1$$

យើងឃើញថា ចំពោះ $\forall\lambda\in\mathbb{R}^+ : (a,b,c,d)\in E$ និង $f(a,b,c,d)\ge 0$

$$\begin{aligned}a^2+b^2=(c^2+d^2)^3 &\Leftrightarrow (\lambda^3a)^2+(\lambda^3b)^2=[(\lambda c)^2+(\lambda d)^2]^3\\ &\Leftrightarrow a_1^3+b_1^3=(c_1^2+d_1^2)^3\end{aligned}$$

$$\begin{aligned}&f(a,b,c,d)=\frac{c^3}{a}+\frac{d^3}{b}-1=\frac{(\lambda c)^3}{\lambda^3a}+\frac{(\lambda d)^3}{\lambda^3b}-1=f(\lambda^3a,\lambda^3b,\lambda c,\lambda d)\\ &=f(a_1,b_1,c_1,d_1)\end{aligned}$$

នោះ $(a_1=\lambda^3a, b_1=\lambda^3b, c_1=\lambda c, d_1=\lambda d)\in E$ និង

$f(a,b,c,d)\ge 0\ \Leftrightarrow f(a_1,b_1,c_1,d_1)\ge 0$ ។ លក្ខណៈខាងលើនេះពិតចំពោះ$\forall\lambda\in\mathbb{R}^+$ ដូច្នេះយើងអាចជ្រើសរើសយក λ ដែលផ្ទៀងផ្ទាត់ $a_1^2+b_1^2=1$ ។ តែយើងអាចជំនួសសំនេរ a_1,b_1,c_1,d_1

ដោយ a,b,c,d ដោយគ្មានបញ្ហាអ្វីទាំងអស់។ ដូច្នេះ មានន័យថាយើងអាចយក $(a,b,c,d)\in E$ និង $a^2+b^2=1$ ដោយមិនធ្វើអោយបាត់ភាពទូទៅឡើយ។ ដូច្នេះ $c^2+d^2=1$ ។

តាមវិសមភាពកូស៊ី– ស្វាត នាំអោយ

$$\left(\frac{c^3}{a}+\frac{d^3}{b}\right)(ac+bd)\geq (c^2+d^2)^2=1$$

តែយើងមាន

$$ac+bd\leq\frac{a^2+c^2}{2}+\frac{b^2+d^2}{2}=\frac{1}{2}(a^2+b^2+c^2+d^2)=1$$

$$\Longrightarrow\quad \frac{c^3}{a}+\frac{d^3}{b}\geq\frac{1}{ac+bd}\geq 1$$

207.▲ តាមវិសមភាពកូស៊ី– ស្វាត

$$\left(\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\right)^2\leq(x+y+z)\left(\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}\right)$$

$$\Leftrightarrow\ \sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\leq\sqrt{x+y+z}\ \sqrt{\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}}$$

យើងមាន

$$\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}=3-\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)=1$$

ដូច្នេះ

$$\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\leq\sqrt{x+y+z}\ \sqrt{\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}}=\sqrt{x+y+z}$$

វិសមភាពពិត។

យើងមានសមភាព លុះត្រាតែ

$$\frac{x-1}{x^2}=\frac{z-1}{z^2}=\frac{z-1}{z^2};\frac{1}{x}+\frac{1}{y}+\frac{1}{z}=2\ \Longrightarrow x=y=z=\frac{3}{2}$$

208.▲ តាង $a=1/x\,;b=1/y\,;c=1/z$ ។ លក្ខខណ្ឌ

$$xyz\geq xy+yz+zx\ \Leftrightarrow\frac{1}{x}+\frac{1}{y}+\frac{1}{z}\leq 1\ \ \Longrightarrow a+b+c\leq 1$$

វិសមភាព

$$xyz\geq 3(x+y+z)\ \ \Leftrightarrow ab+bc+ca\leq\frac{1}{3}$$

យើងមាន

$$1 \geq (a+b+c)^2 = a^2+b^2+c^2+2(ab+bc+ca)$$

ហើយតាមវិសមភាពកូស៊ី– ស្វាត យើងមាន

$$ab+bc+ca \leq \sqrt{a^2+b^2+c^2}\sqrt{b^2+c^2+a^2} \Longrightarrow \; a^2+b^2+c^2 \geq ab+bc+ca$$

ដូច្នេះ នាំអោយ $1 \geq 3(ab+bc+ca)$ ពិត។

209.▲ តាង $a = \tan x\,; b = \tan y\,; c = \tan z$ នោះ x, y, z ជាមុំនៃត្រីកោណស្រួច។ ដូច្នេះ វិសមភាពសមមូលនឹង $\max(\tan x\,, \tan y\,, \tan z) \geq \sqrt{3}$ ។ តែថា មានមុំមួយរបស់ត្រីកោណ ឧទាហរណ៍ x ដែលធំជាងរឺស្មើ $\pi/3$ (បើ តូចជាង$\pi/3$ ទាំងអស់គ្នា នោះ ផលបូកមុំក្នុងត្រីកោណ មានតំលៃតូចជាង π)។ ដោយអនុគមន៍ tan កើនលើ $[0, \pi/2)$ នោះ $\tan x \geq \tan\frac{\pi}{3} = \sqrt{3}$ ។

210.▲ យើងមាន

$$\begin{aligned}
&(x_1+x_2+\cdots+x_n)^4 = [(x_1^2+x_2^2+\cdots+x_n^2)+(2x_1x_2+2x_1x_3+\cdots)]^2 \\
&\geq 4(x_1^2+x_2^2+\cdots+x_n^2)(2x_1x_2+2x_1x_3+\cdots) \quad (\text{វិសមភាពកូស៊ី}) \quad (1) \\
&= 8\,(x_1^2+x_2^2+\cdots+x_n^2)\left(\sum_{i<j} x_i x_j\right) \\
&= 8\sum_{i<j}\left[x_i x_j\,(x_1^2+x_2^2+\cdots+x_n^2)\right] \\
&\geq 8\sum_{i<j}\left[x_i x_j\left(x_i^2+x_j^2\right)\right] \qquad (2)
\end{aligned}$$

យើងមានសមភាព (2) ទាល់តែនិងមានតែ មានយ៉ាងហោចណាស់ x_i ចំនួន $(n-2)$ដែលស្មើសូន្យ។ ឧទាហរណ៍ $x_3 = \cdots = x_n = 0$ ។ ក្នុងលក្ខខណ្ឌនេះ យើងមានសមភាព(1) ទាល់តែនិងមានតែ $2x_1x_2 = x_1^2 + x_2^2$ មានន័យថា $x_1 = x_2$ ។

ដូច្នេះ $C = 1/8$ ដោយអង្គទាំងពីរស្មើគ្នា ទាល់តែនិងមានតែ មានយ៉ាងហោចណាស់ x_i ចំនួន $(n-2)$ តួ ដែលស្មើសូន្យ ហើយតួពីរទៀតស្មើគ្នា។

211.▲ យើងមាន

$$P^2 = (xy+yz+zt+tx)^2 \leq (x^2+y^2+z^2+t^2)(y^2+z^2+t^2+x^2) = 1$$

ដូច្នេះ $-1 \leq P \leq 1$ ។

បើ $x = z = \frac{1}{2}; y = t = -\frac{1}{2}$ នោះ $x+y+z+t = 0; x^2+y^2+z^2+t^2 = 1$ ។ ហើយ $P = \frac{1}{2}.\left(-\frac{1}{2}\right)+\left(-\frac{1}{2}\right)\left(\frac{1}{2}\right)+\left(\frac{1}{2}\right)\left(-\frac{1}{2}\right)+\left(-\frac{1}{2}\right)\left(\frac{1}{2}\right) = -1$ ។ ដូច្នេះ $P_{\min} = -1$ ។

យើងមាន $P=(x+z)(y+t)=-(y+t)^2\le 0$ ។ បើ $x=y=1/2\,;z=t=-1/2$ នោះ $P=0$ ។ ដូច្នេះ $P_{\max}=0$ ។

ជាសរុប $P_{\min}=-1$ ឧទាហរណ៍ត្រង់ $x=z=1/2\,;y=t=-1/2$ ។

$P_{\max}=0$ ឧទាហរណ៍ត្រង់ $x=y=1/2\,;z=t=-1/2$ ។

212.▲ យើងតាង $x_1=\tan\alpha_1\,,x_2=\sec\alpha_1\tan\alpha_2$ និង

$$x_k=\sec\alpha_1\sec\alpha_2\dots\sec\alpha_{k-1}\tan\alpha_k$$

ដោយ $-\frac{\pi}{2}<\alpha_k<\frac{\pi}{2},1\le k\le n$ ។ យើងគួរកត់សំគាល់ថាការជំនួសនេះព្រោះលំជាប់របស់ $\tan\alpha$ គឺ $(-\infty,\infty)$ និង $\sec\alpha$ ខុសពីសូន្យជានិច្ច។ ដូច្នេះតួទីk របស់អង្គខាងឆ្វេងនៃវិសមភាពស្មើនឹង

$$\frac{\sec\alpha_1\dots\sec\alpha_{k-1}\tan\alpha_k}{1+\tan^2\alpha_1+\cdots+\sec^2\alpha_1\dots\sec^2\alpha_{n-1}\tan^2\alpha_n}$$
$$=\cos\alpha_1\cos\alpha_2\dots\cos\alpha_k\sin\alpha_k$$

ដូច្នេះវិសមភាពដែលអោយសមមូលនឹង

$$\cos\alpha_1\sin\alpha_1+\cos\alpha_1\cos\alpha_2\sin\alpha_2+\cdots+\cos\alpha_1\cos\alpha_2\dots\cos\alpha_n\sin\alpha_n<\sqrt{n}$$
$$\Leftrightarrow c_1s_1+c_1c_2s_2+\cdots+c_1c_2\dots c_ns_n<\sqrt{n}$$

ដែល $c_i=\cos\alpha_i$ និង $s_i=\sin\alpha_i$ ចំពោះ $1\le i\le n$ ។ ចំពោះ$2\le i\le n$ ដោយសារ $c_i^2+s_i^2=\cos^2\alpha_i+\sin^2\alpha_i=1$ យើងទាញបានថា

$$c_1^2c_2^2\dots c_{i-1}^2s_i^2+c_1^2c_2^2\dots c_{i-1}^2c_i^2=c_1^2c_2^2\dots c_{i-1}^2$$
$$\Longrightarrow\ s_1^2+c_1^2s_2^2+\cdots+c_1^2s_2^2\dots c_{n-2}^2s_{n-1}^2+c_1^2s_2^2\dots c_{n-1}^2=1\quad(*)$$

តាម(*) និងតាមវិសមភាពកូស៊ីស្វាត យើងទាញបាន

$$c_1s_1+c_1c_2s_2+\cdots+c_1c_2\dots c_ns_n$$
$$\le\sqrt{s_1^2+c_1^2s_2^2+\cdots+c_1^2c_2^2\dots c_{n-2}^2s_{n-1}^2+c_1^2c_2^2\dots c_{n-1}^2}\cdot\sqrt{c_1^2+c_2^2+\cdots+c_{n-1}^2+c_n^2s_n^2}$$
$$=\sqrt{c_1^2+c_2^2+\cdots+c_{n-1}^2+c_n^2s_n^2}$$
$$=\sqrt{\cos^2\alpha_1+\cos^2\alpha_2+\cdots+\cos^2\alpha_{n-1}+\cos^2\alpha_n\sin^2\alpha_n}\le\sqrt{n}$$

វិសមភាពចុងក្រោយ ក្លាយជាសមភាព នៅពេលដែល

$$\cos\alpha_1=\cos\alpha_2=\cdots=\cos\alpha_{n-1}=\cos\alpha_n\sin\alpha_n=1$$

សមភាពនេះមិនអាចទេ ព្រោះ $\cos\alpha_n\sin\alpha_n=\frac{1}{2}\sin 2\alpha_n<1$។ ដូច្នេះ យើងមានវិសមភាពដាច់ខាត។

213.▲ តាង $a=1/x\,,b=1/y\,,c=1/z$ នោះ $a,b,c\in(0;1)$ និង $a+b+c=2$។ វិសមភាពដែលអោយសមមូលនឹង

$$\sqrt{\frac{1}{a}+\frac{1}{b}+\frac{1}{c}} \geq \sqrt{\frac{1-a}{a}}+\sqrt{\frac{1-b}{b}}+\sqrt{\frac{1-c}{c}}$$

$$\Leftrightarrow \quad \sqrt{\frac{1}{2}(a+b+c)\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)} \geq \sqrt{\frac{\frac{a+b+c}{2}-a}{a}}+\sqrt{\frac{\frac{a+b+c}{2}-b}{b}}+\sqrt{\frac{\frac{a+b+c}{2}-c}{c}}$$

$$\Leftrightarrow \quad \sqrt{(a+b+c)\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)} \geq \sqrt{\frac{b+c-a}{a}}+\sqrt{\frac{c+a-b}{b}}+\sqrt{\frac{a+b-c}{c}}$$

$$\Leftrightarrow [(b+c-a)+(c+a-b)+(a+b-c)]\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$$

$$\geq \left(\sqrt{\frac{b+c-a}{a}}+\sqrt{\frac{c+a-b}{b}}+\sqrt{\frac{a+b-c}{c}}\right)^2$$

ពិត តាមវិសមភាពកូស៊ីស្វាត។

214.▲ ដោយចំនួនចំលាស់នៃលំដាប់ $b_1, b_2, \dots, b_n$ មានចំនួនកំនត់ (ទាំងអស់មាន $n!$ របៀប) នោះមានមួយបែបដែល S មានតំលៃធំបំផុត (ដូចគ្នា តូចបំផុត)។ តាង $i < j$ ជាសន្ទស្សន៍ពីរ, តាង σ ជាចំលាស់នៃ$\{1,2,\dots,n\}$ ហើយសន្មតថា $\sigma(i) > \sigma(j)$ ។ ដូច្នេះ$b_{\sigma(j)} \geq b_{\sigma(i)}$ ព្រោះស្វ៊ីត (b_k) កើន។ តាង σ'ជាចំលាស់នៃ$\{1,2,\dots,n\}$ ដែលដូចគ្នានឹង σ ដែរ តែខុសត្រង់ i, j ដែល $\sigma'(j) = \sigma(i)$ និង $\sigma'(i) = \sigma(j)$។ ដូច្នេះ

$$S_{\sigma'} - S_\sigma = \left(a_j - a_i\right)\left(b_{\sigma(i)} - b_{\sigma(j)}\right)$$

– បើ $a_i < a_j$ និង $b_{\sigma(j)} < b_{\sigma(i)}$ នោះ $S_{\sigma'} > S_\sigma$ មានន័យថា S_σ មិនមែនធំបំផុតទេ

– បើ $a_i = a_j$ រឺ $b_{\sigma(j)} = b_{\sigma(i)}$ នោះ $S_{\sigma'} = S_\sigma$

ដូច្នេះ ជំនួស σ ដោយ σ' ផលបូកមិនថយចុះទេ រឺក៏អាចធំជាងមុន។

បើ $\sigma(1) \neq 1$ ឧទាហរណ៍ $\sigma = \{3;1;2;\dots;n\}\,;\sigma(1) = 3;\ \sigma(2) = 1$។ យើងមានចំលាស់ σ' មួយដែល $\sigma'(1) = 1$ ឧទាហរណ៍ $\sigma' = \{1;3;2;\dots;n\}\,;\sigma'(1) = 1; \sigma'(2) = 3$ ដែលតួទាំងអស់ដូចគ្នានឹង σ លើកលែងតែតួទីមួយនឹងទីពីរចេញ។ តាមលក្ខណៈខាងលើ យើងទាញបាន $S_\sigma \leq S_{\sigma'}$ ។ មានន័យថា រៀប $\sigma = \{3;1;2;\dots;n\}$ ជា $\sigma = \{1;3;2;\dots;n\}$ យើងទាញបាន S_σ ធំជាងមុន។ មានន័យថាផលបូក

$$a_1 b_3 + a_2 b_1 + a_3 b_2 + \cdots + a_n b_n \leq a_1 b_1 + a_2 b_3 + a_3 b_2 + \cdots + a_n b_n$$

បន្ទាប់មកទៀតយើងចាប់ផ្តើម ឆ្លាស់សន្ទស្សន៍ចាប់ពីទី២ទៅ ឧទាហរណ៍ $\sigma = \{1; 3; 2; \dots; n\}$ ។ យើងមាន $\sigma(2) = 3, \sigma(3) = 2$ ។ យើងមានចំលាស់ σ' មួយដែល $\sigma'(2) = 2$ ឧទាហរណ៍ $\sigma' = \{1; 2; 3; \dots; n\}; \sigma'(2) = 2; \sigma'(3) = 3$ ដែលតួទាំងអស់ដូចគ្នា នឹង σ លើកលែងតែតួទីពីរនិងទីបីចេញ។ តាមលក្ខណៈខាងលើ យើងទាញបាន $S_\sigma \le S_{\sigma'}$ ។ មានន័យថា រៀប $\sigma = \{1; 3; 2; \dots; n\}$ ជា $\sigma = \{1; 2; 3; \dots; n\}$ យើងទាញបាន S_σ ធំជាងមុន។ មានន័យថាផលបូក

$$a_1b_1 + a_2b_3 + a_3b_2 + \cdots + a_nb_n \le a_1b_1 + a_2b_2 + a_3b_3 + \cdots + a_nb_n$$

ដូចគ្នា ចំពោះ $i = 3, \dots, n-1$ យើងទាញបាន $\sigma'(i) = i$ ដែលពេលនោះផលបូកមានតំលៃធំ ។
ដូច្នេះផលបូកមានតំលៃធំបំផុត ពេល $\sigma(i) = i$ ។
ស្រាយបញ្ជាក់ដូចគ្នាករណីតូចបំផុត។

215.▲ វិសមភាពសមមូលនឹង

$$\begin{aligned} &\sum_{i=1}^{n}(x_i - y_i)^2 \le \sum_{i=1}^{n}(x_i - z_i)^2 \\ \Leftrightarrow\ &\sum_{i=1}^{n}\left(x_i^2 - 2x_iy_i + y_i^2\right) \le \sum_{i=1}^{n}\left(x_i^2 - 2x_iz_i + z_i^2\right) \\ \Leftrightarrow\ &\sum_{i=1}^{n}\left(-2x_iy_i + y_i^2\right) \le \sum_{i=1}^{n}\left(-2x_iz_i + z_i^2\right) \end{aligned}$$

ដោយ $\sum_{i=1}^{n} y_i^2 = \sum_{i=1}^{n} z_i^2$ នោះវិសមភាពសមមូលនឹង

$$\sum_{i=1}^{n} x_iy_i \ge \sum_{i=1}^{n} x_iz_i$$

វិសមភាពក្រោយនេះពិត តាមវិសមភាពតំរៀប។

216.▲ មាន $x \in (0, \pi/2)$ ។ តាង $a_1 = \sin^3 x; a_2 = \cos^3 x$ និង $b_1 = 1/\cos x; b_2 = 1/\sin x$ ។ យើងឃើញថា បើ $a_1 \le a_2$ នោះ $b_1 \le b_2$ ហើយ បើ $a_1 \ge a_2$ នោះ $b_1 \ge b_2$ ។ ដូច្នេះ តាមវិសមភាពតំរៀប

$$f(x) = a_1b_1 + a_2b_2 \ge a_1b_2 + a_2b_1 = \sin^3 x\frac{1}{\sin x} + \cos^3 x\frac{1}{\cos x} = \sin^2 x + \cos^2 x = 1$$

ម្យ៉ាងវិញទៀត យើងដឹងថា $f(\pi/4) = 1{,}0$ ដូច្នេះ តំលៃតូចបំផុតរបស់ f គឺស្មើ 1 ។

217.▲ ដោយវិសមភាពនេះគ្មានលក្ខណៈពិសេសចំពោះតំរៀប a, b, c យើងអាចសន្មតថា $a \geq b \geq c$ ។ ដូច្នេះ $a^2 \geq b^2 \geq c^2$ និង $ab \geq ac \geq bc$ ។ តាមវិសមភាពតំរៀប យើងទាញបាន

$$a^3 + b^3 + c^3 = a^2 a + b^2 b + c^2 c \geq a^2 b + b^2 c + c^2 a$$
$$a^2 b + b^2 c + c^2 a = (ab)a + (ac)c + (bc)b \geq (ab)c + (ac)b + (bc)a = 3abc$$

218.▲ គេអោយ $n \geq 1$។ តាមវិសមភាពតំរៀប យើងមាន $\sum_{k=1}^{n} \frac{a_k}{k^2}$ មានតំលៃតូចបំផុត ពេល $a_1 \leq a_2 \leq \cdots \leq a_n$ ។

នៅក្នុងលក្ខខណ្ឌបែបនេះ $(a_1 \leq a_2 \leq \cdots \leq a_n)$ ហើយ ដោយសារ $a_1, a_2, \dots, a_n$ ជាចំនួនគត់វិជ្ជមាន ដែលខុសគ្នាពីរៗ នោះ យើងទាញបាន $a_i \geq i$ ចំពោះគ្រប់ i ។

ដូច្នេះ យើងទាញបាន

$$\sum_{k=1}^{n} \frac{a_k}{k^2} \geq \sum_{k=1}^{n} \frac{1}{k}$$

219.▲ ❶ របៀបទីមួយ

យើងរៀប a_i តាមលំដាប់មួយដែល $a_{k(1)} \leq a_{k(2)} \leq \cdots \leq a_{k(n)}$។ ដូច្នេះ

$$\frac{1}{a_{k(1)}} \geq \frac{1}{a_{k(2)}} \geq \cdots \geq \frac{1}{a_{k(n)}}$$

ដូច្នេះតាមវិសមភាពតំរៀប យើងទាញបាន

$$\frac{a_1^2}{a_2} + \frac{a_2^2}{a_3} + \cdots + \frac{a_{n-1}^2}{a_n} + \frac{a_n^2}{a_1} = a_1^2 \frac{1}{a_2} + a_2^2 \frac{1}{a_3} + \cdots + a_n^2 \frac{1}{a_1}$$
$$\geq a_{k(1)}^2 \frac{1}{a_{k(1)}} + a_{k(2)}^2 \frac{1}{a_{k(2)}} + \cdots + a_{k(n)}^2 \frac{1}{a_{k(n)}}$$
$$= a_1 + a_2 + \cdots + a_n$$

❷ របៀបទីពីរ

ចំពោះគ្រប់ $i \in \{1,2, \dots, n\}$ យើងមាន

$$\frac{a_i^2}{a_{i+1}} + a_{i+1} \geq 2a_i$$
$$\Rightarrow \sum_{i=1}^{n} \frac{a_i^2}{a_{i+1}} + \sum_{i=1}^{n} a_{i+1} \geq 2\sum_{i=1}^{n} a_i$$

ដោយយក $a_{n+1} = a_1$

$$\Rightarrow \sum_{i=1}^{n} a_{i+1} = \sum_{i=1}^{n} a_i \Rightarrow \sum_{i=1}^{n} \frac{a_i^2}{a_{i+1}} \geq \sum_{i=1}^{n} a_i$$

220.▲ យើងមាន

$$
\begin{aligned}
&(x^{1999}+y^{1999}+z^{1999})^2\\
&=\left[\sqrt{x^{1998}(py+qz)}.\sqrt{\frac{x^{2000}}{py+qz}}+\sqrt{y^{1998}(pz+qx)}.\sqrt{\frac{y^{2000}}{pz+qx}}\right.\\
&\qquad\left.+\sqrt{z^{1998}(px+qy)}.\sqrt{\frac{z^{2000}}{px+qy}}\right]^2\\
&\le [x^{1998}(py+qz)+y^{1998}(pz+qx)+z^{1998}(px+qy)].\left[\frac{x^{2000}}{py+qz}+\frac{y^{2000}}{pz+qx}+\frac{z^{2000}}{px+qy}\right]\\
&=[p(x^{1998}y+y^{1998}z+z^{1998}x)+q(x^{1998}z+y^{1998}x+z^{1998}y)]\left[\frac{x^{2000}}{py+qz}+\frac{y^{2000}}{pz+qx}\right.\\
&\qquad\left.+\frac{z^{2000}}{px+qy}\right] \qquad (1)
\end{aligned}
$$

យើងមាន

$$x^{1998}y+y^{1998}z+z^{1998}x\le x^{1999}+y^{1999}+z^{1999} \qquad (2)$$

ព្រោះតាមវិសមភាពតំរៀប និងដោយសារ(២)មានលក្ខណៈស៊ីមេទ្រីធៀបនឹង x,y,z ដែលយើងអាចសន្មតថា $x\le y\le z$ បាន នោះ

$$a_1=x^{1998}\le a_2=y^{1998}\le a_3=z^{1998};$$
$$b_1=x\le b_2=y\le b_3=z$$

នោះដោយយក $b_{\sigma(i)}=\{b_2;b_3;b_1\}$ យើងទាញបាន

$$
\begin{aligned}
S_\sigma=\sum_1^3 a_ib_{\sigma(i)}&=x^{1998}y+y^{1998}z+z^{1998}x\le a_1b_1+a_2b_2+a_3b_3\\
&=x^{1999}+y^{1999}+z^{1999}
\end{aligned}
$$

ពិត។ ដូច្នេះវិសមភាព(១)ទៅជា

$$
\begin{aligned}
&(x^{1999}+y^{1999}+z^{1999})^2\\
&\le(p+q)(x^{1999}+y^{1999}+z^{1999})\left[\frac{x^{2000}}{py+qz}+\frac{y^{2000}}{pz+qx}+\frac{z^{2000}}{px+qy}\right]\\
&\Leftrightarrow\ \frac{x^{2000}}{py+qz}+\frac{y^{2000}}{pz+qx}+\frac{z^{2000}}{px+qy}\ge\frac{x^{1999}+y^{1999}+z^{1999}}{p+q}
\end{aligned}
$$

221.▲ តាមវិសមភាពតំរៀប យើងមាន

$$
\begin{aligned}
&a_1b_1+a_2b_2+\cdots+a_nb_n=a_1b_1+a_2b_2+\cdots+a_nb_n\\
&a_1b_1+a_2b_2+\cdots+a_nb_n\ge a_1b_2+a_2b_3+\cdots+a_nb_1\\
&\ldots\\
&a_1b_1+a_2b_2+\cdots+a_nb_n\ge a_1b_n+a_2b_1+\cdots+a_nb_{n-1}
\end{aligned}
$$

បូកអង្គនឹងអង្គ យើងទាញបាន

$$n(a_1b_1 + a_2b_2 + \cdots + a_nb_n) \geq (a_1 + a_2 + \cdots + a_n)(b_1 + b_2 + \cdots + b_n)$$

$\Longrightarrow$ វិសមភាពពិត។

ស្រាយបញ្ជាក់ដូចគ្នាករណីស៊ីត (b_n) រៀបតាមលំដាប់ច្រាសមកវិញ។

222.▲ ❶ របៀបទី១

តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $a \geq b \geq c$

$$\Longrightarrow \frac{1}{a+b} \leq \frac{1}{a+c} \leq \frac{1}{b+c}$$

តាមវិសមភាព Chebyshev យើងទាញបាន

$$\begin{aligned}\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b} &= a.\frac{1}{b+c} + b.\frac{1}{c+a} + c.\frac{1}{a+b}\\ &\geq \frac{1}{3}(a+b+c)\left(\frac{1}{b+c} + \frac{1}{c+a} + \frac{1}{a+b}\right)\\ &= \frac{1}{6}[(b+c)+(c+a)+(a+b)]\left(\frac{1}{b+c} + \frac{1}{c+a} + \frac{1}{a+b}\right)\\ &\geq \frac{1}{6}.3\sqrt[3]{(b+c)(c+a)(a+b)}.3\sqrt[3]{\frac{1}{b+c}\frac{1}{c+a}\frac{1}{a+b}}\\ &= \frac{3}{2}\end{aligned}$$

ពិត។

❷ របៀបទី២

តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $a \geq b \geq c$

$$\Longrightarrow \frac{1}{a+b} \leq \frac{1}{a+c} \leq \frac{1}{b+c}$$

តាមវិសមភាពតំរៀប យើងទាញបាន

$$\begin{aligned}&\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b} = a.\frac{1}{b+c} + b.\frac{1}{c+a} + c.\frac{1}{a+b}\\ &\geq a.\frac{1}{c+a} + b.\frac{1}{a+b} + c.\frac{1}{b+c}\end{aligned}$$

និង

$$\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b} \geq a.\frac{1}{a+b} + b.\frac{1}{b+c} + c.\frac{1}{a+c}$$

បូកអង្គនឹងអង្គ យើងទាញបាន

$$2\left(\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}\right)$$
$$\geq a.\frac{1}{c+a}+b.\frac{1}{a+b}+c.\frac{1}{b+c}+a.\frac{1}{a+b}+b.\frac{1}{b+c}+c.\frac{1}{a+c}=3$$
$\Longrightarrow$ វិសមភាពពិត។

223.▲ តាង

$$S=\frac{a^3}{b+c+d}+\frac{b^3}{c+d+a}+\frac{c^3}{d+a+b}+\frac{d^3}{a+b+c}$$
$$x=b+c+d, y=c+d+a, z=d+a+b, t=a+b+c$$
$$x+y+z+t=3(a+b+c+d)$$

ដោយផលបូក S មានលក្ខណៈស៊ីមេទ្រីធៀបនឹង a,b,c,d (ឧទាហរណ៍ ជំនួស a ដោយ b និង b ដោយ a យើងទាញបាន S នៅដដែល) នោះ យើងអាចសន្មតថា $a\geq b\geq c\geq d\Longrightarrow a^n\geq b^n\geq c^n\geq d^n$ ចំពោះគ្រប់ $n\in\mathbb{N}$ និង

$$\frac{1}{x}\geq\frac{1}{y}\geq\frac{1}{z}\geq\frac{1}{t}$$

តាមវិសមភាពតំរៀប យើងមាន $a^2+b^2+c^2+d^2\geq ab+bc+cd+da=1$។

តាមវិសមភាព Chebyshov យើងមាន

$$S=a^3\frac{1}{x}+b^3\frac{1}{y}+c^3\frac{1}{z}+d^3\frac{1}{t}$$
$$\geq\frac{1}{4}(a^3+b^3+c^3+d^3)\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}+\frac{1}{t}\right)$$

និង

$$a^3+b^3+c^3+d^3\geq\frac{1}{4}(a^2+b^2+c^2+d^2)(a+b+c+d)$$
$$\geq\frac{1}{4}(1)(a+b+c+d)=\frac{1}{4}(a+b+c+d)$$
$$\Longrightarrow\quad S\geq\frac{1}{16}(a+b+c+d)\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}+\frac{1}{t}\right)$$
$$\geq\frac{1}{48}(x+y+z+t)\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}+\frac{1}{t}\right)\geq\frac{1}{48}.4\sqrt[4]{xyzt}.4\sqrt[4]{\frac{1}{x}\frac{1}{y}\frac{1}{z}\frac{1}{t}}=\frac{1}{3}$$

224.▲ តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $a\geq b\geq c$ ។ ដូច្នេះ $a^n\geq b^n\geq c^n$ ចំពោះគ្រប់ $n\in\mathbb{N}$ និង

$$\frac{1}{a+b}\leq\frac{1}{a+c}\leq\frac{1}{b+c}$$

តាមវិសមភាពតំរៀប យើងមាន

$$\frac{a^n}{b+c}+\frac{b^n}{c+a}+\frac{c^n}{a+b}\geq\frac{a^n}{a+b}+\frac{b^n}{b+c}+\frac{c^n}{c+a}$$

និង

$$\frac{a^n}{b+c}+\frac{b^n}{c+a}+\frac{c^n}{a+b}\geq\frac{a^n}{c+a}+\frac{b^n}{a+b}+\frac{c^n}{b+c}$$

បូកអង្គនិងអង្គ យើងទាញបាន

$$\frac{a^n}{b+c}+\frac{b^n}{c+a}+\frac{c^n}{a+b}\geq\frac{1}{2}\left(\frac{a^n+b^n}{a+b}+\frac{b^n+c^n}{b+c}+\frac{c^n+a^n}{c+a}\right)$$

តាមវិសមភាព Chebyshev

$$a^n+b^n\geq\frac{1}{2}(a^{n-1}+b^{n-1})(a+b)\ \Rightarrow\frac{a^n+b^n}{a+b}\geq\frac{1}{2}(a^{n-1}+b^{n-1})$$

ដូចគ្នា

$$\frac{b^n+c^n}{b+c}\geq\frac{1}{2}(b^{n-1}+c^{n-1})$$
$$\frac{c^n+a^n}{c+a}\geq\frac{1}{2}(c^{n-1}+a^{n-1})$$
$$\Rightarrow\frac{a^n}{b+c}+\frac{b^n}{c+a}+\frac{c^n}{a+b}\geq\frac{a^{n-1}+b^{n-1}+c^{n-1}}{2}$$

225.▲ តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $x\leq y\leq z$ ។ ដូច្នេះ

$$\frac{1}{(1+y)(1+z)}\leq\frac{1}{(1+z)(1+x)}\leq\frac{1}{(1+x)(1+y)}$$

តាមវិសមភាព Chebyshev យើងទាញបាន

$$\begin{aligned}&\frac{x^3}{(1+y)(1+z)}+\frac{y^3}{(1+z)(1+x)}+\frac{z^3}{(1+x)(1+y)}\\&\geq\frac{x^3+y^3+z^3}{3}\left[\frac{1}{(1+y)(1+z)}+\frac{1}{(1+z)(1+x)}+\frac{1}{(1+x)(1+y)}\right]\\&=\frac{x^3+y^3+z^3}{3}\frac{3+x+y+z}{(1+y)(1+z)(1+x)}\end{aligned}$$

តាង $(x+y+z)/3=a$។ តាមវិសមភាព Chebyshev យើងមាន

$$\frac{x^3+y^3+z^3}{3}\geq\frac{x^2+y^2+z^2}{3}\frac{x+y+z}{3}\geq\frac{x+y+z}{3}.\frac{x+y+z}{3}.\frac{x+y+z}{3}$$
$$=\left(\frac{x+y+z}{3}\right)^3=a^3$$

និង តាមវិសមភាពកូស៊ី

$$3a=x+y+z\geq3\sqrt[3]{xyz}=3$$

$$(1+y)(1+z)(1+x) \leq \left[\frac{(1+y)+(1+z)+(1+x)}{3}\right]^3 = (1+a)^3$$

ដូច្នេះ

$$\frac{x^3}{(1+y)(1+z)} + \frac{y^3}{(1+z)(1+x)} + \frac{z^3}{(1+x)(1+y)} \geq a^3 \frac{6}{(1+a)^3}$$

ដូច្នេះ យើងត្រូវបង្ហាញថា

$$\frac{6a^3}{(1+a)^3} \geq \frac{3}{4}$$

ដោយ $a^3 \geq 1$ នោះ

$$f(a) = \frac{6a^3}{(1+a)^3} = 6\left[1 - \frac{1}{1+a}\right]^3$$

ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}^+$ ។ យើងមាន

$$f(a^3) \geq f(1) = \frac{3}{4}$$

ដូច្នេះវិសមភាពពិត។

226.▲ ❶ របៀបទីមួយ

ចំពោះគ្រប់ចំនួនពិត មិនអវិជ្ជមាន គេមាន

$$\left(\sqrt{a_1} - \sqrt{a_2}\right)^2 \geq 0 \ \Rightarrow \frac{a_1 + a_2}{2} \geq \sqrt{a_1 a_2}$$

ដូច្នេះ វិសមភាពខាងលើពិត ចំពោះ $n = 2$ ។ សន្មតថា វិសមភាពខាងលើពិត រហូតដល់ $n = 2^{k-1}, k > 2$ ។ ដូច្នេះ

$$\sqrt[2^{k-1}]{a_1 a_2 \dots a_{2^{k-1}}} \leq \frac{a_1 + a_2 + \dots + a_{2^{k-1}}}{2^{k-1}}$$

តាង

$$x_1 = \frac{a_1 + a_2 + \dots + a_{2^{k-1}}}{2^{k-1}}$$
$$x_2 = \frac{a_{2^{k-1}+1} + \dots + a_{2^k}}{2^{k-1}}$$

យើងមាន

$$\frac{x_1 + x_2}{2} \geq \sqrt{x_1 x_2}$$

$$\Rightarrow \frac{\frac{a_1+a_2+\cdots+a_{2^{k-1}}}{2^{k-1}}+\frac{a_{2^{k-1}+1}+\cdots+a_{2^k}}{2^{k-1}}}{2}$$
$$\geq \sqrt{\frac{a_1+a_2+\cdots+a_{2^{k-1}}}{2^{k-1}}\cdot\frac{a_{2^{k-1}+1}+\cdots+a_{2^k}}{2^{k-1}}}$$
$$\geq \sqrt{\sqrt[2^{k-1}]{a_1a_2\dots a_{2^{k-1}}}\cdot\sqrt[2^{k-1}]{a_{2^{k-1}+1}\dots a_{2^k}}}=\sqrt[2^k]{a_1a_2\dots a_{2^k}}$$
$$\Rightarrow \frac{a_1+a_2+\cdots+a_{2^k}}{2^k}\geq\sqrt[2^k]{a_1a_2\dots a_{2^k}}$$

ដូច្នេះ វិសមភាពពិតចំពោះ គ្រប់ $n=2^k, k\geq 1$ ។ ឥឡូវសន្មតថា $2^{k-1}<n<2^k$ ។ តាង

$$y_1=a_1, y_2=a_2,\dots,y_n=a_n$$
$$y_{n+1}=y_{n+2}=\cdots=y_{2^k}=A$$
$$A=\frac{a_1+a_2+\cdots+a_n}{n}$$
$$G=\sqrt[n]{a_1a_2\dots a_n}$$

យើងមាន

$$\frac{y_1+y_2+\cdots+y_{2^k}}{2^k}\geq\sqrt[2^k]{y_1y_2\dots y_{2^k}}$$
$$\Leftrightarrow \frac{a_1+a_2+\cdots+a_n+\left(2^k-n\right)A}{2^k}\geq\sqrt[2^k]{a_1a_2\dots a_n.A^{2^k-n}}$$
$$\Leftrightarrow \frac{nA+\left(2^k-n\right)A}{2^k}\geq\sqrt[2^k]{G^nA^{2^k-n}}$$
$$\Leftrightarrow A\geq G^{\frac{n}{2^k}}A^{1-\frac{n}{2^k}}$$
$$\Leftrightarrow A^{\frac{n}{2^k}}\geq G^{\frac{n}{2^k}}$$
$$\Leftrightarrow A\geq G$$
$$\Leftrightarrow \frac{a_1+a_2+\cdots+a_n}{n}\geq\sqrt[n]{a_1a_2\dots a_n}$$

ដូច្នេះវិសមភាពពិតចំពោះគ្រប់ $n\geq 2$ ។

❷ របៀបទីពីរ

អនុគមន៍ $f(x)=\ln x$ ជាអនុគមន៍ប៉ោងលើ $\mathbb{R}^{+*}$ ។ តាមវិសមភាពយិនសិន យើងទាញបាន

$$\ln\left(\frac{1}{n}a_1+\frac{1}{n}a_2+\cdots+\frac{1}{n}a_n\right)\geq\frac{1}{n}\ln a_1+\frac{1}{n}\ln a_2+\cdots+\frac{1}{n}\ln a_n=\ln\sqrt[n]{a_1a_2\dots a_n}$$
$$\Rightarrow \frac{a_1+a_2+\cdots+a_n}{n}\geq\sqrt[n]{a_1a_2\dots a_n}$$

227.▲ តាង $a=x+y, b=y+z, c=z+x$ $(x,y,z>0)$ វិសមភាពដែលអោយសមមូលនឹង

$$6xyz \leq x^2y + xy^2 + y^2z + yz^2 + z^2x + zx^2$$
វិសមភាពនេះពិត ដោយប្រើវិសមភាពមធ្យមនព្វន្តមធ្យមធរណីមាត្រ សំរាប់ $x^2y, xy^2, x^2z, xz^2, y^2z, yz^2$ ។

228.▲ យើងមាន
$$(n!)^{2/n} = \left((1.2.\dots n)^{\frac{1}{n}}\right)^2 \leq \left(\frac{1+2+\cdots+n}{2}\right)^2 = \left(\frac{n+1}{2}\right)^2 \leq \frac{1}{3}n^2 + \frac{1}{2}n + \frac{1}{6}$$

229.▲ តាមវិសមភាពកូស៊ី
$$8a^2b^3c^3 \leq 2a^8 + 3b^8 + 3c^8$$
$$8a^3b^2c^3 \leq 3a^8 + 2b^8 + 3c^8$$
$$8a^3b^3c^2 \leq 3a^8 + 3b^8 + 2c^8$$
បូកវិសមភាពអស់នេះបញ្ចូលគ្នា ហើយចែកនឹង $3a^3b^3c^3$ យើងទាញបានវិសមភាពដែលចង់បាន។

230.▲ តាមវិសមភាពកូស៊ី
$$(n+k-1)x_1^n x_2 \dots x_k \leq nx_1^{n+k-1} + x_2^{n+k-1} + \cdots + x_k^{n+k-1}$$
$$(n+k-1)x_1 x_2^n \dots x_k \leq x_1^{n+k-1} + nx_2^{n+k-1} + \cdots + x_k^{n+k-1}$$
$$\dots \quad \dots$$
$$(n+k-1)x_1 x_2 \dots x_k^n \leq x_1^{n+k-1} + x_2^{n+k-1} + \cdots + nx_k^{n+k-1}$$
បូកវិសមភាពទាំងអស់បញ្ចូលគ្នា បន្ទាប់មកចែកនឹង $(n+k-1)$ យើងទាញបានវិសមភាពដែលត្រូវស្រាយបញ្ជាក់។

231.▲ តាមវិសមភាពកូស៊ី
$$x_1 + x_2 + \cdots + x_n \geq n\sqrt[n]{x_1 x_2 \dots x_n}$$
$$\frac{1}{x_1} + \frac{1}{x_2} + \cdots + \frac{1}{x_n} \geq n\sqrt[n]{\frac{1}{x_1}\frac{1}{x_2}\dots\frac{1}{x_n}}$$
$$\Longrightarrow \quad (x_1 + x_2 + \cdots + x_n)\left(\frac{1}{x_1} + \frac{1}{x_2} + \cdots + \frac{1}{x_n}\right) \geq n^2$$

232.▲ តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $x \leq y \leq z$ ។ តាង
$$f(x,y,z) = x^2 + y^2 + z^2 + x + y + z - 2(xy + yz + zx)$$
យើងមាន
$$\begin{aligned}&f(x,y,z) - f\left(x, \sqrt{yz}, \sqrt{yz}\right)\\&= y^2 + z^2 + y + z - 2(xy + yz + zx) - 2\sqrt{yz} + 4x\sqrt{yz}\\&= (y-z)^2 + \left(\sqrt{y} - \sqrt{z}\right)^2 - 2x\left(\sqrt{y} - \sqrt{z}\right)^2\end{aligned}$$

$$= \left(\sqrt{y}-\sqrt{z}\right)^2\left[\left(\sqrt{y}+\sqrt{z}\right)^2+1-2x\right]$$
$$= \left(\sqrt{y}-\sqrt{z}\right)^2\left[y+z-2x+1+2\sqrt{yz}\right]$$

ដោយ $x \le y \le z$ នោះ $y+z-2x \ge 0 \Rightarrow f(x,y,z)-f\left(x,\sqrt{yz},\sqrt{yz}\right) \ge 0$ ហើយអង្គទាំង២ស្មើគ្នា លុះត្រាតែ $y = z$ ។ បន្ទាប់មកទៀត យើងនឹងបង្ហាញថា $f\left(x,\sqrt{yz},\sqrt{yz}\right) \ge 0$ ។

តាង $a = x$ និង $b = \sqrt{yz}$ ។ ដូច្នេះ $a,b > 0$ និង $ab^2 = 1$ ។ យើងមាន

$$\begin{aligned} f(a,b,b) &= a^2+a+2b-4ab \\ &= \frac{1}{b^4}+\frac{1}{b^2}+2b-\frac{4}{b} \\ &= \frac{1}{b^4}(2b^5-4b^3+b^2+1) \\ &= \frac{1}{b^4}(b-1)^2(2b^3+4b^2+2b+1) \ge 0 \end{aligned}$$

អង្គទាំងពីរស្មើគ្នា លុះត្រាតែ $b = 1$។ ដូច្នេះ $f(x,y,z) \ge f(a,b,b) \ge 0$ ហើយស្មើគ្នា លុះត្រាតែ $y = z, b = 1, xyz = 1 \;\Rightarrow x = y = z = 1$។

233.▲ តាមវិសមភាពកូស៊ី

$$a^2+b^2+c^2+d^2+ab+ac+ad+bc+bd+cd \ge 10\left(a^2b^2c^2d^2abacadbcbdcd\right)^{\frac{1}{10}}$$
$$= 10\left(a^5b^5c^5d^5\right)^{\frac{1}{10}} = 10$$

អង្គទាំង២ស្មើគ្នា ពេល $a = b = c = d = 1$ ។

234.▲ យើងមាន

$$\begin{aligned}(a+b+c)^3 &= a^3+b^3+c^3+6abc+3(a^2b+a^2c+b^2a+b^2c+c^2a+c^2b) \\ &\ge a^3+b^3+c^3+6abc+3.6\sqrt[6]{a^6b^6c^6} = a^3+b^3+c^3+24abc\end{aligned}$$

(តាមវិសមភាពកូស៊ី)

235.▲ ករណីអង្គខាងស្តាំនៃវិសមភាព អវិជ្ជមាន រឺ សូន្យ នោះវិសមភាពជាវិសមភាពដាច់ខាត។ ករណីអង្គខាងស្តាំវិជ្ជមាន យើងសន្មតថា $a = \max(a,b,c)$ ។ ដូច្នេះ $a+b-c > 0$ និង $c+a-b > 0 \;\Rightarrow b+c-a > 0$ ព្រោះអង្គខាងស្តាំវិជ្ជមាន។ ដូច្នេះ a,b,c ជារង្វាស់ជ្រុងនៃត្រីកោណ។ ដូច្នេះ យើងតាង

$$a+b-c = x, b+c-a = y, c+a-b = z$$

$$\Rightarrow \begin{cases} x,y,z > 0 \\ a = \dfrac{x+z}{2}, b = \dfrac{y+x}{2}, c = \dfrac{z+y}{2} \end{cases}$$

វិសមភាពទៅជា

$$(x+z)(y+x)(z+y) \geq 8xyz$$

តាមវិសមភាពកូស៊ី យើងទាញបាន

$$(x+z)(y+x)(z+y) \geq 2\sqrt{xz}.2\sqrt{yx}.2\sqrt{zy} = 8xyz$$

ពិត។ អង្គទាំងពីរស្មើគ្នាទាល់តែនិងមានតែ $x = y = z$ មានន័យថា $a = b = c$ ។

236.▲ តាមវិសមភាពកូស៊ី យើងមាន

$$\prod_{k=1}^{n} a_k(1-a_k) = \left[\prod_{k=1}^{n} a_k\right]\left[\prod_{k=1}^{n}(1-a_k)\right] \leq \left[\frac{1}{n}\sum_{k=1}^{n} a_k\right]^n \left[\frac{1}{n}\sum_{k=1}^{n}(1-a_k)\right]^n = \frac{1}{n^n}.\frac{(n-1)^n}{n^n}$$
$$= \frac{(n-1)^n}{n^{2n}}$$

237.▲ យើងមាន

$$a^2 + b^2 + \frac{1}{a^2} + \frac{b}{a} = \left[b + \frac{1}{2a}\right]^2 + a^2 + \frac{3}{4a^2}$$
$$\geq a^2 + \frac{3}{4a^2} \text{ ស្មើគ្នាទាល់តែ } b = -\frac{1}{2a}$$
$$\geq 2\sqrt{\frac{3}{4}} = \sqrt{3} \quad \text{តាមវិសមភាពកូស៊ី}$$

$$\Rightarrow a^2 + b^2 + \frac{1}{a^2} + \frac{b}{a} \geq \sqrt{3}$$

ស្មើគ្នា លុះត្រាតែ $a^4 = 3/4$ និង $b = -1/2a$ ។

238.▲ តាមវិសមភាពកូស៊ី ចំពោះ $n \geq 2$

$$\left[\left(1+\frac{1}{n-1}\right)^{n-1}\right]^{\frac{1}{n}} < \frac{1 + \left(1+\frac{1}{n-1}\right) + \left(1+\frac{1}{n-1}\right) + \cdots + \left(1+\frac{1}{n-1}\right)}{n}$$
$$= \frac{1 + (n-1)\left(1+\frac{1}{n-1}\right)}{n} = 1 + \frac{1}{n}$$
$$\Rightarrow \left(1+\frac{1}{n-1}\right)^{n-1} < \left(1+\frac{1}{n}\right)^n \quad \Rightarrow U_{n-1} < U_n$$

ម្យ៉ាងវិញទៀត

$$\left[\left(1-\frac{1}{n}\right)^n\right]^{\frac{1}{n+1}} < \frac{1 + \left(1-\frac{1}{n}\right) + \left(1-\frac{1}{n}\right) + \cdots + \left(1-\frac{1}{n}\right)}{n+1} = \frac{1 + n\left(1-\frac{1}{n}\right)}{n+1} = \frac{n}{n+1}$$

$$\Rightarrow \left(\frac{n-1}{n}\right)^n < \left(\frac{n}{n+1}\right)^{n+1} \Leftrightarrow \frac{1}{\left(\frac{n-1+1}{n-1}\right)^n} < \frac{1}{\left(\frac{n+1}{n}\right)^n}$$

$$\Leftrightarrow \frac{1}{\left(1+\frac{1}{n-1}\right)^n} < \frac{1}{\left(1+\frac{1}{n}\right)^n} \Leftrightarrow \frac{1}{V_{n-1}} < \frac{1}{V_n} \Rightarrow V_n < V_{n-1}$$

239.▲ យើងតាង

$$f(a_1, a_2, \dots, a_n) = \frac{a_1}{a_2+a_3} + \frac{a_2}{a_3+a_4} + \dots + \frac{a_{n-1}}{a_n+a_1} + \frac{a_n}{a_1+a_2}$$

ក្នុងសំនេរបន្ទាប់មកទៀតនេះ យើងសន្មតថា $a_{n+1} = a_1; a_{n+2} = a_2; a_{n+3} = a_3; \dots$ ។

$$f(a_1, a_2, \dots, a_n) = \frac{a_1}{a_2+a_3} + \frac{a_2}{a_3+a_4} + \dots + \frac{a_{n-1}}{a_n+a_{n+1}} + \frac{a_n}{a_{n+1}+a_{n+2}}$$

យើងសន្មតថា $a_1 = \max(a_1, a_2, \dots, a_n)$ ។ តាង $i_1 = 1$ ។ តាង i_2 ជាសន្ទស្សន៍របស់ចំនួនធំបំផុតរវាង a_2 និង a_3 គឺ បើ $a_2 > a_3$ យក $i_2 = 2$ និងបើ $a_3 > a_2$ យក $i_2 = 3$ ហើយបើ $a_2 = a_3$ នោះយើងយក $i_2 = 2$ ។ ដូច្នេះ $i_2 \le i_1 + 2$ ។

យើងបង្កើតស្វ៊ីត (i_k) មួយ ដោយកំនើនដូចតទៅនេះ៖

បើ បង្កើតបាន i_k រួចហើយ តាង i_{k+1} ជាសន្ទស្សន៍នៃចំនួនធំជាងគេរវាង a_{i_k+1} និង a_{i_k+2} ដោយបើ $a_{i_k+1} = a_{i_k+2}$ យក $i_{k+1} = i_k + 1$។ ក្នុងលក្ខខណ្ឌនេះ $i_{k+1} \le i_k + 2$។

ដោយ $i_1 = 1$ នោះ $i_{k+1} \le 1 + 2k$ ចំពោះគ្រប់ k ។

ដោយ $a_1 = a_{n+1} = \max(a_1, a_2, \dots, a_n) = \max(a_n, a_{n+1})$ នោះ យើងមាន r ដែល $i_{r+1} = n + 1$ ជាសន្ទស្សន៍របស់ចំនួនធំបំផុតរវាង a_n និង a_{n+1} ដែលត្រូវនឹងចំនួនធំបំផុតរវាង a_{i_r+1} និង a_{i_r+2}។ ដូច្នេះ $i_r = n - 1$ រឺ $i_r = n$ ។ ដូច្នេះ $n - 1 \le i_r \le 1 + 2(r-1)$

$\Rightarrow r \ge n/2$ (1)

☹[*ដើម្បីពន្យល់អំនះអំនាងខាងលើ ខ្ញុំសូមដាក់ឧទាហរណ៍មួយ សន្មតថា* $n = 5; a_1$ *ធំជាងគេនិង* $a_3 > a_2; a_4 > a_5$ ។ *យើងមាន* $i_1 = 1; i_2$ *ជាសន្ទស្សន៍របស់ចំនួនធំបំផុតរវាង* $a_{i_1+1} = a_2$ *និង* $a_{i_1+2} = a_3$ ។ *ដោយ* $a_3 > a_2 \Rightarrow i_2 = 3; i_3$ *ជាសន្ទស្សន៍របស់ចំនួនធំបំផុតរវាង* $a_{i_2+1} = a_4$ *និង* $a_{i_2+2} = a_5$ ។ *ដោយ* $a_4 > a_5$ *នោះ* $i_3 = 4$។ i_4 *ជាសន្ទស្សន៍របស់ចំនួនធំបំផុតរវាង* $a_{i_3+1} = a_5$ *និង* $a_{i_3+2} = a_6 = a_1$ ។ *ដោយ* $a_1 > a_5$ *នោះ* $i_4 = 6$។ *ករណីនេះយើងទាញបាន* $r = 4$ ។ *យើងមាន*

$$f(a_1, a_2, a_3, a_4, a_5) = \frac{a_1}{a_2+a_3} + \frac{a_2}{a_3+a_4} + \frac{a_3}{a_4+a_5} + \frac{a_4}{a_5+a_1} + \frac{a_5}{a_1+a_2}$$
$$> \frac{a_1}{a_2+a_3} + 0 + \frac{a_3}{a_4+a_5} + \frac{a_4}{a_5+a_1} + 0 \ge \frac{a_1}{2a_2} + \frac{a_3}{2a_4} + \frac{a_4}{2a_1} = \frac{a_{i_1}}{2a_{i_2}} + \frac{a_{i_2}}{2a_{i_3}} + \frac{a_{i_3}}{2a_{i_4}}$$

]☺

ដូច្នេះយើងទាញបាន

$$f(a_1,a_2,\dots,a_n) \geq \frac{a_{i_1}}{2a_{i_2}} + \frac{a_{i_2}}{2a_{i_3}} + \cdots + \frac{a_{i_r}}{2a_{i_{r+1}}} \qquad (2)$$

$$\geq \frac{r}{2}\left(\frac{a_{i_1}a_{i_2}\dots a_{i_r}}{a_{i_2}a_{i_3}\dots a_{i_{r+1}}}\right)^{\frac{r}{2}} \quad \text{(វិសមភាពកូស៊ី)}$$

$$= \frac{r}{2} \geq \frac{n}{4}$$

ដើម្បីអោយ $f(a_1,a_2,\dots,a_n) = n/4$ គេត្រូវតែមាន (1) និង (2) ជាសមភាព។ តែសមភាព (2) នាំអោយ $r = n$ តែសមភាពនេះ មិនផ្ទៀងផ្ទាត់សមភាព (1)។ ដូច្នេះ $f(a_1,a_2,\dots,a_n) > n/4$ ។

240.▲ តាមវិសមភាពកូស៊ី ចំពោះគ្រប់ i យើងមាន

$$2 + a_i = 1 + 1 + a_i \geq 3\, a_i^{\frac{1}{3}}$$

$$\Longrightarrow \prod_{i=1}^{n}(2+a_i) \geq 3^n\left(\prod_{i=1}^{n} a_i\right)^{\frac{1}{3}} = 3^n$$

241.▲ ❶ ដោយ a,b ជាចំនួនពិតវិជ្ជមាន នោះគេមាន x,y ដែល $0 < x,y < 90^\circ$ ហើយដែល $\tan x = a; \tan y = b$ ។ វិសមភាពនេះពិត បើ $a = b$។ ដូច្នេះ យើងសន្មតថា $a \neq b$ រឺ សមមូលនឹង $x \neq y$ ។ ដូច្នេះ $1/\sqrt{1+a^2} = \cos x$; $1/\sqrt{1+b^2} = \cos y$ ។ យើងមាន

$$1 + ab = \frac{\cos x\cos y + \sin x\sin y}{\cos x\cos y} = \frac{\cos(x-y)}{\cos x\cos y}$$

ដូច្នេះវិសមភាពសមមូលនឹង

$$\cos x + \cos y \geq 2\sqrt{\frac{\cos x\cos y}{\cos(x-y)}} \qquad (*)$$

$$\Longrightarrow \quad \cos^2 x + \cos^2 y + 2\cos x\cos y \leq \frac{4\cos x\cos y}{\cos(x-y)}$$

ដោយ $0 < |x-y| < 90^\circ$ នោះ $0 < \cos(x-y) < 1$។ ដូច្នេះ $2\cos x\cos y \leq 2\cos x\cos y/\cos(x-y)$ ។ ដូច្នេះយើងគ្រាន់តែបង្ហាញថា

$$\cos^2 x + \cos^2 y \leq \frac{2\cos x\cos y}{\cos(x-y)}$$

$$\Longleftrightarrow \cos(x-y)[\cos^2 x + \cos^2 y] \leq 2\cos x\cos y$$

$$\Longleftrightarrow \cos(x-y)[\cos^2 x + \cos^2 y + 2] \leq 4\cos x\cos y$$

$\Leftrightarrow\ \cos(x-y)[2\cos(x-y)\cos(x+y)+2]\le 2[\cos(x-y)+\cos(x+y)]$
$\Leftrightarrow\ \cos^2(x-y)\cos(x+y)\le\cos(x+y)$
ពិត ព្រោះ $0<a,b\le 1$ យើងមាន $0<x,y<\frac{\pi}{4}$ ដូច្នេះ $0<x+y<\frac{\pi}{2}$ និង $\cos(x+y)>0$ ។

❷ យើងបំលែងវិសមភាព(*) ជា

$$2\cos\frac{x+y}{2}\cos\frac{x-y}{2}\ge 2\sqrt{\frac{1/2[\cos(x+y)+\cos(x-y)\,]}{\cos(x-y)}}$$

$\Leftrightarrow 4\cos^2\frac{x+y}{2}\cos^2\frac{x-y}{2}\cos(x-y)\ge 2[\cos(x+y)+\cos(x-y)]$
$\Leftrightarrow [1+\cos(x+y)][1+\cos(x-y)]\cos(x-y)\ge 2[\cos(x+y)+\cos(x-y)]$
តាង $s=\cos(x+y)$ និង $t=\cos(x-y)$។ ដូច្នេះយើងគ្រាន់តែបង្ហាញថា

$$(1+s)(1+t)t\ge 2(s+t)$$

$\Leftrightarrow\ \ 0\le(1+s)t^2+(s-1)t-2s=(t-1)[(1+s)t+2s]$
ដោយ $t\le 1$ ដូច្នេះយើងគ្រាន់តែបង្ហាញថា $(1+s)t+2s\le 0$
ដោយ $ab\ge 3$ នោះ $\tan x\tan y\ge 3$ វិសមមូលនឹង $\sin x\sin y\ge 3\cos x\cos y$ ។ នាំអោយ

$$\frac{1}{2}[\cos(x-y)-\cos(x+y)]\ge\frac{3}{2}[\cos(x-y)+\cos(x+y)]\Rightarrow t\le -2s$$

ដោយ $1+s\ge 0$ នោះ $(1+s)t\le-(1+s)2s$ ។ យើងទាញបាន $(1+s)t+2s\le$ $-(1+s)2s+2s=-2s^2\le 0$ ដូចដែលចង់បាន។

242.▲ ចំពោះគ្រប់ i តាង $a_i=1/(1+x_i)$ ។ ដូច្នេះ $0<a_i<1, x_i=(1-a_i)/a_i$ និង $a_1+a_2+\cdots+a_{n+1}=1$

$$\Rightarrow\prod_{i=1}^{n+1}x_i=\frac{\prod_{i=1}^{n+1}(1-a_i)}{\prod_{i=1}^{n+1}a_i}$$

តាមវិសមភាពកូស៊ី

$$1-a_i=(a_1+a_2+\cdots+a_{i-1}+a_{i+1}+..+a_{n+1})\ge n\,(a_1a_2\ldots a_{i-1}a_{i+1}\ldots a_{n+1})^{\frac{1}{n}}$$

$$\Leftrightarrow 1-a_i\ge n\left[\prod_{k\ne i}a_k\right]^{\frac{1}{n}}$$

ដោយអង្គទាំងពីស្មើគ្នាបើ $a_k, k\ne i$ ស្មើគ្នាទាំងអស់។ ដូច្នេះ

$$\prod_{i=1}^{n+1}(1-a_i)\ge n^{n+1}\left[\prod_{k\ne 1}a_k\right]^{\frac{1}{n}}\ldots\left[\prod_{k\ne n+1}a_k\right]^{\frac{1}{n}}=n^{n+1}\left[\prod_{i=1}^{n+1}a_i^n\right]^{\frac{1}{n}}=n^{n+1}\prod_{i=1}^{n+1}a_i$$

$$\Longrightarrow \prod_{i=1}^{n+1} x_i = \frac{\prod_{i=1}^{n+1}(1-a_i)}{\prod_{i=1}^{n+1} a_i} \geq n^{n+1}$$

ដោយអង្គទាំងពីរស្មើគ្នា ទាល់តែ $a_1 = a_2 = \cdots = a_{n+1} = 1/(n+1) \Longrightarrow x_1 = x_2 = \cdots = x_{n+1} = n$ ។

243.▲ ចំពោះគ្រប់ចំនួនគត់ k, j តាង $\alpha_{k,j} = x_{j+k}/x_j$ ដែលក្នុងបណ្តាសន្ទស្សន៍ទាំងអស់នេះ បើសន្ទស្សន៍ណាមួយ ធំជាង n យើងដក n ចេញ។ ឧទាហរណ៍ $(n+1)$ ជំនួសដោយ 1; $(n+2)$ ជំនួសដោយ 2; $(2n+1) \to n+1 \to 1$ ។ល។

ដូច្នេះ ចំពោះគ្រប់ k យើងមាន

$$\alpha_{k,1}\alpha_{k,2} \ldots \alpha_{k,n} = \frac{x_{1+k}}{x_1}\frac{x_{2+k}}{x_2}\ldots\frac{x_{n+k}}{x_n} = 1$$

$$x_1 + x_2 + \cdots + x_n = x_{1+j} + x_{2+j} + \cdots + x_{n+j}$$

$$x_{n+j} = x_j$$

តាមវិសមភាពកូស៊ី

$$\begin{aligned}
\sum_{j=1}^{n} \frac{a_j(s-x_j)}{x_j} &= \sum_{j=1}^{n} \frac{a_j(x_1+x_2+\cdots+x_n-x_j)}{x_j} \\
&= \sum_{j=1}^{n} \frac{a_j(x_{1+j}+x_{2+j}+\cdots+x_{n-1+j}+x_{n+j}-x_j)}{x_j} \\
&= \sum_{j=1}^{n} \frac{a_j(x_{1+j}+x_{2+j}+\cdots+x_{n-1+j})}{x_j} \\
&= \sum_{j=1}^{n} a_j\left(\frac{x_{j+1}}{x_j}+\frac{x_{j+2}}{x_j}+\cdots+\frac{x_{j+n-1}}{x_j}\right) = \sum_{j=1}^{n} a_j\,(\alpha_{1,j}+\alpha_{2,j}+\cdots+\alpha_{n-1,j}) \\
&= \sum_{j=1}^{n} a_j\alpha_{1,j} + \sum_{j=1}^{n} a_j\alpha_{2,j} + \cdots + \sum_{j=1}^{n} a_j\alpha_{n-1,j} = \sum_{k=1}^{n-1}\left[\sum_{j=1}^{n} a_j\alpha_{k,j}\right] \\
&\geq \sum_{k=1}^{n-1}\left[n\left(\prod_{j=1}^{n} a_j\alpha_{k,j}\right)^{\frac{1}{n}}\right] = \sum_{k=1}^{n-1}\left[n\left(\prod_{j=1}^{n} a_j\right)^{\frac{1}{n}}\right] = n(n-1)\left(\prod_{j=1}^{n} a_j\right)^{\frac{1}{n}}
\end{aligned}$$

សមភាពកើតមាន ពេល $x_1 = x_2 = \cdots = x_n$ ។ ដូច្នេះ $C(n) = n(n-1)$ ។

244.▲ តាង

$$P = \left(1+\frac{1}{x}\right)\left(1+\frac{1}{y}\right)\left(1+\frac{1}{z}\right);\ Q = \frac{1}{(xyz)^{1/3}}$$

$$\Longrightarrow\quad P = 1+\frac{1}{x}+\frac{1}{y}+\frac{1}{z}+\frac{1}{xy}+\frac{1}{yz}+\frac{1}{zx}+\frac{1}{xyz}$$

តាមវិសមភាពកូស៊ី

$$\frac{1}{x}+\frac{1}{y}+\frac{1}{z}\geq 3Q$$

$$\frac{1}{xy}+\frac{1}{yz}+\frac{1}{zx}\geq 3Q^2$$

$$Q\geq\frac{3}{x+y+z}=3$$

$$\frac{1}{xyz}=Q^3$$

$$\Longrightarrow P\geq 1+3Q+3Q^2+Q^3=(1+Q)^3\geq(1+3)^3=64$$

អង្គទាំង២ស្មើគ្នា ពេល $x=y=z=1/3$ ។

245.▲ ជាដំបូងយើងនឹងបង្ហាញថា ចំពោះគ្រប់ $a,b>0$ គេមាន

$$\frac{a^2-ab+b^2}{a^2+ab+b^2}\geq\frac{1}{3}$$

ហើយអង្គទាំង២ស្មើគ្នា ទាល់តែ $a=b$ ។

យើងមាន

$$\frac{a^2-ab+b^2}{a^2+ab+b^2}\geq\frac{1}{3}\ \Leftrightarrow 3(a^2-ab+b^2)\geq a^2+ab+b^2\ \Leftrightarrow a^2+b^2\geq 2ab$$

ពិត។ អង្គទាំង២ស្មើគ្នា ទាល់តែ $a=b$។ ■

តាង

$$f(x_1,x_2,\dots,x_n)=\sum_{1\leq i<j\leq n}\frac{x_i^9+x_j^9}{x_i^6+x_i^3x_j^3+x_j^6}$$

$$\forall i, a_i=x_i^3$$

យើងមាន $a_1a_2\dots a_n=1$ ហើយ

$$f(x_1,x_2,\dots,x_n)=\sum_{1\le i<j\le n}\frac{x_i^9+x_j^9}{x_i^6+x_i^3x_j^3+x_j^6}=\sum_{1\le i<j\le n}\frac{a_i^3+a_j^3}{a_i^2+a_ia_j+a_j^2}$$

$$=\sum_{1\le i<j\le n}\left[(a_i+a_j)\frac{a_i^2-a_ia_j+a_j^2}{a_i^2+a_ia_j+a_j^2}\right]\ge\sum_{1\le i<j\le n}\left[(a_i+a_j)\frac{1}{3}\right]$$

$$=\frac{1}{3}\sum_{1\le i<j\le n}(a_i+a_j)$$

$$=\frac{1}{3}[(a_1+a_2)+(a_1+a_3)+\cdots+(a_1+a_n)+(a_2+a_3)+(a_2+a_4)$$

$$+\cdots+(a_2+a_n)+\cdots.]=\frac{n-1}{3}(a_1+a_2+\cdots+a_n)$$

$$\ge\frac{n(n-1)}{3}(a_1a_2\dots a_n)^{1/n}=\frac{n(n-1)}{3}$$

$$\Longrightarrow\ f(x_1,x_2,\dots,x_n)\ge\frac{n(n-1)}{3}$$

អង្គទាំង២ស្មើគ្នា ទាល់តែ $x_1=x_2=\cdots=x_n=1$ ។

246.▲ តាង

$$f(a,b,c,d)=abc+bcd+cda+dab-\frac{176}{27}abcd=bc(a+d)+ad\left[b+c-\frac{176}{27}bc\right]$$

យើងឃើញថា $f(a,b,c,d)$ជាទំនាក់ទំនងឆ្លុះ (បើគេប្តូរ a ទៅ b និង b ទៅ a ។ល។ នោះ f នៅដដែល)។

1) ករណី $b+c-\frac{176}{27}bc\le 0$

តាមវិសមភាពកូស៊ី

$$f(a,b,c,d)\le bc(a+d)\le\left[\frac{b+c+(a+d)}{3}\right]^3=\frac{1}{27}$$

$\Longrightarrow$ វិសមភាពពិត។

2) ករណី $b+c-\frac{176}{27}bc>0$

តាមវិសមភាពកូស៊ី

$$f(a,b,c,d)\le bc(a+d)+\left(\frac{a+d}{2}\right)^2\left[b+c-\frac{176}{27}bc\right]=f\left(\frac{a+d}{2},b,c,\frac{a+d}{2}\right)$$

ដូច្នេះ

$f(a,b,c,d)\le f\left(\frac{a+d}{2},b,c,\frac{a+d}{2}\right)=f\left(b,\frac{a+d}{2},\frac{a+d}{2},c\right)$ ព្រោះ f ជាអនុគមន៍ស៊ីមេទ្រី

$$\le f\left(\frac{b+c}{2},\frac{a+d}{2},\frac{a+d}{2},\frac{b+c}{2}\right)=f\left(\frac{a+d}{2},\frac{b+c}{2},\frac{a+d}{2},\frac{b+c}{2}\right)$$

$$\leq f\left(\frac{a+d+b+c}{4},\frac{b+c}{2},\frac{a+d}{2},\frac{a+d+b+c}{4}\right)=f\left(\frac{1}{4},\frac{b+c}{2},\frac{a+d}{2},\frac{1}{4}\right)$$
$$=f\left(\frac{b+c}{2},\frac{1}{4},\frac{1}{4},\frac{a+d}{2}\right)\leq f\left(\frac{1}{4},\frac{1}{4},\frac{1}{4},\frac{1}{4}\right)=\frac{1}{27}$$
$\Longrightarrow$ វិសមភាពពិត។

247.▲ តាង $E=\{(a_1,a_2,\dots,a_n)\in\mathbb{R}^{+*}|a_1+a_2+\dots+a_n=1\}$ និង f ជាអនុគមន៍មួយកំនត់លើ E ដោយ

$$f(a_1,a_2,\dots,a_n)=n^2(n-1)\prod_{k=1}^{n}a_k+\sum_{k=1}^{n}P_k(a_1,a_2,\dots,a_n)$$

ដែល

$$P_k(a_1,a_2,\dots,a_n)=\frac{1}{a_k}\prod_{i=1}^{n}a_i$$

បើ សិនជាគ្រប់ a_i សុទ្ធតែខុសគ្នាទាំងអស់ នោះគេមានពីរក្នុងចំនោមនោះ ឧទាហរណ៍ a_1,a_2 ដែល $a_1<m<a_2$ ដែល $m=(a_1+a_2+\dots+a_n)/n=1/n$ ។

យើងមាន

$$f(a_1,a_2,\dots,a_n)=(a_1+a_2)A+a_1a_2B$$

ដែល

$$A=\prod_{i=3}^{n}a_i\,;\;\; B=n^2(n-1)\prod_{i=3}^{n}a_i+\sum_{i=3}^{n}\frac{P_i(a_1,a_2,\dots,a_n)}{a_1a_2}$$

(បើ $n=2$ យើងតាង $A=1;B=n^2(n-1)$)។ យើងទាញបាន

$$f(m,a_1+a_2-m,\dots,a_n)-f(a_1,a_2,\dots,a_n)=B[m(a_1+a_2-m)-a_1a_2]$$
$$=B(m-a_1)(a_2-m)>0$$

ដូចគ្នា យើងទាញបាន

$$f(m,a_1+a_2-m,\dots,a_n)<f(m,m,\dots,a_n)<\dots<f(m,m,\dots,m)$$

ដូច្នេះ $f(a_1,a_2,\dots,a_n)\leq f(m,m,\dots,m)$ ដោយអង្គទាំងពីរស្មើគ្នាពេល $a_1=a_2=\dots=a_n=m\;\Longrightarrow m=1/n$ ។ ចំពោះ $m=1/n$

$$f(m,m,\dots,m)=\frac{n^2(n-1)}{n^n}+n\frac{1}{n^{n-1}}=\frac{n^3}{n^n}=\frac{1}{n^{n-3}}$$

$$\Longrightarrow f(a_1,a_2,\dots,a_n)\leq\frac{1}{n^{n-3}}$$

$$\Longleftrightarrow\; n^2(n-1)\prod_{k=1}^{n}a_k+\sum_{k=1}^{n}P_k(a_1,a_2,\dots,a_n)\leq\frac{1}{n^{n-3}}$$

$$\Leftrightarrow n^2(n-1)a_1a_2\dots a_n + a_1a_2\dots a_n\ \sum_{k=1}^{n}\frac{1}{a_k} \le \frac{1}{n^{n-3}}$$

$$\Leftrightarrow n^2(n-1) + \sum_{k=1}^{n}\frac{1}{a_k} \le \frac{1}{n^{n-3}}\frac{1}{a_1a_2\dots a_n}$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $a_1 = a_2 = \cdots = a_n = 1/n$ ។

248.▲ តាង $a_0 = 1-(a_1+a_2+\cdots+a_n)$ ។ យើងមាន

$$a_0 > 0,$$

$$\sum_{k=0}^{n} a_k = 1,$$

$$\frac{a_1a_2\dots a_n(1-a_1-a_2-\cdots-a_n)}{(a_1+a_2+\cdots+a_n)(1-a_1)(1-a_2)\dots(1-a_n)} = \frac{\prod_{k=0}^{n}a_k}{\prod_{k=0}^{n}(1-a_k)}$$

តាមវិសមភាពកូស៊ីយើងមាន

$$1-a_i = \left[\sum_{k=0}^{n}a_k\right]-a_i = \sum_{k\neq i}a_k \ge n\left[\prod_{k\neq i}a_k\right]^{\frac{1}{n}}$$

